

ឯកសារគម្ពីព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ១ ដល់ ភាគ៥០
គឺជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងបុត្រធីតា,
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស ៗ និងទុកក្នុង
គេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៗ

កែសម្រួលតាមកុំព្យូទ័រ តម្រូវឧបករណ៍អានអេឡិត្រូនិច
ដោយខ្ញុំព្រះករុណា ខ្ញុំបាទ ស្រុង-ចាន់ណា ៕

www.5000-years.org

# ព្រះ
# ត្រៃបិដកបាលី
និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# សំយុត្តនិកាយ ខន្ធវារវគ្គ
# ឆដ្ឋភាគ
# ៣៤

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព. ស. ២៥០៦

# សុត្តន្តបិដកេ

## សំយុត្តនិកាយស្ស ខន្ធវារវគ្គោ

## ឆដ្ឋភាគោ

---

## ខន្ធសំយុត្តំ

### អន្តវគ្គោ

(១) សាវត្ថី ។បេ។ តត្រ ខោ ។បេ។ អវោច ចត្តារោមេ ភិក្ខវេ អន្តា ។ កតមេ ចត្តារោ ។ សក្កាយន្តោ សក្កាយសមុទយន្តោ សក្កាយនិរោធន្តោ សក្កាយនិរោធគាមិនីបដិបទន្តោ ។

(២) កតមោ ច ភិក្ខវេ សក្កាយន្តោ ។ បញ្ចុបាទានក្ខន្ធាតិស្ស វចនីយំ ។ កតមេ បញ្ច ។ សេយ្យថីទំ រូបុបាទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ។ អយំ វុច្ចតិ ភិក្ខវេ សក្កាយន្តោ ។

# សុត្តន្តបិដក

# សំយុត្តនិកាយ ខន្ធវារវគ្គ

## ផ្ទុំភាគ

## ខន្ធសំយុត្ត

## អន្តវគ្គ

(១) ក្រុងសាវត្ថី ។ បេ ។ ក្នុងទីនោះឯង ។ បេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អន្ត: (ចំណែក) នេះ មាន ៤ យ៉ាង ។ អន្ត: ៤ យ៉ាង តើដូចម្តេច ។ អន្ត:គឺសក្កាយ ១ អន្ត:គឺហេតុឲ្យកើតឡើងនៃសក្កាយ ១ អន្ត:គឺសេចក្តីរលត់នៃសក្កាយ ១ អន្ត:គឺបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃសក្កាយ ១ ។

(២) ម្នាលភិក្ខុទាំងឡាយ ចុះអន្ត:គឺសក្កាយ តើដូចម្តេច ។ គប្បីឆ្លើយថា ឧបាទានក្ខន្ធទាំង៥ ។ ឧបាទានក្ខន្ធទាំង៥ តើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អន្ត:គឺសក្កាយ ។

(៣) កតមោ ច ភិក្ខវេ សក្កាយសមុទយោ ។ យាយំ តណ្ហា ពោនោព្ភវិកា(១) នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី ។ សេយ្យថីទំ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ អយំ វុច្ចតិ ភិក្ខវេ សក្កាយសមុទយោ ។

(៤) កតមោ ច ភិក្ខវេ សក្កាយនិរោធោ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។ អយំ វុច្ចតិ ភិក្ខវេ សក្កាយនិរោធោ ។

(៥) កតមោ ច ភិក្ខវេ សក្កាយនិរោធគាមិនីបដិបទា ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ អយំ វុច្ចតិ ភិក្ខវេ សក្កាយនិរោធគាមិនីបដិបទា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អន្តាតិ ។

---

១ ឱ. ពោនព្ភវិកា ។

( ៣ ) ម្នាលភិក្ខុទាំងឡាយ ចុះអន្តៈគឺហេតុឲ្យកើតឡើងនៃសក្កាយ តើដូចម្តេច ។ តណ្ហាណា ដែលតាក់តែងនូវភពថ្មី ប្រកបដោយសេចក្តីរីករាយនិងសេចក្តីត្រេកអរ មានសេចក្តីរីករាយក្នុងអារម្មណ៍នោះ ៗ ។ តណ្ហា តើដូចម្តេច ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អន្តៈគឺហេតុឲ្យកើតឡើងនៃសក្កាយ ។

( ៤ ) ម្នាលភិក្ខុទាំងឡាយ ចុះអន្តៈគឺសេចក្តីរលត់នៃសក្កាយ តើដូចម្តេច ។ សេចក្តីវិនាសនិងសេចក្តីរលត់មិនមានសល់ នៃតណ្ហានោះ កិរិយាលះបង់ កិរិយារលាស់ចោល នូវតណ្ហានោះ កិរិយារួចចាកតណ្ហានោះ សេចក្តីមិនអាល័យក្នុងតណ្ហានោះ ឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អន្តៈគឺសេចក្តីរលត់នៃសក្កាយ ។

( ៥ ) ម្នាលភិក្ខុទាំងឡាយ ចុះអន្តៈគឺបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃសក្កាយ តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ។ តើដូចម្តេចខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ ការនិយាយត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ សេចក្តីរឭកត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អន្តៈគឺបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃសក្កាយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាអន្តៈ (ចំណែក) ទាំង ៤ យ៉ាង ។

(៦) សាវត្ថី ។ ទុក្ខញ្ច វោ ភិក្ខវេ ទេសិស្សាមិ ទុក្ខសមុទយញ្ច ទុក្ខនិរោធញ្ច ទុក្ខនិរោធគាមិនីបដិបទញ្ច តំ សុណាថ ។

(៧) កតមញ្ច ភិក្ខវេ ទុក្ខំ ។ បញ្ចុបាទានក្ខន្ធាតិស្ស វចនីយំ ។ កតមេ បញ្ច ។ សេយ្យថីទំ រូបុបាទានក្ខន្ធោ ។បេ។ វិញ្ញាណុបាទានក្ខន្ធោ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ ។

(៨) កតមោ ច ភិក្ខវេ ទុក្ខសមុទយោ ។ យាយំ តណ្ហា ពោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី ។ សេយ្យថីទំ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខសមុទយោ ។

(៦) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង នូវទុក្ខផង នូវហេតុឲ្យកើតឡើងនៃទុក្ខផង នូវសេចក្តីរលត់នៃទុក្ខផង នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃទុក្ខផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវសេចក្តីនោះចុះ ។

(៧) ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខ តើដូចម្តេច ។ គប្បីឆ្លើយថា ឧបាទានក្ខន្ធទាំង ៥ ។ ចុះឧបាទានក្ខន្ធទាំង ៥ តើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខ ។

(៨) ម្នាលភិក្ខុទាំងឡាយ ចុះហេតុឲ្យកើតឡើងនៃទុក្ខ តើដូចម្តេច ។ តណ្ហាណា ដែលតាក់តែងនូវភពថ្មី ប្រកបដោយសេចក្តីរេកពយនិងសេចក្តីត្រេកអរ មានសេចក្តីរេកពយក្នុងអារម្មណ៍នោះៗ ។ តណ្ហា តើដូចម្តេច ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ហេតុឲ្យកើតឡើងនៃទុក្ខ ។

[៩] កតមោ ច ភិក្ខវេ ទុក្ខនិរោធោ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធោ ។

[១០] កតមា ច ភិក្ខវេ ទុក្ខនិរោធគាមិនីបដិបទា ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធគាមិនីបដិបទាតិ ។

[១១] សាវត្ថី ។ សក្កាយញ្ច វោ ភិក្ខវេ ទេសិស្សាមិ សក្កាយសមុទយញ្ច សក្កាយនិរោធញ្ច សក្កាយនិរោធគាមិនីបដិបទញ្ច តំ សុណាថ ។

(៩) ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់នៃទុក្ខ តើដូចម្តេច ។ សេចក្តីវិនាសនិងសេចក្តីរលត់មិនមានសល់ នៃតណ្ហានោះ ការលះបង់ ការរលាស់ចោល នូវតណ្ហានោះ ការរួចចាកតណ្ហានោះ សេចក្តីមិនអាល័យ ក្នុងតណ្ហានោះ ឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីរលត់នៃទុក្ខ ។

(១០) ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃទុក្ខ តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង ។ តើដូចម្តេចខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។បេ។ ការតម្កល់ចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃទុក្ខ ។

(១១) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវសក្កាយផង នូវហេតុឲ្យកើតឡើងនៃសក្កាយផង នូវសេចក្តីរលត់នៃសក្កាយផង នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់ នៃសក្កាយផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់ នូវសេចក្តីនោះចុះ ។

(១២) កតមោ ច ភិក្ខវេ សក្កាយោ ។ បញ្ចុបាទានក្ខន្ធាតិស្ស វចនីយំ ។ កតមេ បញ្ច ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ ។បេ។ វិញ្ញាណូបាទានក្ខន្ធោ ។ អយំ វុច្ចតិ ភិក្ខវេ សក្កាយោ ។

(១៣) កតមោ ច ភិក្ខវេ សក្កាយសមុទយោ ។ យាយំ តណ្ហា ពោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី ។ សេយ្យថីទំ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ អយំ វុច្ចតិ ភិក្ខវេ សក្កាយសមុទយោ ។

(១៤) កតមោ ច ភិក្ខវេ សក្កាយនិរោធោ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។ អយំ វុច្ចតិ ភិក្ខវេ សក្កាយនិរោធោ ។

(១២) ម្នាលភិក្ខុទាំងឡាយ ចុះសក្កាយ តើដូចម្តេច ។ គប្បីឆ្លើយថា ឧបាទានក្ខន្ធទាំង ៥ ។ ឧបាទានក្ខន្ធទាំង ៥ តើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សក្កាយ ។

(១៣) ម្នាលភិក្ខុទាំងឡាយ ចុះហេតុឲ្យកើតឡើងនៃសក្កាយ តើដូចម្តេច ។ តណ្ហាណា ដែលតាក់តែងនូវភពថ្មី ប្រកបដោយសេចក្តីរីករាយនិងសេចក្តីត្រេកអរ មានសេចក្តីរីករាយក្នុងអារម្មណ៍នោះ ៗ ។ តើដូចម្តេចខ្លះ ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ហេតុឲ្យកើតឡើងនៃសក្កាយ ។

(១៤) ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់នៃសក្កាយ តើដូចម្តេច ។ សេចក្តីវិនាសនិងសេចក្តីរលត់មិនមានសល់ នៃតណ្ហានោះ គឺកិរិយាលះបង់ កិរិយារលាស់ចោល នូវតណ្ហានោះ កិរិយារួចចាកតណ្ហានោះ សេចក្តីមិនអាល័យក្នុងតណ្ហានោះ ឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីរលត់នៃសក្កាយ ។

(១៥) កតមា ច ភិក្ខវេ សក្កាយនិរោធគាមិនីបដិបទា ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ ។បេ។ សម្មាសមាធិ ។ អយំ វុច្ចតិ ភិក្ខវេ សក្កាយនិរោធគាមិនីបដិបទាតិ ។

(១៦) សាវត្ថិ ។ បរិញ្ញេយ្យេ ច ភិក្ខវេ ធម្មេ ទេសិស្សាមិ បរិញ្ញញ្ច បរិញ្ញាតាវិញ្ច បុគ្គលំ តំ សុណាថ ។

(១៧) កតមេ ច ភិក្ខវេ បរិញ្ញេយ្យា ធម្មា ។ រូបំ ភិក្ខវេ បរិញ្ញេយ្យោ ធម្មោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ បរិញ្ញេយ្យោ ធម្មោ ។ ឥមេ វុច្ចន្តិ ភិក្ខវេ បរិញ្ញេយ្យា ធម្មា ។

(១៨) កតមា ច ភិក្ខវេ បរិញ្ញា ។ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ។ អយំ វុច្ចតិ ភិក្ខវេ បរិញ្ញា ។

( ១៥ ) ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃសក្កាយ តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង ។ តើដូចម្តេចខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ ។ បេ ។ ការតម្កល់ចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃសក្កាយ ។

( ១៦ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ដែលបុគ្គលគប្បីកំណត់ដឹងផង នូវការកំណត់ដឹងផង នូវបុគ្គលអ្នកកំណត់ដឹងផង អ្នកទាំងឡាយចូរស្តាប់នូវសេចក្តីនោះចុះ ។

( ១៧ ) ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលបុគ្គលគប្បីកំណត់ដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបជាធម៌ដែលបុគ្គលគប្បីកំណត់ដឹង ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជាធម៌ដែលបុគ្គលគប្បីកំណត់ដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលបុគ្គលគប្បីកំណត់ដឹង ។

( ១៨ ) ម្នាលភិក្ខុទាំងឡាយ ចុះការកំណត់ដឹង តើដូចម្តេច ។ ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការកំណត់ដឹង ។

(១៩) កតមោ ច ភិក្ខវេ បរិញ្ញាតាវី បុគ្គលោ ។ អរហាតិស្ស វចនីយំ ។ យោ អយំ(១) អាយស្មា ឯវំនាមោ ឯវំគោត្តោ ។ អយំ វុច្ចតិ ភិក្ខវេ បរិញ្ញាតាវី បុគ្គលោតិ ។

(២០) សាវត្ថី ។ បញ្ចិមេ ភិក្ខវេ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ សេយ្យថីទំ រូបុបាទានក្ខន្ធោ ។បេ។ វិញ្ញាណុបាទានក្ខន្ធោ ។ យេ កេចិ(២) ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ ។ ន មេ តេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បនាយស្មន្តោ(៣) សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

១ ម. ស្វាយំ ។ ២ ឱ.ម. យេ ហិ កេចិ ។ ៣ ន បន តេ អាយស្មន្តោតិ ជាហេ មញ្ញេ ភវេយ្យុំ ។

(១៩) ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកកំណត់ដឹង តើដូចម្តេច ។ គប្បីឆ្លើយថា ព្រះអរហន្ត ។ គឺលោកមានអាយុណា មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលអ្នកកំណត់ដឹង ។

(២០) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធនេះមាន ៥ យ៉ាង ។ ៥ យ៉ាងតើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់តាមពិត នូវអានិសង្សផង នូវទោសផង នៃឧបាទានក្ខន្ធទាំង ៥ នេះ នូវការរលាស់ចេញនូវឧបាទានក្ខន្ធទាំង ៥ នេះផង ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនុ៎ះ តថាគតមិនបានសន្មតថាជាសមណៈក្នុងពួកសមណៈផង មិនសន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង អ្នកទាំងនោះ រមែងមិនធ្វើឲ្យជាក់ច្បាស់ មិនសម្រេច ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវប្រយោជន៍នៃសមណភាព ឬប្រយោជន៍នៃព្រាហ្មណភាពទេ ។

[២១] យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានន្តិ ។ តេ ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

[២២] បញ្ចិមេ ភិក្ខវេ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធោ ។ យេ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ ។ បេ ។ បជានន្តិ ។ បេ ។ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ដឹងច្បាស់តាមពិត នូវអាទិនវផង នូវទោសផង នៃឧបាទានក្ខន្ធទាំង ៥ នេះ នូវការរលាស់ចេញឧបាទានក្ខន្ធទាំង ៥ នេះផង ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ ទាំងនោះឯង តថាគតសន្មតថាជាសមណៈក្នុងពួកសមណៈផង សន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង អ្នកទាំងនោះ រមែងធ្វើឲ្យជាក់ច្បាស់ សម្រេច ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវប្រយោជន៍នៃសមណភាព ឬប្រយោជន៍នៃព្រាហ្មណភាព ។

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធនេះ មាន ៥ យ៉ាង ។ ៥ យ៉ាងតើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬ ព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់តាមពិត នូវសេចក្តីកើតឡើងផង នូវសេចក្តីអស់ទៅផង នូវអានិសង្សផង នូវទោសផង នៃឧបាទានក្ខន្ធទាំង ៥ នេះ នូវការរលាស់ចេញឧបាទានក្ខន្ធទាំង ៥ នេះផង ។ បេ ។ ដឹងច្បាស់ ។ បេ ។ រមែងធ្វើឲ្យជាក់ច្បាស់ សម្រេច ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ។

(២៣) បញ្ចិមេ ភិក្ខវេ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធោ ។ យតោ ខោ ភិក្ខវេ អរិយសាវកោ ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(២៤) សាវត្ថី ។ បញ្ចិមេ ភិក្ខវេ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធោ ។ យតោ ខោ ភិក្ខវេ ភិក្ខុ ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា អនុបាទា វិមុត្តោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិត-

[២៣] ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធនេះ មាន ៥ យ៉ាង ។ ៥ យ៉ាងតើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវក ដឹងច្បាស់តាមពិត នូវសេចក្តីកើតឡើងផង សេចក្តីអស់ទៅផង អានិសង្សផង ទោសផង នៃឧបាទានក្ខន្ធទាំង ៥ នេះ នូវការរលាស់ចេញឧបាទានក្ខន្ធទាំង ៥ នេះផង ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកនេះហៅថា សោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹង ជាទីប្រព្រឹត្តទៅក្នុងខាងមុខ ។

[២៤] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធនេះមាន ៥ យ៉ាង ។ ៥ យ៉ាងតើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុដឹងច្បាស់តាមពិត នូវសេចក្តីកើតឡើងផង សេចក្តីអស់ទៅផង អានិសង្សផង ទោសផង នៃឧបាទានក្ខន្ធទាំង ៥ នេះ នូវការរលាស់ចេញឧបាទានក្ខន្ធទាំង ៥ នេះផង ហើយរួចស្រឡះដោយមិនបានប្រកាន់មាំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា អរហន្តខីណាស្រព មានមគ្គព្រហ្មចរិយៈប្រព្រឹត្តគ្រប់គ្រាន់ហើយ មានសោឡសកិច្ចធ្វើហើយ មានភារៈដាក់

ភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា វិមុត្តោតិ ។

[២៨] សាវត្ថី ។ រូបេ ភិក្ខវេ យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា តំ បជហថ ឯវន្តំ រូបំ បហីនំ ភវិស្សតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា តំ បជហថ ឯវន្តំ វិញ្ញាណំ បហីនំ ភវិស្សតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មន្តិ ។

ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចហើយ មានសញ្ញោជនៈក្នុងភពគឺតណ្ហាអស់ហើយ ជាអ្នករួចស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ។

[ ៤៩ ] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងរូប អ្នកទាំងឡាយ ចូរលះបង់នូវសេចក្តីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ រូបនោះ មុខជាអ្នកទាំងឡាយនឹងលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតឡើងតទៅបាន ជាពុំខាន សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារ ។ ក្នុងវិញ្ញាណ អ្នកទាំងឡាយចូរលះបង់ នូវសេចក្តីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ វិញ្ញាណនោះ មុខជាអ្នកទាំងឡាយនឹងលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតឡើងតទៅបាន ជាពុំខាន ។

[២៦] សាវត្ថិ ។ រូបេ ភិក្ខវេ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ បជហថ ឯវន្តំ រូបំ បហីនំ ភវិស្សតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ យោ ឆន្ទោ ។ បេ ។ ឯវន្តេ សង្ខារា បហីនា ភវិស្សន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ វិញ្ញាណេ យោ ឆន្ទោ

(២៦) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ឧបាយ(១) និងឧបាទាន ដែលជាទីឈរ ជាទីអង្គុយ ជាទីដេកនៅនៃចិត្តណា ក្នុងរូប អ្នកទាំងឡាយចូរលះបង់ នូវសេចក្តីពេញចិត្ត ជាដើមនោះចេញ កាលបើយ៉ាងនេះ រូបនោះ មុខជាអ្នកទាំងឡាយនឹងលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតទៀតតទៅបាន ជាតុំខាន ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ សេចក្តីពេញចិត្តណា ក្នុងសង្ខារ ។ បេ ។ កាលបើយ៉ាងនេះ សង្ខារទាំងនោះ មុខជាអ្នកទាំងឡាយនឹងលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតទៀតតទៅបាន ជាតុំខាន ។ សេចក្តីពេញចិត្តណា

---

១ ជាឈ្មោះនៃតណ្ហានិងទិដ្ឋិ ។

យោ រាគោ យា នន្ទី យា តណ្ហា យេ ឧបាយុបាទា-
នា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ បជហថ
ឯវន្តំ វិញ្ញាណំ បហីនំ ភវិស្សតិ ឧច្ឆិន្នមូលំ តាលា-
វត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មន្តិ ។

អត្តវគ្គោ បឋមោ ។

## តស្សុទ្ទានំ

អត្តោ ទុក្ខញ្ច(១) សក្កាយោ
បរិញ្ញេយ្យា សមណា ទុវេ(២)
សោតាបន្នោ អរហា(៣) ច
ទុវេ ច ឆន្ទប្បហីនាតិ(៤) ។

១ ឱ. អត្តេ ទុក្ខញ្ច ។ ២ ឱ. សមណា ទ្វេ ។ ៣ ឱ. អរហញ្ច ។ ៤ ឱ. ម. ឆន្ទរាគិនោ ។

សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ឧបាយ និងឧបាទាន ដែលជាទីឈរ ជាទីអង្គុយ ជាទីដេកនៅ នៃចិត្តណា ក្នុងវិញ្ញាណ អ្នកទាំងឡាយចូរលះបង់ នូវសេចក្តីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ វិញ្ញាណនោះ មុខជាអ្នកទាំងឡាយនឹងលះបង់ គាស់រំលើងបុសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតទៀតទៅបាន ជាពុំមាន ៕

ចប់ អត្តវគ្គ ទី ១ ។

## ឧទ្ទាននៃអត្តវគ្គនោះគឺ

និយាយអំពីអត្តៈគឺបំណែក ១ ទុក្ខ ១ សក្កាយ ១ ធម៌ដែលបុគ្គលគប្បីកំណត់ដឹង ១ ពួកសមណព្រាហ្មណ៍មាន ២ លើក សោតាបន្នបុគ្គល ១ ព្រះអរហន្ត ១ បុគ្គលលះបង់នូវសេចក្តីពេញចិត្ត ២ លើក ៕

# ធម្មកថិកវគ្គោ

[២៧] សាវត្ថី ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ។ បេ ។ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អវិជ្ជា អវិជ្ជាតិ ភន្តេ វុច្ចតិ កតមា នុ ខោ ភន្តេ អវិជ្ជា កិត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។ ឥធ ភិក្ខុ អស្សុតវា បុថុជ្ជនោ រូបំ នប្បជានាតិ រូបសមុទយំ នប្បជានាតិ រូបនិរោធំ នប្បជានាតិ រូបនិរោធគាមិនឹ បដិបទំ នប្បជានាតិ ។ វេទនំ នប្បជានាតិ ។ សញ្ញំ នប្បជានាតិ ។ សង្ខារេ នប្បជានាតិ ។ វិញ្ញាណំ នប្បជានាតិ ។ បេ ។ វិញ្ញាណនិរោធគាមិនឹ បដិបទំ នប្បជានាតិ ។ អយំ វុច្ចតិ ភិក្ខុ អវិជ្ជា ឯត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។

# ធម្មកថិកវគ្គ

(២៧) ក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមួយរូបចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយហើយ បានក្រាបទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលហៅថា អវិជ្ជា អវិជ្ជា បពិត្រព្រះអង្គដ៏ចំរើន អវិជ្ជាតើដូចម្តេច បុគ្គលប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលភិក្ខុ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនដឹងច្បាស់នូវរូប មិនដឹងច្បាស់នូវហេតុនាំឲ្យកើតរូប មិនដឹងច្បាស់នូវសេចក្តីរលត់រូប មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់រូប ។ មិនដឹងច្បាស់នូវវេទនា ។ មិនដឹងច្បាស់នូវសញ្ញា ។ មិនដឹងច្បាស់នូវសង្ខារទាំងឡាយ ។ មិនដឹងច្បាស់នូវវិញ្ញាណ ។ បេ ។ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់វិញ្ញាណ ។ ម្នាលភិក្ខុ នេះហៅថា អវិជ្ជា បុគ្គលប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងនេះ ។

(២៨) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច វិជ្ជា វិជ្ជាតិ ភន្តេ វុច្ចតិ កតមា នុ ខោ ភន្តេ វិជ្ជា កិត្តាវតា ច វិជ្ជាគតោ ហោតីតិ ។ ឥធ ភិក្ខុ សុតវា អរិយសាវកោ រូបំ បជានាតិ រូបសមុទយំ ។ បេ ។ រូបនិរោធគាមិនីបដិបទំ បជានាតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ បជានាតិ ។ បេ ។ វិញ្ញាណនិរោធគាមិនីបដិបទំ បជានាតិ ។ អយំ វុច្ចតិ ភិក្ខុ វិជ្ជា ឯត្តាវតា ច វិជ្ជាគតោ ហោតីតិ ។

(២៩) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ធម្មកថិកោ ធម្មកថិកោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ធម្មកថិកោ ហោតិ កិត្តាវតា ធម្មានុធម្មប្បដិបន្នោ ហោតិ កិត្តាវតា ទិដ្ឋធម្មនិព្វានប្បត្តោ ហោតីតិ ។ រូបស្ស ចេ ភិក្ខុ

[ ២៨ ] ក្រុងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា វិជ្ជា វិជ្ជា បពិត្រព្រះអង្គដ៏ចម្រើន វិជ្ជាតើដូចម្ដេច បុគ្គលប្រកបដោយវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលភិក្ខុ អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង រមែងដឹងច្បាស់នូវរូប នូវហេតុនាំឲ្យកើតរូប ។ បេ ។ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្ដីរលត់រូប ។ នូវវេទនា ។ នូវសញ្ញា ។ ដឹងច្បាស់នូវសង្ខារទាំងឡាយ ។ បេ ។ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់សេចក្ដីរលត់វិញ្ញាណ ។ ម្នាលភិក្ខុ នេះហៅថា វិជ្ជា បុគ្គលប្រកបដោយវិជ្ជា ដោយហេតុយ៉ាងនេះ ។

[ ២៩ ] ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា ធម្មកថិក ធម្មកថិក បពិត្រព្រះអង្គដ៏ចម្រើន ធម្មកថិក តើដោយហេតុយ៉ាងណា ភិក្ខុអ្នកប្រតិបត្តិធម៌សមគួរតាមធម៌ ដោយហេតុយ៉ាងណា ភិក្ខុអ្នកដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ដោយហេតុយ៉ាងណា ។ ម្នាលភិក្ខុ

និព្វិទាយ វិរាគាយ និរោធាយ ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ រូបស្ស ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ធម្មានុធម្មប្បដិបន្នោ ភិក្ខូតិ អលំ វចនាយ ។ រូបស្ស ចេ ភិក្ខុ និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ទិដ្ឋធម្មនិព្វានប្បត្តោ ភិក្ខូតិ អលំ វចនាយ ។ វេទនាយ ចេ ភិក្ខុ ។ បេ ។ សញ្ញាយ ចេ ភិក្ខុ ។ សង្ខារានំ ចេ ភិក្ខុ ។ វិញ្ញាណស្ស ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ វិញ្ញាណស្ស ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ធម្មានុធម្មប្បដិបន្នោ ភិក្ខូតិ អលំ វចនាយ ។ វិញ្ញាណស្ស ចេ ភិក្ខុ និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ទិដ្ឋធម្មនិព្វានប្បត្តោ ភិក្ខូតិ អលំ វចនាយាតិ ។

បើភិក្ខុសំដែងធម៌ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់រូប ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។ ម្នាលភិក្ខុ បើភិក្ខុប្រតិបត្តិ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់រូប ទើបគួរហៅថា ភិក្ខុអ្នកប្រតិបត្តិធម៌ សមគួរតាមធម៌ ។ ម្នាលភិក្ខុ បើភិក្ខុរួចផុតស្រឡះ ព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះសេចក្តីរលត់ ព្រោះមិនប្រកាន់ នូវរូប ទើបគួរហៅថា ភិក្ខុអ្នកដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុ បើវេទនា ។ បេ ។ ម្នាលភិក្ខុ បើសញ្ញា ។ ម្នាលភិក្ខុ បើសង្ខារទាំងឡាយ ។ ម្នាលភិក្ខុ បើភិក្ខុសំដែងធម៌ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់វិញ្ញាណ ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។ ម្នាលភិក្ខុ បើភិក្ខុប្រតិបត្តិ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់វិញ្ញាណ ទើបគួរហៅថា ភិក្ខុអ្នកប្រតិបត្តិធម៌សមគួរតាមធម៌ ។ ម្នាលភិក្ខុ បើភិក្ខុរួចស្រឡះព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះសេចក្តីរលត់ ព្រោះមិនប្រកាន់នូវវិញ្ញាណ ទើបគួរហៅថា ភិក្ខុអ្នកដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

(៣០) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ធម្មកថិកោ ធម្មកថិកោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ធម្មកថិកោ ហោតិ កិត្តាវតា ធម្មានុធម្មប្បដិបន្នោ ហោតិ កិត្តាវតា ទិដ្ឋធម្មនិព្ពានប្បត្តោ ហោតីតិ ។ រូបស្ស ចេ ភិក្ខុ និព្ពិទាយ វិរាគាយ និរោធាយ ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ រូបស្ស ចេ ភិក្ខុ និព្ពិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ធម្មានុធម្មប្បដិបន្នោ ភិក្ខូតិ អលំ វចនាយ ។ រូបស្ស ចេ ភិក្ខុ និព្ពិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ទិដ្ឋធម្មនិព្ពានប្បត្តោ ភិក្ខូតិ អលំ វចនាយ ។ វេទនាយ ចេ ភិក្ខុ ។បេ។ សញ្ញាយ ចេ ភិក្ខុ ។ សង្ខារានំ ចេ ភិក្ខុ ។ វិញ្ញាណស្ស ចេ ភិក្ខុ និព្ពិទាយ វិរាគាយ និរោធាយ ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ វិញ្ញាណស្ស ចេ ភិក្ខុ និព្ពិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ

( ៣០ ) គ្រង់សាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា ធម្មកថិក ធម្មកថិក បពិត្រព្រះអង្គដ៏ចម្រើន ធម្មកថិក តើដោយហេតុយ៉ាងណា ភិក្ខុអ្នកប្រតិបត្តិធម៌សមគួរតាមធម៌ ដោយហេតុយ៉ាងណា ភិក្ខុអ្នកដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ដោយហេតុយ៉ាងណា ។ ម្នាលភិក្ខុ បើភិក្ខុសំដែងធម៌ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់រូប ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។ ម្នាលភិក្ខុ បើភិក្ខុប្រតិបត្តិ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់រូប ទើបគួរហៅថា ភិក្ខុអ្នកប្រតិបត្តិធម៌សមគួរតាមធម៌ ។ ម្នាលភិក្ខុ បើភិក្ខុរួចស្រឡះ ព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះសេចក្តីរលត់ ព្រោះមិនបានប្រកាន់នូវរូប ទើបគួរហៅថា ភិក្ខុអ្នកដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុ បើវេទនា ។ បេ ។ ម្នាលភិក្ខុ បើសញ្ញា ។ ម្នាលភិក្ខុ បើសង្ខារទាំងឡាយ ។ ម្នាលភិក្ខុ បើភិក្ខុសំដែងធម៌ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់វិញ្ញាណ ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។ ម្នាលភិក្ខុ បើភិក្ខុប្រតិបត្តិ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់វិញ្ញាណ

ធម្មានុធម្មប្បដិបន្នោ ភិក្ខូតិ អលំ វចនាយ ។ វិញ្ញា-ណស្ស ចេ ភិក្ខុ និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ទិដ្ឋធម្មនិព្វានប្បត្តោ ភិក្ខូតិ អលំ វចនាយាតិ ។

(៣១) សាវត្ថី ។ ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី ។បេ។ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មិំ វា អត្តានំ ។ អយំ វុច្ចតិ ភិក្ខវេ អស្សុតវា បុថុជ្ជនោ រូបពន្ធនពទ្ធោ សន្តរពាហិរពន្ធនពទ្ធោ អតីរទស្សី អបារទស្សី ពទ្ធោ ជិយ្យតិ(១) ពទ្ធោ មិយ្យតិ ពទ្ធោ អស្មា លោកា បរំ លោកំ គច្ឆតិ ។ វេទនំ អត្តតោ សមនុបស្សតិ ។បេ។ វេទនាយ វា អត្តានំ ។ អយំ វុច្ចតិ ភិក្ខវេ អស្សុតវា បុថុជ្ជនោ វេទនាពន្ធនពទ្ធោ សន្តរពាហិរពន្ធនពទ្ធោ អតីរទស្សី អបារទស្សី ពទ្ធោ ជិយ្យតិ ពទ្ធោ មិយ្យតិ

១ ជាយតីតិបិ ញាហោ ។

ទើបគួរហៅថា ភិក្ខុអ្នកប្រតិបត្តិធម៌សមគួរតាមធម៌ ។ ម្នាលភិក្ខុ បើភិក្ខុរួចស្រឡះ ព្រោះនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះសេចក្តីរលត់ ព្រោះមិនប្រកាន់នូវវិញ្ញាណ ទើបគួរហៅថា ភិក្ខុអ្នកដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

( ៣១ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ ។ បេ ។ មិនបានសិក្សាក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ នូវខ្លួនថាមានរូបខ្លះ នូវរូបថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងរូបខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុថុជ្ជនអ្នកមិនចេះដឹង ជាប់ដោយចំណងគឺរូប ជាប់ដោយចំណងទាំងខាងក្នុងទាំងខាងក្រៅ ជាអ្នកមិនឃើញនូវឆ្នេរគឺវដ្តៈ មិនឃើញនូវត្រើយគឺព្រះនិព្វាន រមែងចាស់ទាំងជាប់ចំណង ស្លាប់ទាំងជាប់ចំណង ចេញចាកលោកនេះទៅកាន់លោកខាងមុខ ទាំងជាប់ចំណង ។ ពិចារណាឃើញ នូវវេទនាថាជាខ្លួនខ្លះ ។ បេ ។ នូវខ្លួនថាមានក្នុងវេទនាខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុថុជ្ជនអ្នកមិនចេះដឹង ជាប់ដោយចំណងគឺវេទនា ជាប់ដោយចំណងទាំងខាងក្នុងទាំងខាងក្រៅ មិនឃើញនូវឆ្នេរ មិនឃើញនូវត្រើយ រមែងចាស់ទាំងជាប់ចំណង ស្លាប់ទាំងជាប់ចំណង

ពទ្ធោ អស្មា លោកា បរំ លោកំ គច្ឆតិ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អស្សុតវា បុថុជ្ជនោ វិញ្ញាណពន្ធនពទ្ធោ សាន្តរពាហិរពន្ធនពទ្ធោ អតីរទស្សី អបារទស្សី ពទ្ធោ ជិយ្យតិ ពទ្ធោ មិយ្យតិ ពទ្ធោ អស្មា លោកា បរំ លោកំ គច្ឆតិ ។

[៣២] សុតវា ច ខោ ភិក្ខវេ អរិយសាវកោ អរិយានំ ទស្សាវី ។ បេ ។ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ។ អយំ វុច្ចតិ ភិក្ខវេ សុតវា អរិយសាវកោ នរូបពន្ធនពទ្ធោ នសាន្តរពាហិរពន្ធនពទ្ធោ តីរទស្សី បារទស្សី បរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ បេ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ

ចេញចាកលោកនេះ ទៅកាន់លោកខាងមុខ ទាំងជាប់ចំណង ៗ ពិចារណាឃើញនូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ នូវវិញ្ញាណថាជាខ្លួន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុថុជ្ជនអ្នកមិនចេះដឹង ជាប់ដោយចំណងគឺវិញ្ញាណ ជាប់ដោយចំណងទាំងខាងក្នុង ទាំងខាងក្រៅ មិនឃើញនូវឆ្នេរ មិនឃើញនូវត្រើយ រមែងចាស់ទាំងជាប់ចំណង ស្លាប់ទាំងជាប់ចំណង ចេញចាកលោកនេះទៅកាន់លោកខាងមុខទាំងជាប់ចំណង ៗ

( ៣២ ) ម្នាលភិក្ខុទាំងឡាយ ចំណែកខាងអរិយសាវ័កជាអ្នកចេះដឹង បានឃើញពួកព្រះអរិយៈ ។ បេ ។ បានសិក្សាក្នុងធម៌របស់សប្បុរស មិនពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ នូវខ្លួនថាមានរូបខ្លះ នូវរូបថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងរូបខ្លះឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អរិយសាវ័កអ្នកចេះដឹង មិនជាប់ដោយចំណងគឺរូប មិនជាប់ដោយចំណងទាំងខាងក្នុងទាំងខាងក្រៅ ឃើញនូវឆ្នេរ ឃើញនូវត្រើយ តថាគតពោលថា អរិយសាវ័កនោះផុតស្រឡះចាកទុក្ខ ។ បេ ។ មិនពិចារណាឃើញនូវសញ្ញា ។ មិនពិចារណាឃើញនូវសង្ខារទាំងឡាយ ។ មិនពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា

សុតវា អរិយសាវកោ ន វិញ្ញាណពន្ធនពន្ធោ ន សន្តរពាហិរពន្ធនពន្ធោ តីរទស្សី បារទស្សី បរិមុត្តោ សោ ទុក្ខស្មាតិ វទាមីតិ ។

(៣៣) សាវត្ថី ។ តំ កិំ មញ្ញថ ភិក្ខវេ រូបំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សថាតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ រូបំ ភិក្ខវេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សថាតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ វិញ្ញាណំ ភិក្ខវេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

អរិយសាវ័កអ្នកចេះដឹង មិនដាច់ដោយចំណង់ គឺវិញ្ញាណ មិនដាច់ដោយចំណង់ទាំងខាងក្នុងទាំងខាងក្រៅ ឃើញនូវនេះ ឃើញនូវត្រើយ តថាគតពោលថា អរិយសាវ័កនោះផុតស្រឡះចាកទុក្ខ ។

( ៣៣ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ហេតុនោះដូចម្តេច អ្នកទាំងឡាយពិចារណាឃើញនូវរូបថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរឃើញតាមពិតនូវរូបនុ៎ះដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ អ្នកទាំងឡាយពិចារណាឃើញនូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ នូវវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរឃើញតាមពិតនូវវិញ្ញាណនុ៎ះដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ បេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៣៤) សាវត្ថី ។ តត្រ ខោ ។ តំ កឹ មញ្ញថ ភិក្ខវេ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សថាតិ ។ ឯវំ ភន្តេ ។ សាធុ ភិក្ខវេ រូបំ ភិក្ខវេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សថាតិ ។ ឯវំ ភន្តេ ។ សាធុ ភិក្ខវេ វិញ្ញាណំ ភិក្ខវេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

( ៣៦ ) ក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ហេតុនោះដូចម្តេច អ្នកទាំងឡាយពិចារណាឃើញនូវរូបថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរឃើញតាមពិត នូវរូបនុ៎ះដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ អ្នកទាំងឡាយពិចារណាឃើញនូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ នូវវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរឃើញតាមពិត នូវវិញ្ញាណនុ៎ះដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៣៥) សាវត្ថិ ។ សញ្ញោជនិយេ ច ភិក្ខវេ ធម្មេ ទេសិស្សាមិ សញ្ញោជនញ្ច តំ សុណាថ ។ កតមេ ច ភិក្ខវេ សញ្ញោជនិយា ធម្មា កតមំ សញ្ញោជនំ ។ រូបំ ភិក្ខវេ សញ្ញោជនិយោ ធម្មោ យោ តត្ថ ឆន្ទ-រាគោ តំ តត្ថ សញ្ញោជនំ ។ វេទនា ។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ សញ្ញោជនិយោ ធម្មោ យោ តត្ថ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ ឥមេ វុច្ចន្តិ ភិក្ខវេ សញ្ញោជនិយា ធម្មា ឥទំ សញ្ញោជនន្តិ ។

(៣៦) សាវត្ថិ ។ ឧបាទានិយេ ច ភិក្ខវេ ធម្មេ ទេសិស្សាមិ ឧបាទានញ្ច តំ សុណាថ ។ កតមេ ច ភិក្ខវេ ឧបាទានិយា ធម្មា កតមំ ឧបាទានំ ។ រូបំ ភិក្ខវេ ឧបាទានិយោ ធម្មោ យោ តត្ថ ឆន្ទរាគោ

( ៣៥ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវពួកធម៌ជាបច្ច័យរបស់សញ្ញោជនៈផង នូវតួសញ្ញោជនៈផង អ្នកទាំងឡាយ ចូរស្តាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ជាបច្ច័យរបស់សញ្ញោជនៈ ដូចម្តេច តួសញ្ញោជនៈ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូប ជាធម៌ដែលជាបច្ច័យរបស់សញ្ញោជនៈ សេចក្តីត្រេកត្រអាលណា ក្នុងរូបនោះ សេចក្តីត្រេកត្រអាលនោះ ក្នុងរូបនោះ ឈ្មោះថាតួសញ្ញោជនៈ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ ជាធម៌ដែលជាបច្ច័យរបស់សញ្ញោជនៈ សេចក្តីត្រេកត្រអាលណា ក្នុងវិញ្ញាណនោះ សេចក្តីត្រេកត្រអាលនោះ ក្នុងវិញ្ញាណនោះ ឈ្មោះថាតួសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ពួកធម៌ជាបច្ច័យរបស់សញ្ញោជនៈ នេះ ជាតួសញ្ញោជនៈ ។

( ៣៦ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវពួកធម៌ជាបច្ច័យរបស់ឧបាទានផង នូវតួឧបាទានផង អ្នកទាំងឡាយ ចូរស្តាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ជាបច្ច័យរបស់ឧបាទាន ដូចម្តេច តួឧបាទាន ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូប ជាធម៌ដែលជាបច្ច័យរបស់ឧបាទាន សេចក្តីត្រេកត្រអាលណា ក្នុងរូបនោះ

តំ តត្ថ ឧបាទានំ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ ឧបាទានិយោ ធម្មោ យោ តត្ថ ឆន្ទរាគោ តំ តត្ថ ឧបាទានំ ។ ឥមេ វុច្ចន្តិ ភិក្ខវេ ឧបាទានិយា ធម្មា ឥទំ ឧបាទានន្តិ ។

(៣៧) ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាកោដ្ឋិតោ(១) ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថខោ អាយស្មា មហាកោដ្ឋិតោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ។ បេ ។ ឯតទវោច សីលវតាវុសោ សារីបុត្ត ភិក្ខុនា កតមេ ធម្មា យោនិសោ មនសិកាតព្វាតិ ។ សីលវតាវុសោ កោដ្ឋិត ភិក្ខុនា បញ្ចុបាទានក្ខន្ធា អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ យោនិសោ មនសិកាតព្វា ។ កតមេ បញ្ច ។ សេយ្យថីទំ រូបុបា-

១ មហាកោដ្ឋិកោតិ ភា បាឋោ ។

សេចក្ដីត្រេកត្រអាលនោះ ក្នុងរូបនោះ ឈ្មោះថាតួឧបាទាន ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ ជាធម៌ដែលជាបច្ច័យរបស់ឧបាទាន សេចក្ដីត្រេកត្រអាលណា ក្នុងវិញ្ញាណនោះ សេចក្ដីត្រេកត្រអាលនោះ ក្នុងវិញ្ញាណនោះ ឈ្មោះថាតួឧបាទាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ពួកធម៌ជាបច្ច័យរបស់ឧបាទាន នេះជាតួឧបាទាន ។

( ៣៧ ) សម័យមួយ ព្រះសារីបុត្តមានអាយុ និងព្រះមហាកោដ្ឋិតៈមានអាយុ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ គ្រានោះ ព្រះមហាកោដ្ឋិតៈមានអាយុ ចេញចាកទីសម្ងំក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះសារីបុត្តមានអាយុ ។ បេ ។ បានពោលពាក្យនេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុអ្នកមានសីល គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្ដេច ។ ម្នាលអាវុសោកោដ្ឋិតៈ ភិក្ខុអ្នកមានសីល គួរធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ ថាមិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសរ ជាជម្ងឺ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សូន្យ ជារបស់មិនមែនខ្លួន ។ ឧបាទានក្ខន្ធទាំង ៥ ដូចម្ដេច ។ គឺរូបូបា-

ទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ។ សីលវតាវុសោ កោដ្ឋិត ភិក្ខុនា ឥមេ បញ្ចុបាទានក្ខន្ធា អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ យោនិសោ មនសិកាតព្វា ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ សីលវា ភិក្ខុ ឥមេ បញ្ចុបាទានក្ខន្ធេ អនិច្ចតោ ។បេ។ អនត្តតោ យោនិសោ មនសិករោន្តោ សោតាបត្តិផលំ សច្ឆិករេយ្យាតិ ។

(៣៨) សោតាបន្នេន បនាវុសោ សារីបុត្ត ភិក្ខុនា កតមេ ធម្មា យោនិសោ មនសិកាតព្វាតិ ។ សោតាបន្នេនបិ ខោ អាវុសោ កោដ្ឋិត ភិក្ខុនា ឥមេ បញ្ចុបាទានក្ខន្ធា អនិច្ចតោ ។ បេ ។ អនត្តតោ យោនិសោ មនសិកាតព្វា ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ សោតាបន្នោ ភិក្ខុ ឥមេ បញ្ចុបាទានក្ខន្ធេ អនិច្ចតោ ។ បេ ។ អនត្តតោ យោនិសោ មនសិករោន្តោ សកទាគាមិផលំ សច្ឆិករេយ្យាតិ ។

ទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលអាវុសោកោដ្ឋិតៈ ភិក្ខុអ្នកមានសីល គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះ ថា មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសរ ជាជម្ងឺ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សូន្យ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ ហេតុនេះតែងមានប្រាកដ គឺត្រង់ដែលភិក្ខុមានសីល កាលធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលបាន ។

[៣៨ ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុជាសោតាបន្ន គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្តេច ។ ម្នាលអាវុសោកោដ្ឋិតៈ ទោះបីភិក្ខុជាសោតាបន្ន ក៏គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ ហេតុនេះតែងមានប្រាកដ គឺត្រង់ដែលភិក្ខុជាសោតាបន្ន កាលធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះ ថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន នឹងធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលបាន ។

(៣៩) សកទាគាមិនា បនាវុសោ សារីបុត្ត ភិក្ខុនា កតមេ ធម្មា យោនិសោ មនសិកាតព្វាតិ ។ សកទាគាមិនាបិ ខោ អាវុសោ កោដ្ឋិត ភិក្ខុនា ឥមេ បញ្ចុបាទានក្ខន្ធា អនិច្ចតោ ។បេ។ អនត្តតោ យោនិសោ មនសិកាតព្វា ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ សកទាគាមី ភិក្ខុ ឥមេ បញ្ចុបាទានក្ខន្ធេ អនិច្ចតោ ។បេ។ អនត្តតោ យោនិសោ មនសិករោន្តោ អនាគាមិផលំ សច្ឆិករេយ្យាតិ ។

(៤០) អនាគាមិនា បនាវុសោ សារីបុត្ត ភិក្ខុនា កតមេ ធម្មា យោនិសោ មនសិកាតព្វាតិ ។ អនាគាមិនាបិ ខោ អាវុសោ កោដ្ឋិត ភិក្ខុនា ឥមេ បញ្ចុបាទានក្ខន្ធា អនិច្ចតោ ។បេ។ អនត្តតោ យោនិសោ មនសិកាតព្វា ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អនាគាមី ភិក្ខុ ឥមេ បញ្ចុបាទានក្ខន្ធេ អនិច្ចតោ ។បេ។ អនត្តតោ យោនិសោ មនសិករោន្តោ អរហត្តំ សច្ឆិករេយ្យាតិ ។

( ៣៩ ) ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុជាសកទាគាមី គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្តេច ។ ម្នាលអាវុសោកោដ្ឋិតៈ ទោះបីភិក្ខុជាសកទាគាមី ក៏គួរធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ ហេតុនេះតែងមានប្រាកដ គឺត្រង់ដែលភិក្ខុជាសកទាគាមី កាលធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន នឹងធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលបាន ។

( ៤០ ) ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុជាអនាគាមី គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្តេច ។ ម្នាលអាវុសោកោដ្ឋិតៈ ទោះបីភិក្ខុជាអនាគាមី ក៏គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ ហេតុនេះតែងមានប្រាកដ គឺត្រង់ដែលភិក្ខុជាអនាគាមី កាលធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន នឹងធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលបាន ។

(៦៣) អរហតា បនាវុសោ សារីបុត្ត កតមេ ធម្មា យោនិសោ មនសិកាតព្វាតិ។ អរហតាបិ ខោ អាវុសោ កោដ្ឋិត ឥមេ បញ្ចុបាទានក្ខន្ធា អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ យោនិសោ មនសិកាតព្វា ។ នត្ថិ ខោ អាវុសោ អរហតោ ឧត្តរិ-ករណីយំ កតស្ស វា បដិច្ចយោ អបិ ចិមេ ធម្មា ភាវិតា ពហុលីកតា ទិដ្ឋធម្មសុខវិហារាយ ចេវ សំ-វត្តន្តិ សតិសម្បជញ្ញាយ ចាតិ ។

(៦២) ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាកោដ្ឋិតោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថខោ អាយស្មា មហា-កោដ្ឋិតោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្ក-

(៤១) ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុជាព្រះអរហន្ត គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្តេច ។ ម្នាលអាវុសោកោដ្ឋិតៈ ទោះបីភិក្ខុជាព្រះអរហន្ត ក៏គួរធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះថា មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសរ ជាជម្ងឺ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សូន្យ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ សេចក្តីសន្សំរបស់ភិក្ខុជាព្រះអរហន្ត ដែលធ្វើករណីយកិច្ចទៅទៀតឥតមានទេ ប៉ុន្តែធម៌ទាំងនេះ ដែលព្រះអរហន្តបានចម្រើន បានធ្វើរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្នផង ដើម្បីសតិសម្បជញ្ញៈផង ។

(៤២) សម័យមួយ ព្រះសារីបុត្តមានអាយុ និងព្រះមហាកោដ្ឋិតៈមានអាយុ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ គ្រានោះឯង ព្រះកោដ្ឋិតៈមានអាយុ ចេញចាកទីសម្ងំក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅ

ភិក្ខូ ។បេ។ ឯតទវោច សុតវតាវុសោ សារីបុត្ត ភិក្ខុនា កតមេ ធម្មា យោនិសោ មនសិកាតព្វាតិ ។ សុតវតាវុសោ កោដ្ឋិត ភិក្ខុនា បញ្ចុបាទានក្ខន្ធា អនិច្ចតោ ។បេ។ អនត្តតោ យោនិសោ មនសិកាតព្វា ។ កតមេ បញ្ច ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ ។បេ។ វិញ្ញាណូបាទានក្ខន្ធោ ។ សុតវតាវុសោ កោដ្ឋិត ភិក្ខុនា ឥមេ បញ្ចុបាទានក្ខន្ធា អនិច្ចតោ ។បេ។ អនត្តតោ យោនិសោ មនសិកាតព្វា ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ សុតវា ភិក្ខុ ឥមេ បញ្ចុបាទានក្ខន្ធេ អនិច្ចតោ ។បេ។ អនត្តតោ យោនិសោ មនសិករោន្តោ សោតាបត្តិផលំ សច្ឆិករេយ្យាតិ ។

ដល់ហើយ ។ បេ ។ បានពោលពាក្យនេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុមានសេចក្តីចេះដឹង គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្តេច ។ ម្នាលអាវុសោកោដ្ឋិតៈ ភិក្ខុមានសេចក្តីចេះដឹង គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ ថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន ។ ឧបាទានក្ខន្ធទាំង៥ដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលអាវុសោកោដ្ឋិតៈ ភិក្ខុមានសេចក្តីចេះដឹង គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះ ថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ ហេតុនេះតែងមានប្រាកដ គឺត្រង់ដែលភិក្ខុមានសេចក្តីចេះដឹង កាលធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះ ថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលបាន ។

(៤៣) សោតាបន្នេន បនាវុសោ សារីបុត្ត ភិក្ខុនា កតមេ ធម្មា យោនិសោ មនសិកាតព្វាតិ ។ សោតាបន្នេនបិ ខោ អាវុសោ កោដ្ឋិត ភិក្ខុនា ឥមេ បញ្ចុបាទានក្ខន្ធា អនិច្ចតោ ។ បេ ។ អនត្តតោ យោនិសោ មនសិកាតព្វា ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ សោតាបន្នោ ភិក្ខុ ឥមេ បញ្ចុបាទានក្ខន្ធេ អនិច្ចតោ ។ បេ ។ អនត្តតោ យោនិសោ មនសិករោន្តោ សកទាគាមិផលំ ។ បេ ។ អនាគាមិផលំ ។ បេ ។ អរហត្តផលំ សច្ឆិករេយ្យាតិ ។

(៤៤) អរហតា បនាវុសោ សារីបុត្ត កតមេ ធម្មា យោនិសោ មនសិកាតព្វាតិ ។ អរហតាបិ ខោ អាវុសោ កោដ្ឋិត ឥមេ បញ្ចុបាទានក្ខន្ធា អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ យោនិសោ មនសិកាតព្វា ។ នត្ថិ ខោ អាវុសោ អរហតោ ឧត្តរិករណីយំ កតស្ស វា បតិចយោ អបិ

[ ៤៣ ] ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុជាសោតាបន្ន គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្ដេចទៀត ។ ម្នាលអាវុសោកោដ្ឋិត: ទោះបីភិក្ខុជាសោតាបន្ន ក៏គួរធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះ ថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ ហេតុនេះតែងមានប្រាកដ គឺត្រង់ដែលភិក្ខុជាសោតាបន្ន កាលធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះ ថា មិនទៀង ។ បេ ។ ជារបស់មិនមែនខ្លួន នឹងធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលបាន ។ បេ ។ នូវអនាគាមិផលបាន ។ បេ ។ នូវអរហត្តផលបាន ។

[ ៤៤ ] ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុជាព្រះអរហន្ត គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដូចម្ដេចទៀត ។ ម្នាលអាវុសោកោដ្ឋិត: ទោះបីភិក្ខុជាព្រះអរហន្ត ក៏គួរធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះឧបាទានក្ខន្ធទាំង ៥ នេះ ថា មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសរ ជាជម្ងឺ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សូន្យ ជារបស់មិនមែនខ្លួន ។ ម្នាលអាវុសោ សេចក្ដីសន្សំរបស់ភិក្ខុជាព្រះអរហន្ត ដែលធ្វើនូវករណីយកិច្ចតទៅទៀត ឥតមានទេ

ចិមេ ធម្មា ភាវិតា ពហុលីកតា ទិដ្ឋធម្មសុខវិហារាយ ចេវ សំវត្តន្តិ សតិសម្បជញ្ញាយ ចាតិ ។

(៤៨) សាវត្ថី ។ អថខោ អាយស្មា រាហុលោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាហុលោ ភគវន្តំ ឯតទវោច កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។ យំ កិញ្ចិ រាហុល រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ យា កាចិ វេទនា ។ បេ ។ យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា

ប៉ុន្តែធម៌ទាំងនេះ ដែលព្រះអរហន្តបានចំរើនហើយ បានធ្វើរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្នផង ដើម្បីសតិសម្បជញ្ញៈផង ។

[៤៥] ក្រុងសាវត្ថី ។ គ្រានោះឯង ព្រះកប្បៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។បេ។ លុះព្រះកប្បៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គលដឹងដូចម្តេច ឃើញដូចម្តេច បានជាមិនមានអហង្ការមមង្ការនិងមានានុស័យ ក្នុងកាយប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំងអស់ជាខាងក្រៅផង ។ ម្នាលកប្បៈ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឬរូបណាដែលមានក្នុងទីឆ្ងាយក្តី ជិតក្តី បុគ្គលឃើញរូបទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណាមួយ ។បេ។ សញ្ញាណាមួយ ។ សង្ខារទាំងឡាយណាមួយ ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី

យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេ-សោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ ឯវំ ខោ រាហុល ជានតោ ឯវំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។

(៩២) សាវត្ថី ។ អថ ខោ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាហុលោ ភគវន្តំ ឯតទវោច កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការ-មមង្ការមានាបគតំ មានសំ ហោតិ វិធា សមតិក្កន្តំ សន្តំ សុវិមុត្តន្តិ ។ យំ កិញ្ចិ រាហុល រូបំ អតីតានាគត-

ឬវិញ្ញាណណា ដែលមានក្នុងទីឆ្ងាយក្តី ទីជិតក្តី បុគ្គលឃើញវិញ្ញាណទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ម្នាលកប្បៈ កាលបើបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ទើបមិនមានអហង្ការមមង្ការនិងមានានុស័យ ក្នុងកាយប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំងអស់ជាខាងក្រៅផង ។

(៨៦) ក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ លុះព្រះកប្បៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដឹងដូចម្តេច ឃើញដូចម្តេច ទើបមានចិត្តប្រាសចាកអហង្ការមមង្ការនិងមានានុស័យ ក្នុងកាយប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំងអស់ជាខាងក្រៅផង ជាចិត្តកន្លងដោយប្រពៃចាកវិធាននៃមានះ រម្ងាប់ទូកិលេស ផុតស្រឡះចាកកិលេស ។ ម្នាលកប្បៈ រូបណាមួយ ជាអតីត អនាគត

តបច្ចុប្បន្នំ ។បេ។ សព្វំ រូបំ នេតំ មម នេសោហ-
មស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្ប-
ញ្ញាយ ទិស្វា អនុបាទា វិមុត្តោ ហោតិ ។ យា កាចិ
វេទនា ។ យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា ។
យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា
ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ
វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម
នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថា-
ភូតំ សម្មប្បញ្ញាយ ទិស្វា អនុបាទា វិមុត្តោ ហោតិ ។
ឯវំ ខោ កប្ប ជានតោ ឯវំ បស្សតោ ឥមស្មិញ្ច
សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ
អហង្ការមមង្ការមានាបគតំ មានសំ ហោតិ វិធា សម-
តិក្កន្តំ សន្តំ សុវិមុត្តន្តិ ។

ធម្មកថិកវគ្គោ ទុតិយោ ។

បច្ចុប្បន្ន ។បេ។ បុគ្គលឃើញរូបទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញដូច្នេះហើយ ឈ្មោះថាជាអ្នករួចស្រឡះ ព្រោះមិនមានសេចក្ដីប្រកាន់ ។ វេទនាណាមួយ ។ សញ្ញាណាមួយ ។ សង្ខារទាំងឡាយណាមួយ ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្តមក្ដី ឬវិញ្ញាណណា ដែលមានក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី បុគ្គលឃើញវិញ្ញាណទាំងអស់នុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញដូច្នេះហើយ ទើបឈ្មោះថាជាអ្នករួចស្រឡះ ព្រោះមិនមានសេចក្ដីប្រកាន់ ។ ម្នាលកប្បៈ បុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ទើបមានចិត្តប្រាសចាកអហង្ការមមង្ការនិងមានានុស័យ ក្នុងកាយប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំងអស់ខាងក្រៅផង ជាចិត្តកន្លងដោយប្រពៃចាកចំណែកនៃមានះ រម្ងាប់នូវកិលេស ផុតស្រឡះចាកកិលេស ។

ចប់ ធម្មកថិកវគ្គ ទី ២ ។

## តត្រុទ្ទានំ

អវិជ្ជវិជ្ជា ទ្វេ កថិកា
ពន្ធនា បរិមុច្ចិតា ទ្វេ
សញ្ញោជនំ ឧបាទានំ
សីលំ សុតវា ទ្វេ ច កប្បេនាតិ ។

---

# ឧទានក្នុងធម្មកថិកវគ្គនោះ គឺ

ពោលអំពីអវិជ្ជា ១ វិជ្ជា ១ ធម្មកថិក ២ លើក ចំណង ១ បុគ្គលប្រ្យបាកទុក្ខ ២ លើក សញ្ញោជនៈ ១ ឧបាទាន ១ សីល ១ កិច្ចមានការចេះដឹង ១ កិច្ចឈ្មោះកប្បៈ ២ លើក ។

# អវិជ្ជាវគ្គោ

(៤៧) សាវត្ថី ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។បេ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អវិជ្ជា អវិជ្ជាតិ ភន្តេ វុច្ចតិ កតមា នុ ខោ ភន្តេ អវិជ្ជា កិត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។ ឥធ ភិក្ខុ អស្សុតវា បុថុជ្ជនោ សមុទយធម្មំ រូបំ សមុទយធម្មំ រូបន្តិ យថាភូតំ នប្បជានាតិ វយធម្មំ រូបំ វយធម្មំ រូបន្តិ យថាភូតំ នប្បជានាតិ សមុទយវយធម្មំ រូបំ សមុទយវយធម្មំ រូបន្តិ យថាភូតំ នប្បជានាតិ សមុទយធម្មំ វេទនំ សមុទយធម្មា វេទនាតិ យថាភូតំ នប្បជានាតិ វយធម្មំ វេទនំ វយធម្មា វេទនាតិ យថាភូតំ នប្បជានាតិ ។បេ។ នប្បជានាតិ សមុទយធម្មំ សញ្ញំ ។បេ។

# អវិជ្ជាវគ្គ

(៤៧) ក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមួយរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលហៅថា អវិជ្ជា អវិជ្ជា បពិត្រព្រះអង្គដ៏ចំរើន អវិជ្ជា តើដូចម្តេច បុគ្គលឈ្មោះថាប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលភិក្ខុ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនដឹងច្បាស់តាមពិត នូវរូបដែលកើតឡើងជាធម្មតាថា រូបកើតឡើងជាធម្មតា មិនដឹងច្បាស់តាមពិត នូវរូបដែលសូន្យទៅជាធម្មតាថា រូបសូន្យទៅជាធម្មតា មិនដឹងច្បាស់តាមពិត នូវរូបដែលកើតឡើងហើយសូន្យទៅជាធម្មតាថា រូបកើតឡើងហើយសូន្យទៅជាធម្មតា មិនដឹងច្បាស់តាមពិត នូវវេទនាដែលកើតឡើងជាធម្មតាថា វេទនាកើតឡើងជាធម្មតា មិនដឹងច្បាស់តាមពិត នូវវេទនាដែលសូន្យទៅជាធម្មតាថា វេទនាសូន្យទៅជាធម្មតា ។ បេ ។ នូវសញ្ញាដែលកើតឡើងជាធម្មតា ។ បេ ។

នប្បជានាតិ សមុទយធម្មេ សង្ខារេ សមុទយធម្មា សង្ខារាតិ យថាភូតំ នប្បជានាតិ វយធម្មេ សង្ខារេ វយធម្មា សង្ខារាតិ យថាភូតំ នប្បជានាតិ សមុទយវយធម្មេ សង្ខារេ សមុទយវយធម្មា សង្ខារាតិ យថាភូតំ នប្បជានាតិ សមុទយធម្មំ វិញ្ញាណំ សមុទយធម្មំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ វយធម្មំ វិញ្ញាណំ វយធម្មំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ សមុទយវយធម្មំ វិញ្ញាណំ សមុទយវយធម្មំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ អយំ វុច្ចតិ ភិក្ខុ អវិជ្ជា ឯត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។

មិនដឹងច្បាស់តាមពិត នូវសង្ខារទាំងឡាយ ដែលកើតឡើងជាធម្មតាថា សង្ខារទាំងឡាយកើតឡើងជាធម្មតា មិនដឹងច្បាស់តាមពិត នូវសង្ខារទាំងឡាយដែលសូន្យទៅជាធម្មតាថា សង្ខារទាំងឡាយសូន្យទៅជាធម្មតា មិនដឹងច្បាស់តាមពិត នូវសង្ខារទាំងឡាយ ដែលកើតឡើងហើយសូន្យទៅជាធម្មតាថា សង្ខារទាំងឡាយកើតឡើងហើយសូន្យទៅជាធម្មតា មិនដឹងច្បាស់តាមពិត នូវវិញ្ញាណដែលកើតឡើងជាធម្មតាថា វិញ្ញាណកើតឡើងជាធម្មតា មិនដឹងច្បាស់តាមពិត នូវវិញ្ញាណដែលសូន្យទៅជាធម្មតាថា វិញ្ញាណសូន្យទៅជាធម្មតា មិនដឹងច្បាស់តាមពិត នូវវិញ្ញាណដែលកើតឡើង ហើយសូន្យទៅជាធម្មតាថា វិញ្ញាណកើតឡើងហើយសូន្យទៅជាធម្មតា ។ ម្នាលភិក្ខុ នេះហៅថា អវិជ្ជា ឯបុគ្គលអ្នកប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

[៤៨] ឯវំ វុត្តេ សោ ភិក្ខុ ភគវន្តំ ឯតទវោច វិជ្ជា វិជ្ជាតិ ភន្តេ វុច្ចតិ កតមា នុ ខោ ភន្តេ វិជ្ជា កិត្តាវតា ច វិជ្ជាគតោ ហោតីតិ ។ ឥធ ភិក្ខុ សុតវា អរិយសាវកោ សមុទយធម្មំ រូបំ សមុទយធម្មំ រូបន្តិ យថាភូតំ បជានាតិ វយធម្មំ រូបំ វយធម្មំ រូបន្តិ យថាភូតំ បជានាតិ សមុទយវយធម្មំ រូបំ សមុទយវយធម្មំ រូបន្តិ យថាភូតំ បជានាតិ សមុទយធម្មំ វេទនំ សមុទយធម្មា វេទនាតិ យថាភូតំ បជានាតិ វយធម្មំ វេទនំ វយធម្មា វេទនាតិ យថាភូតំ បជានាតិ សមុទយវយធម្មំ វេទនំ សមុទយវយធម្មា វេទនាតិ យថាភូតំ បជានាតិ សមុទយធម្មំ សញ្ញំ ។បេ។ បជានាតិ សមុទយធម្មេ សង្ខារេ សមុទយធម្មា សង្ខារាតិ យថាភូតំ បជានាតិ

( ៤៨ ) កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ភិក្ខុនោះ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា វិជ្ជា វិជ្ជា បពិត្រព្រះអង្គដ៏ចម្រើន វិជ្ជា តើដូចម្តេច បុគ្គលប្រកបដោយវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលភិក្ខុ អរិយសាវ័ក ក្នុងលោកនេះ ជាអ្នកចេះដឹង ដឹងច្បាស់តាមពិត នូវរូបដែលកើតឡើង ជាធម្មតាថា រូបកើតឡើងជាធម្មតា ដឹងច្បាស់តាមពិត នូវរូបដែល សូន្យទៅជាធម្មតាថា រូបសូន្យទៅជាធម្មតា ដឹងច្បាស់តាមពិត នូវរូប ដែលកើតឡើងហើយសូន្យទៅជាធម្មតាថា រូបកើតឡើងហើយសូន្យទៅ ជាធម្មតា ដឹងច្បាស់តាមពិតនូវវេទនាដែលកើតឡើងជាធម្មតាថា វេទនា កើតឡើងជាធម្មតា ដឹងច្បាស់តាមពិត នូវវេទនាដែលសូន្យទៅជាធម្មតា ថាវេទនាសូន្យទៅជាធម្មតា ដឹងច្បាស់តាមពិត នូវវេទនាដែលកើតឡើង ហើយសូន្យទៅជាធម្មតាថា វេទនាកើតឡើងហើយសូន្យទៅជាធម្មតា នូវ សញ្ញាដែលកើតឡើងជាធម្មតា ។ បេ ។ ដឹងច្បាស់តាមពិតនូវសង្ខារទាំង- ឡាយដែលកើតឡើងជាធម្មតាថា សង្ខារទាំងឡាយកើតឡើងជាធម្មតា

វយធម្មេ សង្ខារេ វយធម្មា សង្ខារាតិ យថាភូតំ បជា-នាតិ សមុទយវយធម្មេ សង្ខារេ សមុទយវយធម្មា សង្ខារាតិ យថាភូតំ បជានាតិ សមុទយធម្មំ វិញ្ញាណំ សមុទយធម្មំ វិញ្ញាណន្តិ យថាភូតំ បជានាតិ វយធម្មំ វិញ្ញាណំ វយធម្មំ វិញ្ញាណន្តិ យថាភូតំ បជានាតិ ស-មុទយវយធម្មំ វិញ្ញាណំ សមុទយវយធម្មំ វិញ្ញាណន្តិ យថាភូតំ បជានាតិ ។ អយំ វុច្ចតិ ភិក្ខុ វិជ្ជា ឯត្តាវ-តា ច វិជ្ជាគតោ ហោតីតិ ។

(៤៩) ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាកោដ្ឋិតោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថខោ អាយស្មា មហា-កោដ្ឋិតោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហា-កោដ្ឋិតោ អាយស្មន្តំ សារីបុត្តំ ឯតទវោច អវិជ្ជា អវិជ្ជាតិ អាវុសោ សារីបុត្ត វុច្ចតិ កតមា នុ ខោ អាវុសោ អវិជ្ជា កិត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។

ដឹងច្បាស់តាមពិត នូវសង្ខារទាំងឡាយដែលសូន្យទៅជាធម្មតាថា សង្ខារទាំងឡាយសូន្យទៅជាធម្មតា ដឹងច្បាស់តាមពិត នូវសង្ខារទាំងឡាយដែលកើតឡើងហើយសូន្យទៅជាធម្មតាថា សង្ខារទាំងឡាយកើតឡើងហើយសូន្យទៅជាធម្មតា ដឹងច្បាស់តាមពិត នូវវិញ្ញាណដែលកើតឡើងជាធម្មតាថា វិញ្ញាណកើតឡើងជាធម្មតា ដឹងច្បាស់តាមពិត នូវវិញ្ញាណដែលសូន្យទៅជាធម្មតាថា វិញ្ញាណសូន្យទៅជាធម្មតា ដឹងច្បាស់តាមពិត នូវវិញ្ញាណដែលកើតឡើងហើយសូន្យទៅជាធម្មតាថា វិញ្ញាណកើតឡើងហើយសូន្យទៅជាធម្មតា ។ ម្នាលភិក្ខុ នេះហៅថា វិជ្ជា បុគ្គលអ្នកប្រកបដោយវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

[ ៤៩ ] សម័យមួយ ព្រះសារីបុត្តមានអាយុនិងព្រះមហាកោដ្ឋិតៈមានអាយុ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ គ្រានោះឯង ព្រះមហាកោដ្ឋិតៈមានអាយុ ចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ។ បេ ។ លុះព្រះមហាកោដ្ឋិតៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះសារីបុត្តមានអាយុ ដូច្នេះថា ម្នាលអាវុសោសារីបុត្ត ដែលហៅថា អវិជ្ជា អវិជ្ជា ម្នាលអាវុសោ អវិជ្ជា តើដូចម្ដេច បុគ្គលអ្នកប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងណា ។

ឥធាវុសោ អស្សុតវា បុថុជ្ជនោ សមុទយធម្មំ រូបំ សមុទយធម្មំ រូបន្តិ យថាភូតំ នប្បជានាតិ វយធម្មំ រូបំ វយធម្មំ រូបន្តិ យថាភូតំ នប្បជានាតិ សមុទយវយធម្មំ សមុទយវយធម្មំ រូបន្តិ យថាភូតំ នប្បជានាតិ សមុទយធម្មំ វេទនំ ។បេ។ វយធម្មំ វេទនំ ។បេ។ សមុទយវយធម្មំ វេទនំ ។ បេ ។ សមុទយធម្មំ សញ្ញំ ។បេ។ សមុទយធម្មេ សង្ខារេ ។បេ។ វយធម្មេ សង្ខារេ ។ សមុទយវយធម្មេ សង្ខារេ សមុទយវយធម្មា សង្ខារាតិ យថាភូតំ នប្បជានាតិ សមុទយធម្មំ វិញ្ញាណំ ។បេ។ វយធម្មំ វិញ្ញាណំ ។ សមុទយវយធម្មំ វិញ្ញាណំ សមុទយវយធម្មំ វិញ្ញាណន្តិ យថាភូតំ នប្បជានាតិ ។ អយំ វុច្ចតាវុសោ អវិជ្ជា ឯត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។

ម្នាលអាវុសោ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនដឹងច្បាស់តាមពិត នូវរូបដែលកើតឡើងជាធម្មតាថា រូបកើតឡើងជាធម្មតា មិនដឹងច្បាស់តាមពិត នូវរូបដែលសូន្យទៅជាធម្មតាថា រូបសូន្យទៅជាធម្មតា មិនដឹងច្បាស់តាមពិត នូវរូបដែលកើតឡើងហើយសូន្យទៅជាធម្មតាថា រូបកើតឡើងហើយសូន្យទៅជាធម្មតា មិនដឹងច្បាស់តាមពិត នូវវេទនាដែលកើតឡើងជាធម្មតា ។ បេ ។ នូវវេទនាដែលសូន្យទៅជាធម្មតា ។ បេ ។ នូវវេទនាដែលកើតឡើងហើយសូន្យទៅជាធម្មតា ។ បេ ។ នូវសញ្ញាដែលកើតឡើងជាធម្មតា ។ បេ ។ នូវសង្ខារទាំងឡាយដែលកើតឡើងជាធម្មតា ។ បេ ។ នូវសង្ខារទាំងឡាយដែលសូន្យទៅជាធម្មតា ។ នូវសង្ខារទាំងឡាយ ដែលកើតឡើងហើយសូន្យទៅជាធម្មតាថា សង្ខារទាំងឡាយកើតឡើងហើយសូន្យទៅជាធម្មតា មិនដឹងច្បាស់តាមពិត នូវវិញ្ញាណដែលកើតឡើងជាធម្មតា ។ បេ ។ នូវវិញ្ញាណដែលសូន្យទៅជាធម្មតា ។ នូវវិញ្ញាណដែលកើតឡើងហើយសូន្យទៅជាធម្មតាថា វិញ្ញាណកើតឡើងហើយសូន្យទៅជាធម្មតា ។ ម្នាលអាវុសោ នេះហៅថា អវិជ្ជា បុគ្គលអ្នកប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

[៤០] ឯកំ សមយំ អាយស្មា ច សារិបុត្តោ អាយស្មា ច មហាកោដ្ឋិតោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិតោ អាយស្មន្តំ សារិបុត្តំ ឯត-ទវោច វិជ្ជា វិជ្ជាតិ អាវុសោ សារិបុត្ត វុច្ចតិ កតមា នុ ខោ អាវុសោ វិជ្ជា កិត្តាវតា ច វិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ សុតវា អរិយសាវកោ សមុទយធម្មំ រូបំ សមុទយធម្មំ រូបន្តិ យថាភូតំ បជានាតិ វយធម្មំ រូបំ ។ បេ ។ សមុទយវយធម្មំ រូបំ សមុទយវយធម្មំ រូបន្តិ យថាភូតំ បជានាតិ សមុទយធម្មំ វេទនំ ។ បេ ។ សមុទយធម្មំ សញ្ញំ ។ បេ ។ សមុទយធម្មេ សង្ខារេ ។ វយធម្មេ សង្ខារេ ។ សមុទយវយធម្មេ សង្ខារេ សមុទយវយធម្មា សង្ខារាតិ យថាភូតំ បជានាតិ

( ៩០ ) សម័យមួយ ព្រះសារីបុត្តមានអាយុនិងព្រះមហាកោដ្ឋិតៈមានអាយុ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ លុះព្រះមហាកោដ្ឋិតៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ពាក្យដែលហៅថា វិជ្ជា វិជ្ជា ម្នាលអាវុសោ វិជ្ជា តើដូចម្តេច បុគ្គលអ្នកប្រកបដោយវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង រមែងដឹងច្បាស់តាមពិត នូវរូបដែលកើតឡើងជាធម្មតាថា រូបកើតឡើងជាធម្មតា ដឹងច្បាស់តាមពិត នូវរូបដែលសូន្យទៅជាធម្មតា ។ បេ ។ នូវរូបដែលកើតឡើងហើយសូន្យទៅជាធម្មតាថា រូបកើតឡើងហើយសូន្យទៅជាធម្មតា ដឹងច្បាស់តាមពិត នូវវេទនាដែលកើតឡើងជាធម្មតា ។ បេ ។ នូវសញ្ញាដែលកើតឡើងជាធម្មតា ។ បេ ។ នូវសង្ខារទាំងឡាយដែលកើតឡើងជាធម្មតា ។ នូវសង្ខារទាំងឡាយដែលសូន្យទៅជាធម្មតា ។ នូវសង្ខារទាំងឡាយដែលកើតឡើងហើយសូន្យទៅជាធម្មតាថា សង្ខារទាំងឡាយកើតឡើងហើយសូន្យទៅជាធម្មតា

សមុទយធម្មំ វិញ្ញាណំ ។ វយធម្មំ វិញ្ញាណំ ។ សមុទយវយធម្មំ វិញ្ញាណំ សមុទយវយធម្មំ វិញ្ញាណន្តិ យថាភូតំ បជានាតិ ។ អយំ វុច្ចតាវុសោ វិជ្ជា ឯត្តាវតា ច វិជ្ជាគតោ ហោតីតិ ។

(៩១) តញ្ញេវ និទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិតោ អាយស្មន្តំ សារីបុត្តំ ឯតទវោច អវិជ្ជា អវិជ្ជាតិ អាវុសោ សារីបុត្ត វុច្ចតិ កតមា នុ ខោ អាវុសោ អវិជ្ជា កិត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ អស្សុតវា បុថុជ្ជនោ រូបស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ វេទនាយ ។បេ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ ។ អយំ វុច្ចតាវុសោ អវិជ្ជា ឯត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។

ដឹងច្បាស់តាមពិត នូវវិញ្ញាណដែលកើតឡើងជាធម្មតា ១ នូវវិញ្ញាណដែលសូន្យទៅជាធម្មតា ១ នូវវិញ្ញាណដែលកើតឡើងហើយសូន្យទៅជាធម្មតាថា វិញ្ញាណកើតឡើងហើយសូន្យទៅជាធម្មតា ១ ម្នាលអាវុសោ នេះហៅថា វិជ្ជា បុគ្គលអ្នកប្រកបដោយវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

[៤១] និទាននោះដដែល ។ លុះព្រះមហាកោដ្ឋិតៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះសារីបុត្តមានអាយុ ដូច្នេះថា ម្នាលអាវុសោសារីបុត្ត ពាក្យដែលហៅថា អវិជ្ជា អវិជ្ជា ម្នាលអាវុសោ អវិជ្ជា តើដូចម្តេច បុគ្គលអ្នកប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង រមែងមិនដឹងច្បាស់តាមពិត នូវអានិសង្សនិងទោសរបស់រូបផង នូវការរលាស់ចេញនូវរូបផង វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ មិនដឹងច្បាស់តាមពិត នូវអានិសង្សនិងទោសរបស់វិញ្ញាណផង នូវការរលាស់ចេញនូវវិញ្ញាណផង ។ ម្នាលអាវុសោ នេះហៅថា អវិជ្ជា បុគ្គលអ្នកប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

(៤២) តញ្ញេវ និទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិតោ អាយស្មន្តំ សារីបុត្តំ ឯតទវោច វិជ្ជា វិជ្ជាតិ អាវុសោ សារីបុត្ត វុច្ចតិ កតមា នុ ខោ អាវុសោ វិជ្ជា កិត្តាវតា ច វិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ សុតវា អរិយសាវកោ រូបស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ វេទនាយ ។ បេ ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ វុច្ចតាវុសោ វិជ្ជា ឯត្តាវតា ច វិជ្ជាគតោ ហោតីតិ ។

(៤៣) តញ្ញេវ និទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិតោ អាយស្មន្តំ សារីបុត្តំ ឯតទវោច អវិជ្ជា អវិជ្ជាតិ អាវុសោ សារីបុត្ត វុច្ចតិ កតមា នុ ខោ អាវុសោ អវិជ្ជា កិត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ អស្សុតវា បុថុជ្ជនោ

(៩២) និទាននោះដដែល ។ លុះព្រះមហាកោដ្ឋិតៈមានអាយុ អង្គុយក្នុងទីសមគួរហើយ បានពោលនឹងព្រះសារីបុត្តមានអាយុ ដូច្នេះថា ម្នាលអាវុសោសារីបុត្ត ពាក្យដែលហៅថា វិជ្ជា វិជ្ជា ម្នាលអាវុសោ វិជ្ជា តើដូចម្តេច បុគ្គលអ្នកប្រកបដោយវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ អរិយសាវកក្នុងលោកនេះ ជាអ្នកចេះដឹង រមែងដឹងច្បាស់តាមពិត នូវអានិសង្សនិងទោសរបស់រូបផង នូវការរលាស់ចេញនូវរូបផង នូវវេទនា ។ បេ ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ ដឹងច្បាស់តាមពិត នូវអានិសង្សនិងទោសរបស់វិញ្ញាណផង នូវការរលាស់ចេញនូវវិញ្ញាណផង ។ ម្នាលអាវុសោ នេះហៅថា វិជ្ជា បុគ្គលអ្នកប្រកបដោយវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

(៩៣) និទាននោះដដែល ។ លុះព្រះមហាកោដ្ឋិតៈមានអាយុ អង្គុយក្នុងទីសមគួរហើយ បានពោលនឹងព្រះសារីបុត្ត មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ពាក្យដែលហៅថា អវិជ្ជា អវិជ្ជា ម្នាលអាវុសោ អវិជ្ជា តើដូចម្តេច បុគ្គលអ្នកប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង

រូបស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ វេទនាយ ។បេ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ ។ អយំ វុច្ចតាវុសោ អវិជ្ជា ឯត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។

(៥៨) តញ្ញេវ និទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិតោ អាយស្មន្តំ សារីបុត្តំ ឯតទវោច វិជ្ជា វិជ្ជាតិ អាវុសោ សារីបុត្ត វុច្ចតិ កតមា នុ ខោ អាវុសោ វិជ្ជា កិត្តាវតា ច វិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ សុតវា អរិយសាវកោ រូបស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ វេទនាយ ។បេ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ វុច្ចតាវុសោ វិជ្ជា ឯត្តាវតា ច វិជ្ជាគតោ ហោតីតិ ។

រមែងមិនដឹងច្បាស់តាមពិត នូវការកើតឡើងនិងការរលត់ នូវអានិសង្សនិងទោសរបស់រូបផង នូវការរលាស់ចេញនូវរូបផង នូវវេទនា ។ បេ ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ មិនដឹងច្បាស់ នូវការកើតឡើងនិងការរលត់ នូវអានិសង្សនិងទោសរបស់វិញ្ញាណផង នូវការរលាស់ចេញនូវវិញ្ញាណផង ។ ម្នាលអាវុសោ នេះហៅថា អវិជ្ជា បុគ្គលអ្នកប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

[៩៤] និទាននោះដដែល ។ លុះព្រះមហាកោដ្ឋិតៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះសារីបុត្តមានអាយុ ដូច្នេះថា ម្នាលអាវុសោសារីបុត្ត ពាក្យដែលហៅថា វិជ្ជា វិជ្ជា ម្នាលអាវុសោ វិជ្ជា តើដូចម្តេច បុគ្គលអ្នកប្រកបដោយវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង រមែងដឹងច្បាស់តាមពិត នូវការកើតឡើងនិងការរលត់ នូវអានិសង្សនិងទោសរបស់រូបផង នូវការរលាស់ចេញនូវរូបផង នូវវេទនា ។ បេ ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ ដឹងច្បាស់តាមពិត នូវការកើតឡើងនិងការរលត់ នូវអានិសង្សនិងទោសរបស់វិញ្ញាណផង នូវការរលាស់ចេញនូវវិញ្ញាណផង ។ ម្នាលអាវុសោ នេះហៅថា វិជ្ជា បុគ្គលអ្នកប្រកបដោយវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

(៨៨) ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាកោដ្ឋិតោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថខោ អាយស្មា សារីបុត្តោ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាកោដ្ឋិតំ ឯតទវោច អវិជ្ជា អវិជ្ជាតិ អាវុសោ កោដ្ឋិត វុច្ចតិ កតមា នុ ខោ អាវុសោ អវិជ្ជា កិត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ អស្សុតវា បុថុជ្ជនោ រូបស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ វេទនាយ ។ បេ ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ ។ អយំ វុច្ចតាវុសោ អវិជ្ជា ឯត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។

(៤៤) សម័យមួយ ព្រះសារីបុត្តមានអាយុនិងព្រះមហាកោដ្ឋិតៈ មានអាយុ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ គ្រានោះឯង ព្រះសារីបុត្តមានអាយុ ។ បេ ។ លុះព្រះសារីបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះមហាកោដ្ឋិតៈមានអាយុដូច្នេះថា ម្នាលអាវុសោកោដ្ឋិត. ពាក្យដែលហៅថា អវិជ្ជា អវិជ្ជា ម្នាលអាវុសោ អវិជ្ជាតើដូចម្តេច បុគ្គលប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង រមែងមិនដឹងច្បាស់តាមពិត នូវអានិសង្សនិងទោសរបស់រូបផង នូវការរលាស់ចេញនូវរូបផង នូវវេទនា ។ បេ ។ នូវសញ្ញា ។ នូវសង្ខារទាំង-ឡាយ ។ មិនដឹងច្បាស់តាមពិត នូវអានិសង្សនិងទោសរបស់វិញ្ញាណផង នូវការរលាស់ចេញនូវវិញ្ញាណផង ។ ម្នាលអាវុសោ នេះហៅថា អវិជ្ជា បុគ្គលប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

(៨៦) ឯវំ វុត្តេ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាកោដ្ឋិតំ ឯតទវោច វិជ្ជា វិជ្ជាតិ អាវុសោ កោដ្ឋិត វុច្ចតិ កតមា នុ ខោ អាវុសោ វិជ្ជា កិត្តាវតា ច វិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ សុតវា អរិយសាវកោ រូបស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ វេទនាយ ។ បេ ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ វុច្ចតាវុសោ វិជ្ជា ឯត្តាវតា ច វិជ្ជាគតោ ហោតីតិ ។

(៨៧) តញ្ញេវ និទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាកោដ្ឋិតំ ឯតទវោច អវិជ្ជា អវិជ្ជាតិ អាវុសោ កោដ្ឋិត វុច្ចតិ

( ៩៦ ) កាលព្រះមហាកោដ្ឋិតៈមានអាយុ ពោលយ៉ាងនេះហើយ ព្រះសារីបុត្តមានអាយុ ក៏បានពោលនឹងព្រះមហាកោដ្ឋិតៈមានអាយុដូច្នេះថា ម្នាលអាវុសោកោដ្ឋិតៈ ពាក្យដែលហៅថា វិជ្ជា វិជ្ជា ម្នាលអាវុសោ វិជ្ជា តើដូចម្តេច បុគ្គលប្រកបដោយវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង រមែងដឹងច្បាស់តាមពិត នូវអានិសង្សនិងទោសរបស់រូបផង នូវការរលាស់ចេញនូវរូបផង នូវវេទនា ។ បេ ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ ដឹងច្បាស់តាមពិត នូវអានិសង្សនិងទោសរបស់វិញ្ញាណផង នូវការរលាស់ចេញនូវវិញ្ញាណផង ។ ម្នាលអាវុសោ នេះហៅថា វិជ្ជា បុគ្គលប្រកបដោយវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

( ៩៧ ) និទាននោះដដែល ។ លុះព្រះសារីបុត្តមានអាយុអង្គុយ ក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះមហាកោដ្ឋិតៈមានអាយុដូច្នេះថា ម្នាលអាវុសោកោដ្ឋិតៈ ពាក្យដែលហៅថា អវិជ្ជា អវិជ្ជា

កតមា នុ ខោ អាវុសោ អវិជ្ជា កិត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ អស្សុតវា បុថុជ្ជនោ រូបស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ វេទនាយ ។បេ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ ។ អយំ វុច្ចតាវុសោ អវិជ្ជា ឯត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។

(៥៨) ឯវំ វុត្តេ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាកោដ្ឋិតំ ឯតទវោច វិជ្ជា វិជ្ជាតិ អាវុសោ កោដ្ឋិត វុច្ចតិ កតមា នុ ខោ អាវុសោ វិជ្ជា កិត្តាវតា ច វិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ សុតវា អរិយសាវកោ រូបស្ស សមុទយញ្ច អត្ថង្គមញ្ច

ម្នាលអាវុសោ អវិជ្ជា តើដូចម្តេច បុគ្គលប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង រមែងមិនដឹងច្បាស់តាមពិត នូវការកើតឡើងនិងការរលត់ នូវអានិសង្សនិងទោសរបស់រូបផង នូវការរលាស់ចេញនូវរូបផង នូវវេទនា ។ បេ ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ មិនដឹងច្បាស់តាមពិត នូវការកើតឡើងនិងការរលត់ នូវអានិសង្សនិងទោសរបស់វិញ្ញាណផង នូវការរលាស់ចេញនូវវិញ្ញាណផង ។ ម្នាលអាវុសោ នេះហៅថា អវិជ្ជា បុគ្គលប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

[៥៨] កាលដែលព្រះមហាកោដ្ឋិតៈមានអាយុ ពោលយ៉ាងនេះហើយ ព្រះសារីបុត្តមានអាយុ ក៏បានពោលនឹងព្រះមហាកោដ្ឋិតៈមានអាយុដូច្នេះថា ម្នាលអាវុសោកោដ្ឋិតៈ ពាក្យដែលហៅថា វិជ្ជា វិជ្ជា ម្នាលអាវុសោ វិជ្ជា តើដូចម្តេច បុគ្គលប្រកបដោយវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង រមែងដឹងច្បាស់តាមពិត នូវការកើតឡើងនិងការរលត់

អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ វេទនាយ ។ បេ ។ សញ្ញាយ ។ សង្ខារានំ ។ វិញ្ញាណស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ វុច្ចតាវុសោ វិជ្ជា ឯត្តាវតា ច វិជ្ជាគតោ ហោតីតិ ។

(៨៩) តញ្ញេវ និទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាកោដ្ឋិតំ ឯតទវោច អវិជ្ជា អវិជ្ជាតិ អាវុសោ កោដ្ឋិត វុច្ចតិ កតមា នុ ខោ អាវុសោ អវិជ្ជា កិត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ អស្សុតវា បុថុជ្ជនោ រូបំ នប្បជានាតិ រូបសមុទយំ នប្បជានាតិ រូបនិរោធំ នប្បជានាតិ រូបនិរោធគាមិនីបដិបទំ នប្បជានាតិ វេទនំ ។ បេ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ នប្បជានាតិ វិញ្ញាណសមុទយំ នប្បជានាតិ វិញ្ញាណនិរោធំ នប្បជានាតិ វិញ្ញាណនិរោធគាមិនីបដិបទំ នប្បជានាតិ ។ អយំ វុច្ចតាវុសោ អវិជ្ជា ឯត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។

នូវអានិសង្សនិងទោសរបស់រូបផង នូវការរលាស់ចេញនូវរូបផង នូវវេទនា ។ បេ ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ ដឹងច្បាស់តាមពិត នូវការកើតឡើងនិងការរលត់ នូវអានិសង្សនិងទោសរបស់វិញ្ញាណផង នូវការរលាស់ចេញនូវវិញ្ញាណផង ។ ម្នាលអាវុសោ នេះ ហៅថា វិជ្ជា បុគ្គលប្រកបដោយវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

[ ៨៩ ] និទាននោះដដែល ។ លុះព្រះសារីបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះមហាកោដ្ឋិតៈមានអាយុ ដូច្នេះថា ម្នាលអាវុសោកោដ្ឋិតៈ ពាក្យដែលហៅថា អវិជ្ជា អវិជ្ជា ម្នាលអាវុសោ អវិជ្ជា តើដូចម្តេច បុគ្គលប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង រមែងមិនដឹងច្បាស់នូវរូប មិនដឹងច្បាស់នូវហេតុនាំឲ្យកើតរូប មិនដឹងច្បាស់នូវការរលត់រូប មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់រូប មិនដឹងច្បាស់នូវវេទនា ។ បេ ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ មិនដឹងច្បាស់នូវវិញ្ញាណ មិនដឹងច្បាស់នូវហេតុនាំឲ្យកើតវិញ្ញាណ មិនដឹងច្បាស់នូវការរលត់វិញ្ញាណ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់វិញ្ញាណ ។ ម្នាលអាវុសោ នេះហៅថា អវិជ្ជា បុគ្គលប្រកបដោយអវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

[៦០] ឯវំ វុត្តេ អាយស្មា សារិបុត្តោ អាយស្មន្តំ មហាកោដ្ឋិតំ ឯតទវោច វិជ្ជា វិជ្ជាតិ អាវុសោ កោដ្ឋិត វុច្ចតិ កតមា នុ ខោ អាវុសោ វិជ្ជា កិត្តាវតា ច វិជ្ជាគតោ ហោតីតិ ។ ឥធាវុសោ សុតវា អរិយសាវកោ រូបំ បជានាតិ រូបសមុទយំ បជានាតិ រូបនិរោធំ បជានាតិ រូបនិរោធគាមិនិំ បដិបទំ បជានាតិ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បជានាតិ វិញ្ញាណសមុទយំ បជានាតិ វិញ្ញាណនិរោធំ បជានាតិ វិញ្ញាណនិរោធគាមិនិំ បដិបទំ បជានាតិ ។ អយំ វុច្ចតាវុសោ វិជ្ជា ឯត្តាវតា ច វិជ្ជាគតោ ហោតីតិ ។

អវិជ្ជាវគ្គោ តតិយោ ។

( ៦០ ) កាលព្រះមហាកោដ្ឋិតៈមានអាយុ ពោលយ៉ាងនេះហើយ ទើបព្រះសារីបុត្តមានអាយុ បានពោលនឹងព្រះមហាកោដ្ឋិតៈមានអាយុដូច្នេះថា ម្នាលអាវុសោកោដ្ឋិតៈ ពាក្យដែលហៅថា វិជ្ជា វិជ្ជា ម្នាលអាវុសោ វិជ្ជា តើដូចម្តេច បុគ្គលប្រកបដោយវិជ្ជា ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង រមែងដឹងច្បាស់នូវរូប ដឹងច្បាស់នូវហេតុនាំឲ្យកើតរូប ដឹងច្បាស់នូវការរលត់រូប ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់រូប ដឹងច្បាស់នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ ដឹងច្បាស់នូវវិញ្ញាណ ដឹងច្បាស់នូវហេតុនាំឲ្យកើតវិញ្ញាណ ដឹងច្បាស់នូវការរលត់វិញ្ញាណ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ការរលត់វិញ្ញាណ ។ ម្នាលអាវុសោ នេះហៅថា វិជ្ជា បុគ្គលប្រកបដោយវិជ្ជា ដោយហេតុយ៉ាងនេះឯង ។

ចប់ អវិជ្ជាវគ្គ ទី៣ ។

## តត្រុទ្ទានំ

សមុទយធម្មេន តីណិ

អស្សាទេ ច អបរេ ទុវេ

សមុទយេ ច ទ្វេ វុត្តា

កោដ្ឋិតេ អបរេ តយោតិ ។

---

## ឧទ្ទានក្នុងអវិជ្ជាវគ្គនោះ គឺ

ពោលអំពីការកើតឡើងជាធម្មតា ៣ លើក អំពីអានិសង្ស ដទៃទៀត ២ លើក អំពីការកើតឡើង ២ លើក អំពីព្រះកោដ្ឋិតៈដទៃទៀត ៣ លើក ។

# កុក្កុឡវគ្គោ

(៦៧) សាវត្ថី ។ រូបំ ភិក្ខវេ កុក្កុឡំ វេទនា កុក្កុឡា សញ្ញា កុក្កុឡា សង្ខារា កុក្កុឡា វិញ្ញាណំ កុក្កុឡំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

# កុក្កុឡវគ្គ

(៦១) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ រូបក្តៅ វេទនាក៏ក្តៅ សញ្ញាក៏ក្តៅ សង្ខារទាំងឡាយក៏ក្តៅ វិញ្ញាណក៏ក្តៅ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័ក អ្នកចេះដឹង បានឃើញច្បាស់យ៉ាងនេះ ក៏នឿយណាយនឹងរូបផង នឿយណាយនឹងវេទនាផង នឿយណាយនឹងសញ្ញាផង នឿយណាយនឹងសង្ខារទាំងឡាយផង នឿយណាយនឹងវិញ្ញាណផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ទើបរួចស្រឡះ ។ កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ អរិយសាវ័កនោះ ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៦២) សាវត្ថី ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទោ បហាតព្វោ ។ កិញ្ច ភិក្ខវេ អនិច្ចំ រូបំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទោ បហាតព្វោ ។ វេទនា អនិច្ចា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនិច្ចំ តត្រ វោ ឆន្ទោ បហាតព្វោ ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទោ បហាតព្វោតិ ។

(៦៣) សាវត្ថី ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ រាគោ បហាតព្វោ ។ កិញ្ច ភិក្ខវេ អនិច្ចំ រូបំ ភិក្ខវេ អនិច្ចំ តត្រ វោ រាគោ បហាតព្វោ ។ វេទនា អនិច្ចា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនិច្ចំ តត្រ វោ រាគោ បហាតព្វោ ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ រាគោ បហាតព្វោតិ ។

[ ៦២ ] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង អ្នកទាំងឡាយត្រូវលះបង់ឆន្ទៈគឺសេចក្តីពេញចិត្ត ក្នុងរបស់នោះចេញ ។ ម្នាលភិក្ខុទាំងឡាយ ចុះរបស់អ្វីដែលមិនទៀង ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង អ្នកទាំងឡាយត្រូវលះបង់ឆន្ទៈក្នុងរូបនោះចេញ ។ វេទនាមិនទៀង ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀង អ្នកទាំងឡាយត្រូវលះបង់ឆន្ទៈ ក្នុងវិញ្ញាណនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង អ្នកទាំងឡាយត្រូវលះបង់ឆន្ទៈ ក្នុងរបស់នោះចេញ ។

[ ៦៣ ] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង អ្នកទាំងឡាយត្រូវលះបង់រាគៈគឺតម្រេក ក្នុងរបស់នោះចេញ ។ ម្នាលភិក្ខុទាំងឡាយ ចុះរបស់អ្វីដែលមិនទៀង ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង អ្នកទាំងឡាយត្រូវលះបង់រាគៈ ក្នុងរូបនោះចេញ ។ វេទនាមិនទៀង ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀង អ្នកទាំងឡាយត្រូវលះបង់រាគៈ ក្នុងវិញ្ញាណនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង អ្នកទាំងឡាយត្រូវលះបង់រាគៈ ក្នុងរបស់នោះចេញ ។

(៦៤) សាវត្ថី ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទោ បហាតព្វោ ។ កិញ្ច ភិក្ខវេ អនិច្ចំ រូបំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទោ បហាតព្វោ ។ វេទនា អនិច្ចា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនិច្ចំ តត្រ វោ ឆន្ទោ បហាតព្វោ ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទោ បហាតព្វោតិ ។

(៦៥) សាវត្ថី ។ យំ ភិក្ខវេ ទុក្ខំ តត្រ វោ ឆន្ទោ បហាតព្វោ ។ បេ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោតិ ។

(៦៦) សាវត្ថី ។ តត្រ ខោ ។ យោ ភិក្ខវេ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។ កោ ច ភិក្ខវេ អនត្តា

( ៦៤ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង អ្នកទាំងឡាយ ត្រូវលះបង់ឆន្ទរាគគឺសេចក្តីត្រេកត្រអាល ក្នុងរបស់នោះចេញ ។ ម្នាលភិក្ខុទាំងឡាយ ចុះរបស់អ្វី ដែលមិនទៀង ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង អ្នកទាំងឡាយត្រូវលះបង់ឆន្ទរាគ ក្នុងរូបនោះចេញ ។ វេទនាមិនទៀង ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀង អ្នកទាំងឡាយត្រូវលះបង់ឆន្ទរាគ ក្នុងវិញ្ញាណនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង អ្នកទាំងឡាយ ត្រូវលះបង់ឆន្ទរាគ ក្នុងរបស់នោះចេញ ។

( ៦៥ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ របស់ណាជាទុក្ខ អ្នកទាំងឡាយត្រូវលះបង់ឆន្ទៈ ក្នុងរបស់នោះចេញ ។ បេ ។ ត្រូវលះបង់រាគៈចេញ ។ ត្រូវលះបង់ឆន្ទរាគចេញ ។

( ៦៦ ) ក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាមិនមែនខ្លួន អ្នកទាំងឡាយត្រូវលះបង់ឆន្ទៈក្នុងសភាវៈនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ ចុះសភាវៈដូចម្តេច ដែលមិនមែនខ្លួន

រូបំ ភិក្ខវេ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។ វេទនា អនត្តា ។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។ យោ ភិក្ខវេ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោតិ ។

(៦៧) សាវត្ថី ។ យោ ភិក្ខវេ អនត្តា តត្រ វោ រាគោ បហាតព្វោ ។ កោ ច ភិក្ខវេ អនត្តា រូបំ ភិក្ខវេ អនត្តា តត្រ វោ រាគោ បហាតព្វោ ។ វេទនា អនត្តា ។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនត្តា តត្រ វោ រាគោ បហាតព្វោ ។ យោ ភិក្ខវេ អនត្តា តត្រ វោ រាគោ បហាតព្វោតិ ។

ម្នាលភិក្ខុទាំងឡាយ រូបមិនមែនខ្លួន អ្នកទាំងឡាយ ត្រូវលះបង់ឆន្ទៈ ក្នុងរូបនោះចេញ ។ វេទនាមិនមែនខ្លួន ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនមែនខ្លួន អ្នកទាំងឡាយត្រូវលះបង់ឆន្ទៈ ក្នុងវិញ្ញាណនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាមិនមែនខ្លួន អ្នកទាំងឡាយត្រូវលះបង់ឆន្ទៈ ក្នុងសភាវៈនោះចេញ ។

( ៦៧ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាមិនមែនខ្លួន អ្នកទាំងឡាយត្រូវលះបង់រាគៈ ក្នុងសភាវៈនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ ចុះសភាវៈដូចម្ដេចដែលមិនមែនខ្លួន ម្នាលភិក្ខុទាំងឡាយ រូបមិនមែនខ្លួន អ្នកទាំងឡាយត្រូវលះបង់រាគៈ ក្នុងរូបនោះចេញ ។ វេទនាមិនមែនខ្លួន ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនមែនខ្លួន អ្នកទាំងឡាយត្រូវលះបង់រាគៈ ក្នុងវិញ្ញាណនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាមិនមែនខ្លួន អ្នកទាំងឡាយត្រូវលះបង់រាគៈ ក្នុងសភាវៈនោះចេញ ។

(២៨) សាវត្ថី ។ យោ ភិក្ខវេ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។ កោ ច ភិក្ខវេ អនត្តា រូបំ ភិក្ខវេ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។ វេទនា អនត្តា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។ យោ ភិក្ខវេ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។

(២៩) សាវត្ថី ។ តត្រ ខោ ។ សទ្ធាបព្វជិតស្ស ភិក្ខវេ កុលបុត្តស្ស អយមនុធម្មោ ហោតិ យំ រូបេ និព្វិទាពហុលំ(១) វិហរេយ្យ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ និព្វិទាពហុលំ វិហរេយ្យ ។ យោ រូបេ និព្វិទាពហុលំ វិហរន្តោ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។

---

១ និព្វិទាពហុលោតិ ទិស្សតិ ។ អដ្ឋកថា ។

[៦៨] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាមិនមែនខ្លួន អ្នកទាំងឡាយត្រូវលះបង់ឆន្ទរាគ ក្នុងសភាវៈនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ ចុះសភាវៈដូចម្តេចដែលមិនមែនខ្លួន ម្នាលភិក្ខុទាំងឡាយ រូបមិនមែនខ្លួន អ្នកទាំងឡាយត្រូវលះបង់ឆន្ទរាគ ក្នុងរូបនោះចេញ ។ វេទនាមិនមែនខ្លួន ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនមែនខ្លួន អ្នកទាំងឡាយត្រូវលះបង់ឆន្ទរាគ ក្នុងវិញ្ញាណនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាមិនមែនខ្លួន អ្នកទាំងឡាយ ត្រូវលះបង់ឆន្ទរាគ ក្នុងសភាវៈនោះចេញ ។

[៦៩] ក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តដែលបួសដោយសទ្ធា តែងមានអនុធម៌(១)នេះ គឺតែងនៅច្រើនដោយសេចក្តីនឿយណាយ នឹងរូប ។ នឹងវេទនា ។ នឹងសញ្ញា ។ នឹងសង្ខារទាំងឡាយ ។ តែងនៅច្រើនដោយសេចក្តីនឿយណាយ នឹងវិញ្ញាណ ។ កុលបុត្តណា កាលនៅច្រើនដោយសេចក្តីនឿយណាយ នឹងរូប ។ នឹងវេទនា ។ នឹងសញ្ញា ។ នឹងសង្ខារទាំងឡាយ ។

---

១ អនុធម៌ ប្រែថា ធម៌ស្របតាម, ធម៌សមតាម គឺស្រប, សមតាមភេទ តាមនាទី តាមមុខការរបស់ខ្លួន ដូចអ្នកបួសដោយសទ្ធា តែងនឿយណាយនឹងរូប វេទនាជាដើម ។ អនុធម៌ ជាគូនឹងធម៌ (ធម្មានុធម៌ = ធម៌និងអនុធម៌), ឯធម៌ មនុស្សគ្រប់ប្រភេទអាចប្រតិបត្តិបាន ដូចការមិនសម្លាប់សត្វជាដើម ។

វិញ្ញាណេ និព្វិទាពហុលំ វិហរន្តោ រូបំ បរិជានាតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បរិជានាតិ សោ រូបំ បរិជានំ វេទនំ ។បេ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បរិជានំ បរិមុច្ចតិ រូបម្ហា បរិមុច្ចតិ វេទនាយ បរិមុច្ចតិ សញ្ញាយ បរិមុច្ចតិ សង្ខារេហិ បរិមុច្ចតិ វិញ្ញាណម្ហា បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមីតិ ។

(៧០) សាវត្ថី ។ សទ្ធាបព្វជិតស្ស ភិក្ខវេ កុលបុត្តស្ស អយមនុធម្មោ ហោតិ យំ រូបេ អនិច្ចានុបស្សី វិហរេយ្យ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ អនិច្ចានុបស្សី វិហរេយ្យ ។បេ។ បរិមុច្ចតិ ទុក្ខស្មាតិ វទាមីតិ ។

(៧១) សាវត្ថី ។ សទ្ធាបព្វជិតស្ស ភិក្ខវេ កុលបុត្តស្ស អយមនុធម្មោ ហោតិ យំ រូបេ ទុក្ខានុបស្សី វិហរេយ្យ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ ទុក្ខានុបស្សី វិហរេយ្យ ។បេ។ បរិមុច្ចតិ ទុក្ខស្មាតិ វទាមីតិ ។

កាលនៅច្រើនដោយសេចក្តីនឿយណាយ នឹងវិញ្ញាណ តែងកំណត់ដឹងនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ តែងកំណត់ដឹងនូវវិញ្ញាណ កាលកុលបុត្តនោះ កំណត់ដឹង នូវរូប នូវវេទនា ។ បេ ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ កាលបើកំណត់ដឹង នូវវិញ្ញាណ តថាគតពោលថា កុលបុត្តនោះ រួចស្រឡះចាករូប រួចស្រឡះចាកវេទនា រួចស្រឡះចាកសញ្ញា រួចស្រឡះចាកសង្ខារទាំង-ឡាយ រួចស្រឡះចាកវិញ្ញាណ រួចស្រឡះចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត រួចស្រឡះចាកទុក្ខ ។

(៧០) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តដែលបួសដោយសទ្ធា តែងមានអនុធម៌នេះ គឺតែងឃើញនូវសេចក្តីមិនទៀង ក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ តែងពិចារណាឃើញនូវសេចក្តីមិនទៀង ក្នុងវិញ្ញាណ ។ បេ ។ តថាគតពោលថា កុលបុត្តនោះ រួចស្រឡះចាកទុក្ខ ។

(៧១) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តដែលបួសដោយសទ្ធា តែងមានអនុធម៌នេះ គឺតែងពិចារណាឃើញនូវសេចក្តីទុក្ខក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ តែងពិចារណាឃើញនូវសេចក្តីទុក្ខ ក្នុងវិញ្ញាណ ។ បេ ។ តថាគតពោលថា កុលបុត្តនោះ រួចស្រឡះចាកទុក្ខ ។

(៧២) សាវត្ថី ។ សទ្ធាបព្វជិតស្ស ភិក្ខវេ កុលបុត្តស្ស អយមនុធម្មោ ហោតិ យំ រូបេ អនត្តានុបស្សី វិហរេយ្យ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ អនត្តានុបស្សី វិហរេយ្យ ។ យោ រូបេ អនត្តានុបស្សី វិហរន្តោ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ អនត្តានុបស្សី វិហរន្តោ រូបំ បរិជានាតិ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បរិជានាតិ សោ រូបំ បរិជានំ ។ វេទនំ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ បរិជានំ បរិមុច្ចតិ រូបម្ហា បរិមុច្ចតិ វេទនាយ បរិមុច្ចតិ សញ្ញាយ បរិមុច្ចតិ សង្ខារេហិ បរិមុច្ចតិ វិញ្ញាណម្ហា បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមីតិ ។

កុក្កុឡវគ្គោ ចតុត្ថោ ។

(៧២) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តដែលបួសដោយសទ្ធា តែងមានអនុធម៌នេះ គឺតែងពិចារណាឃើញថាមិនមែនខ្លួន ក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ តែងពិចារណាឃើញថាមិនមែនខ្លួន ក្នុងវិញ្ញាណ ។ កុលបុត្តណា កាលពិចារណាឃើញថាមិនមែនខ្លួន ក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ កាលពិចារណាឃើញថាមិនមែនខ្លួន ក្នុងវិញ្ញាណ តែងកំណត់ដឹងនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ តែងកំណត់ដឹងនូវវិញ្ញាណ កាលកុលបុត្តនោះកំណត់ដឹងនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ កាលកំណត់ដឹងនូវវិញ្ញាណ តថាគតពោលថា កុលបុត្តនោះ រួចស្រឡះចាករូប រួចស្រឡះចាកវេទនា រួចស្រឡះចាកសញ្ញា រួចស្រឡះចាកសង្ខារទាំងឡាយ រួចស្រឡះចាកវិញ្ញាណ រួចស្រឡះចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត រួចស្រឡះចាកទុក្ខ ។

ចប់ កុក្កុឡវគ្គ ទី ៤ ។

## តស្សុទ្ទានំ

កុក្កុឡា តយោ អនិច្ចេន

ទុក្ខេន អបរេ តយោ

អនត្តេន តយោ វុត្តា

កុលបុត្តេន ទ្វេ ទុក្ខាតិ ។

# ឧទ្ទាននៃកុក្កុឡវគ្គនោះគឺ

ពោលអំពីបញ្ចក្ខន្ធក្តៅ ១ អំពីបញ្ចក្ខន្ធមិនទៀង ៣ លើក បញ្ចក្ខន្ធប្រកបដោយទុក្ខដទៃទៀត ៣ លើក បញ្ចក្ខន្ធប្រកបដោយអនត្តា ៣ លើក កុលបុត្តបេឋាកទុក្ខ ៦ លើក ។

---

# ទិដ្ឋិវគ្គោ

(៧៣) សាវត្ថី ។ កិស្មិំ នុ ខោ ភិក្ខវេ សតិ កិំ ឧបាទាយ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខន្តិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ វេទនាយ សតិ ។បេ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។

(៧៤) តំ កិំ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឧប្បជ្ជេយ្យ អជ្ឈត្តំ សុខទុក្ខន្តិ ។ នោ ហេតំ ភន្តេ ។ វេទនា ។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ

# ទិដ្ឋិវគ្គ

(៧៣) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើរបស់អ្វីមាន ទើបសុខនិងទុក្ខក្នុងសន្តានកើតឡើងបាន ព្រោះអាស្រ័យអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ របស់យើងទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ទើបសុខនិងទុក្ខក្នុងសន្តានកើតឡើងបាន ព្រោះអាស្រ័យរូប កាលបើវេទនាមាន ។ បេ ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ទើបសុខនិងទុក្ខក្នុងសន្តានកើតឡើងបាន ព្រោះអាស្រ័យវិញ្ញាណ ។

(៧៤) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើសុខនិងទុក្ខក្នុងសន្តាននឹងកើតឡើង ព្រោះមិនបានអាស្រ័យរបស់នោះបានដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង

ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឧប្ប-ជ្ជេយ្យ អជ្ឈត្តំ សុខទុក្ខន្តិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៧៨) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ វេទនាយ សតិ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។

របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា តើសុខនិងទុក្ខក្នុងសន្ដាន នឹងកើតឡើង ព្រោះមិនបានអាស្រ័យរបស់នោះបាន ដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ រមែងដឹងច្បាស់ថា មគ្គ-ភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៧៩) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើរបស់អ្វីមាន បុគ្គលអាស្រ័យអ្វី ប្រកាន់អ្វី ទើបពិចារណាឃើញថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយរបស់យើងទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន បុគ្គលអាស្រ័យនូវរូប ប្រកាន់នូវរូប រមែងពិចារណាឃើញថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន បុគ្គលអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ រមែងពិចារណាឃើញថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

(៧៦) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ។ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សេយ្យាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ។ អបិ នុ តំ អនុបាទាយ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តា-តិ សមនុបស្សេយ្យាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៧៧) សាវត្ថី ។ តត្រ ខោ ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ សោ អត្តា សោ លោកោ សោ បេច្ច ភ-វិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ

(៧៦) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះ ដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ មាន សេចក្តីប្រែប្រួលជាធម្មតា តើបុគ្គល មិនបានប្រកាន់នូវរូបនោះ ហើយ គួរពិចារណាឃើញថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារ ទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ តើបុគ្គល មិនបានប្រកាន់នូវវិញ្ញាណនោះ ហើយគួរពិចារណាឃើញថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ កាលឃើញយ៉ាងនេះ ។ បេ ។ រមែងដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៧៧) ក្រុងសាវត្ថី ។ កន្លែងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបើរបស់អ្វីមាន បុគ្គលអាស្រ័យរបស់អ្វី ប្រកាន់របស់អ្វី ទើបទិដ្ឋិ កើតឡើង យ៉ាងនេះថា នោះជាខ្លួន នោះជាលោក អាត្មាអញនោះ នឹងទៅកើតក្នុងលោកខាងមុខ ជាអ្នកទៀងទាត់ ឋិតថេរ មានសភាព មិនបានប្រែប្រួល ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ យើងទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន បុគ្គលអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិ

ឧប្បជ្ជតិ សោ អត្តា សោ លោកោ សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ ។ វេទនាយ សតិ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ សោ អត្តា សោ លោកោ សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ ។

(៧៨) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សោ អត្តា សោ លោកោ សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ

កើតឡើង យ៉ាងនេះថា នោះជាខ្លួន នោះជាលោក អាត្មាអញនោះ នឹងទៅកើតក្នុងលោកខាងមុខ ជាអ្នកទៀងទាត់ ឋិតថេរ មានសភាពមិនបានប្រែប្រួល ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន បុគ្គលអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា នោះជាខ្លួន នោះជាលោក អាត្មាអញនោះ នឹងទៅកើតក្នុងលោកខាងមុខ ជាអ្នកទៀងទាត់ ឋិតថេរ មានសភាពមិនបានប្រែប្រួល ។

( ៧៨ ) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ហេតុនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា បុគ្គលមិនបានអាស្រ័យនូវរបស់នោះទេ តើទិដ្ឋិគួរកើតឡើង យ៉ាងនេះថា នោះជាខ្លួន នោះជាលោក អាត្មាអញនោះ នឹងទៅកើតក្នុងលោកខាងមុខ ជាអ្នកទៀងទាត់ ឋិតថេរ មានសភាពមិនប្រែប្រួលដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀង

វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សោ អត្តា សោ លោកោ សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៧៩) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ(១) ន មេ ភវិស្សតីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នោ ចស្សំ នោ ច មេ សិយា

---

១ ភវិស្សាមីតិបិ បាឋោ ទិស្សតិ ។

ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះ ជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា បុគ្គលមិនអាស្រ័យនូវវិញ្ញាណនោះទេ តើទិដ្ឋិគួរកើតឡើងយ៉ាងនេះថា នោះជាខ្លួន នោះជាលោក អាត្មាអញនោះ នឹងទៅកើតក្នុងលោកខាងមុខ ជាអ្នកទៀងទាត់ ឋិតថេរ មានសភាពមិនប្រែប្រួលដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៧៩) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើរបស់អ្វីមាន បុគ្គលអាស្រ័យរបស់អ្វី ប្រកាន់របស់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា បើអាត្មាអញនឹងមិនមានទេ (បរិក្ខារ) របស់អាត្មាអញក៏នឹងមិនមាន (បើកម្មសង្ខារជាទីញុំាងខន្ធឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញ ក៏នឹងមិនមានដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយរបស់យើងទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន បុគ្គលអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើង យ៉ាងនេះថា បើអាត្មាអញនឹងមិនមានទេ (បរិក្ខារ) របស់អាត្មាអញ ក៏នឹងមិនមាន

ន ភវិស្សតិ ន មេ ភវិស្សតីតិ ។ វេទនាយ សតិ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ។

(៨០) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្ប-ជ្ជេយ្យ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។

(បើកម្មសង្ខារជាទីញុំាងខន្ធឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញក៏នឹងមិនមានដែរ ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន បុគ្គលអាស្រ័យវិញ្ញាណ ប្រកាន់វិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា បើអាត្មាអញនឹងមិនមានទេ (បរិក្ខារ) របស់អាត្មាអញក៏នឹងមិនមាន (បើកម្មសង្ខារជាទីញុំាងខន្ធឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញក៏នឹងមិនមានដែរ ។

[ ៨០ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា បុគ្គលមិនអាស្រ័យនូវរបស់នោះទេ តើទិដ្ឋិគួរកើតឡើងយ៉ាងនេះថា បើអាត្មាអញនឹងមិនមានទេ (បរិក្ខារ) របស់អាត្មាអញក៏នឹងមិនមានដែរ (បើកម្មសង្ខារជាទីញុំាងខន្ធឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញនឹងមិនមានដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។

អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[៨១] សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស មិច្ឆាទិដ្ឋិ ឧប្បជ្ជតីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស មិច្ឆាទិដ្ឋិ ឧប្បជ្ជតិ ។ វេទនាយ សតិ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស មិច្ឆាទិដ្ឋិ ឧប្បជ្ជតិ ។

មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬ ជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា ព្រោះមិនអាស្រ័យនូវរបស់នោះទេ តើទិដ្ឋិគួរកើតឡើងយ៉ាងនេះថា បើអាត្មាអញនឹងមិនមានទេ (បរិក្ខារ) របស់អាត្មាអញក៏នឹងមិនមាន (បើកម្មសង្ខារជាទីញុំាងខន្ធឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញ ក៏នឹងមិនមានដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ កាលបើអរិយសាវ័កឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡស-កិច្ចនេះទៀត មិនមានឡើយ ។

[៨១] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើរបស់អ្វីមាន ព្រោះអាស្រ័យរបស់អ្វី ប្រកាន់របស់អ្វី ទើបមិច្ឆាទិដ្ឋិកើតឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបមិច្ឆាទិដ្ឋិកើតឡើង ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបមិច្ឆាទិដ្ឋិកើតឡើង ។

(៨២) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ។ បេ ។ អបិ នុ តំ អនុបាទាយ មិច្ឆាទិដ្ឋិ ឧប្បជ្ជេយ្យាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ មិច្ឆាទិដ្ឋិ ឧប្បជ្ជេយ្យាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៩២) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ។ បេ ។ ព្រោះមិនអាស្រ័យនូវរបស់នោះទេ តើមិច្ឆាទិដ្ឋិគួរកើតឡើងដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ព្រោះមិនអាស្រ័យរបស់នោះទេ តើមិច្ឆាទិដ្ឋិគួរកើតឡើងដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ កាលបើអរិយសាវ័កឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៨៣) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ
កឹ ឧបាទាយ កឹ អភិនិវិស្ស សក្កាយទិដ្ឋិ ឧប្បជ្ជ-
តីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ រូបេ
ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស
សក្កាយទិដ្ឋិ ឧប្បជ្ជតិ ។ វេទនាយ សតិ ។ សញ្ញា-
យ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ
វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស សក្កាយ-
ទិដ្ឋិ ឧប្បជ្ជតិ ។

(៨៤) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ
វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ អបិ នុ តំ អនុបាទាយ
សក្កាយទិដ្ឋិ ឧប្បជ្ជេយ្យាតិ ។ នោ ហេតំ ភន្តេ ។
វេទនា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ
វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ។ បេ ។
អបិ នុ តំ អនុបាទាយ សក្កាយទិដ្ឋិ ឧប្បជ្ជេយ្យាតិ ។
នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តា-
យាតិ បជានាតីតិ ។

[ ៨៣ ] គ្រូនសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើរបស់អ្វីមាន ព្រោះអាស្រ័យរបស់អ្វី ប្រកាន់របស់អ្វី ទើបសក្កាយទិដ្ឋិកើតឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបសក្កាយទិដ្ឋិកើតឡើង ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបសក្កាយទិដ្ឋិកើតឡើង ។

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ហេតុនោះដូចម្ដេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ព្រោះមិនអាស្រ័យនូវរបស់នោះទេ តើសក្កាយទិដ្ឋិគួរកើតឡើងដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ។ បេ ។ ព្រោះមិនអាស្រ័យរបស់នោះទេ តើសក្កាយទិដ្ឋិគួរកើតឡើងដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ កាលបើអរិយសាវកឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៨៥) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស អត្តានុទិដ្ឋិ ឧប្បជ្ជតីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស អត្តានុទិដ្ឋិ ឧប្បជ្ជតិ ។ វេទនាយ សតិ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស អត្តានុទិដ្ឋិ ឧប្បជ្ជតិ ។

(៨៦) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ យំ បនានិច្ចំ ។ បេ ។ អបិ នុ តំ អនុបាទាយ អត្តានុទិដ្ឋិ ឧប្បជ្ជេយ្យាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ។ បេ ។ អបិ នុ តំ អនុបាទាយ អត្តានុទិដ្ឋិ ឧប្បជ្ជេយ្យាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៨៥) គ្រង់សាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើរបស់អ្វី មាន ព្រោះអាស្រ័យរបស់អ្វី ប្រកាន់របស់អ្វី ទើបអត្តានុទិដ្ឋិកើតឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូប មាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបអត្តានុទិដ្ឋិកើតឡើង ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំង-ឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យ នូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបអត្តានុទិដ្ឋិកើតឡើង ។

(៨៦) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះ ដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះរបស់ណាមិនទៀង ។ បេ ។ ព្រោះមិនអាស្រ័យនូវរបស់នោះទេ តើអត្តានុ-ទិដ្ឋិគួរកើតឡើងដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ។ បេ ។ ព្រោះមិនអាស្រ័យនូវរបស់នោះទេ តើអត្តានុទិដ្ឋិគួរកើតឡើងដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ កាលបើអរិយសាវ័កឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គ-ភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៨៧) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឧប្បជ្ជន្តិ សញ្ញោជនាភិនិវេសវិនិពន្ធាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឧប្បជ្ជន្តិ សញ្ញោជនាភិនិវេសវិនិពន្ធា ។ វេទនាយ សតិ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឧប្បជ្ជន្តិ សញ្ញោជនាភិនិវេសវិនិពន្ធា ។

(៨៨) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ។បេ។ អបិ នុ តំ អនុបាទាយ ឧប្បជ្ជេយ្យុំ សញ្ញោជនាភិនិវេសវិនិពន្ធាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ

( ៨៧ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើរបស់អ្វី មាន ព្រោះអាស្រ័យរបស់អ្វី ប្រកាន់របស់អ្វី ទើបសញ្ញោជនៈ អភិនិវេសៈ(១) វិនិពន្ធៈ(២) កើតឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបសញ្ញោជនៈ អភិនិវេសៈ វិនិពន្ធៈ កើតឡើង ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបសញ្ញោជនៈ អភិនិវេសៈ វិនិពន្ធៈ កើតឡើង ។

( ៨៨ ) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ។ បេ ។ សញ្ញោជនៈ អភិនិវេសៈ វិនិពន្ធៈ គប្បីកើតឡើង ព្រោះមិនបានអាស្រ័យវិញ្ញាណនោះទេ ឬអ្វី ។ មិនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀង

១ ការប្រកាន់មាំក្នុងរូបារម្មណ៍ជាដើម ។ ២ ធម៌ជាចំណងនៃចិត្តមាន ៥ គឺ សេចក្តីស្រឡាញ់ពេញចិត្តក្នុងកាម ១ កាយ ១ រូប ១ បរិភោគអាហារឆ្អែតហើយប្រកបតែសេចក្តីសុខដោយការដេក ការផ្អែក ការលក់ ១ ប្រព្រឹត្តព្រហ្មចរិយៈ ប្រាថ្នាទៅកើតជាទេវតាណានីមួយ ១ ។

វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ
វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ
វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឧប្បជ្ជេយ្យុំ
សញ្ញោជនាភិនិវេសវិនិពន្ធាតិ ។ នោ ហេតំ ភន្តេ ។
ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៨៩) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ
ឧបាទាយ កឹ អភិនិវិស្ស ឧប្បជ្ជន្តិ សញ្ញោជនាភិនិវេ-
សវិនិពន្ធាជ្ឈោសានាតិ ។ ភគវំមូលកា នោ ភន្តេ
ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទា-
យ រូបំ អភិនិវិស្ស ឧប្បជ្ជន្តិ សញ្ញោជនាភិនិវេសវិនិ-
ពន្ធាជ្ឈោសានា ។ វេទនាយ សតិ ។ សញ្ញាយ
សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ
ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឧប្បជ្ជន្តិ សញ្ញោជ-
នាភិនិវេសវិនិពន្ធាជ្ឈោសានា ។

ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា ព្រោះមិនអាស្រ័យនូវរបស់នោះទេ តើសញ្ញោជនៈ អភិនិវេសៈ វិនិពន្ធៈ គួរកើតឡើងបានដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ កាលបើអរិយសាវ័កឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(៨៩) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើរបស់អ្វីមាន ព្រោះអាស្រ័យរបស់អ្វី ប្រកាន់របស់អ្វី ទើបសញ្ញោជនៈ អភិនិវេសៈ វិនិពន្ធៈ អជ្ឈោសានៈ(១) កើតឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ របស់យើងទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបសញ្ញោជនៈ អភិនិវេសៈ វិនិពន្ធៈ អជ្ឈោសានៈ កើតឡើង ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបសញ្ញោជនៈ អភិនិវេសៈ វិនិពន្ធៈ អជ្ឈោសានៈ កើតឡើង ។

---

១ សេចក្ដីប្រកាន់មាំ គឺតណ្ហា ។

(៩០) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ។បេ។ អបិ នុ តំ អនុបាទាយ ឧប្បជ្ជេយ្យុំ សញ្ញោជនាភិនិវេសវិនិពន្ធាជ្ឈោសានាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(៩១) សាវត្ថី ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។បេ។ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ តំ កឹ មញ្ញសិ អានន្ទ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។

( ៩០ ) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ។ បេ ។ ព្រោះមិនបានអាស្រ័យនូវរបស់នោះទេ តើសញ្ញោជនៈ អភិនិវេសៈ វិនិពន្ធៈ អជ្ឈោសានៈ គួរកើតឡើងបានដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ កាលបើអរិយសាវ័កឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

( ៩១ ) ក្រុងសាវត្ថី ។ គ្រានោះឯង ព្រះអានន្ទមានអាយុចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់សំដែងធម៌ ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ លុះខ្ញុំព្រះអង្គបានស្តាប់ធម៌ព្រះមានព្រះភាគហើយ ក៏នឹងចៀសចេញទៅតែម្នាក់ឯង មិនមានសេចក្តីប្រមាទ មានតែសេចក្តីព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សម្រាន្តនៅដោយឥរិយាបថទាំង៤ ។ ម្នាលអានន្ទ អ្នកសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះ ជាទុក្ខឬជាសុខ ។

ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

(៩២) តស្មាតិហានន្ទ យំ កិញ្ចិ រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ យា កាចិ វេទនា ។ យា កាចិ សញ្ញា ។ យេ កេចិ សង្ខារា ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា

ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។

(៩២) ម្នាលអានន្ទ ហេតុដូច្នោះ រូបណានីមួយ ក្នុងលោកនេះ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបណា មានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី បុគ្គលគួរឃើញនូវរូបទាំងអស់នោះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណានីមួយ ។ សញ្ញាណានីមួយ ។ សង្ខារទាំងឡាយណានីមួយ ។ វិញ្ញាណណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី

យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោ-

ហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្ប-

ញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ អានន្ទ សុតវា អរិយសាវ-

កោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញា-

យបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ

និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្ត-

មិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្ម-

ចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

ទិដ្ឋិវគ្គោ បញ្ចមោ

វិញ្ញាណណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី បុគ្គលគួរឃើញនូវវិញ្ញាណទាំងអស់នោះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ម្នាលអានន្ទ អរិយសាវ័កជាអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយនឹងរូប នឿយណាយនឹងវេទនា នឿយណាយនឹងសញ្ញា នឿយណាយនឹងសង្ខារទាំងឡាយ នឿយណាយនឹងវិញ្ញាណ កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ ។ កាលបើចិត្តផុតស្រឡះ ញាណក៏កើតឡើងថា ចិត្តរបស់អាត្មាអញផុតស្រឡះហើយ ។ ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

ចប់ ទិដ្ឋិវគ្គ ទី ៥ ។

## តស្សុទ្ទានំ ភវតិ

អជ្ឈត្តិកំ ឯតំ មម
ឯសោ អត្តា ចោ មេ សិយា
មិច្ឆាសក្កាយអត្តានុ ទ្វេ
ភិនិវេសា(១) អបរេ ទុវេ
អានន្ទេន បុរិតោ វគ្គោតិ ។
បុព្វបណ្ណាសកោ សមត្តោ ។

## តស្ស វគ្គុទ្ទានំ

អត្តា(២) ធម្មកថិកាវិជ្ជា
កុក្កុឡំ ទិដ្ឋិបញ្ចមំ
គតិយោ បញ្ញាសកោ វុត្តោ
និបាតោ តេន បវុច្ចតិ ។

## ខន្ធវគ្គស្ស និបាតកេ តិបញ្ញាសកំ សមត្តំ ។

ខន្ធសំយុត្តំ និដ្ឋិតំ ។

---

១ ឱ. ម អភិនិវេសាអានន្ទេនាតិ ។ ឧបរិបណ្ណាសកុទ្ទានំ អត្តំ វិជ្ជាសមុទយញ្ច កុក្កុឡំ ទិដ្ឋិ បញ្ចមំ គតិយោ បញ្ញាសកោ វុត្តោ និបាតោតិ បវុច្ចតីតិ ។ ខន្ធសំយុត្តំ និដ្ឋិតំ ។ ២ ឱ. ម. អត្តំ វិជ្ជាសមុទយញ្ច កុក្កុឡំ ទិដ្ឋិបញ្ចមំ គតិយោ បញ្ញាសកោ វុត្តោ និបាតោតិ បវុច្ចតីតិ ។

## ឧទ្ទាននៃទិដ្ឋិវគ្គនោះ គឺ

ពោលអំពីសុខនិងទុក្ខប្រព្រឹត្តទៅខាងក្នុង ១ អំពីសេចក្តីប្រកាន់ថា នុះរបស់អញ ១ នុះជាខ្លួនអញ ១ អំពីសេចក្តីប្រកាន់ថា (បរិក្ខារ) មិនគប្បីមានដល់អញ ១ អំពីមិច្ឆាទិដ្ឋិ ១ សក្កាយទិដ្ឋិ ១ អត្តានុទិដ្ឋិ ១ អំពីសេចក្តីប្រកាន់មាន ២ លើក វគ្គ (នេះ) បន្ត្រូប់ដោយរឿងព្រះអានន្ទ ១ ។

ចប់ ចុល្លបណ្ណាសកៈ ។

## ឧទ្ទាននៃវគ្គនៃបណ្ណាសកៈនោះ គឺ

អន្តវគ្គ ធម្មកថិកវគ្គ អវិជ្ជាវគ្គ កុក្កុឡវគ្គ ទិដ្ឋិវគ្គ ជាគម្រប់ ៥ បញ្ញាសកៈទី ៣ ព្រះមានព្រះភាគត្រាស់ហើយ ព្រោះហេតុនោះ ទើបហៅថា និបាត ។

ចប់ តិបញ្ញាសកៈ ក្នុងនិបាតនៃខន្ធវគ្គ ។

ចប់ ខន្ធសំយុត្ត ។

# រាធសំយុត្តំ

## មារវគ្គោ

[៩៣] សាវត្ថី ។ អថខោ អាយស្មា រាធោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច មារោ មារោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ មារោតិ វុច្ចតីតិ ។ រូបេ ខោ រាធ សតិ មារោ វា អស្ស មារេតា វា យោ វា បន មិយ្យតិ តស្មាតិហ ត្វំ រាធ រូបំ មារោតិ បស្ស មារេតាតិ បស្ស មិយ្យតីតិ បស្ស រោគោតិ បស្ស គណ្ឌោតិ បស្ស សល្លន្តិ បស្ស អឃន្តិ បស្ស អឃភូតន្តិ បស្ស យេ នំ ឯវំ បស្សន្តិ តេ សម្មា បស្សន្តិ ។ វេទនាយ សតិ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ មារោ វា

# រាធសំយុត្ត

## មារវគ្គ

(៩៣) ក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរាធៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាធៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា មារ មារ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា មារ តើដោយហេតុយ៉ាងណា ។ ម្នាលរាធៈ កាលបើរូបមាន សេចក្តីស្លាប់ក្តី សត្វដែលត្រូវគេសម្លាប់ក្តី ក៏មានដែរ ឬ សត្វណាតែងស្លាប់ (សត្វនោះក៏មានដែរ) ម្នាលរាធៈ ហេតុដូច្នេះ អ្នកចូរឃើញនូវរូបថាជាមារ ឃើញថាជាសត្វដែលត្រូវគេសម្លាប់ ឃើញថា រមែងស្លាប់ ឃើញថាជារោគ ឃើញថាជាបូស ឃើញថាជាសរ ឃើញថាជាទុក្ខ ឃើញថាជារបស់មានទុក្ខ ពួកជនណា ឃើញនូវរូបនោះយ៉ាងនេះ ពួកជននោះ ឈ្មោះថាឃើញប្រពៃ ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន សេចក្តីស្លាប់ក្តី

អស្ស មារេតា វា យោ វា បន មិយ្យតិ តស្មាតិហ ត្វំ រាធ វិញ្ញាណំ មារោតិ បស្ស មារេតាតិ បស្ស មិយ្យតីតិ បស្ស រោគោតិ បស្ស គណ្ឌោតិ បស្ស សល្លន្តិ បស្ស អឃន្តិ បស្ស អឃភូតន្តិ បស្ស យេ នំ ឯវំ បស្សន្តិ តេ សម្មា បស្សន្តីតិ ។ សម្មាទស្សនំ បន ភន្តេ កិមត្ថិយន្តិ ។ សម្មាទស្សនំ ខោ រាធ និព្វិទត្ថំ ។ និព្វិទា បន ភន្តេ កិមត្ថិយាតិ ។ និព្វិទា ខោ រាធ វិរាគត្ថា ។ វិរាគោ បន ភន្តេ កិមត្ថិយោតិ ។ វិរាគោ ខោ រាធ វិមុត្តត្ថោ ។ វិមុត្តិ បន ភន្តេ កិមត្ថិយាតិ ។ វិមុត្តិ ខោ រាធ និព្វានត្ថា ។

សត្វដែលត្រូវគេសម្លាប់ក្តី ក៏មានដែរឬ សត្វណាតែងស្លាប់ (សត្វនោះក៏មានដែរ) ម្នាលរាធៈ ហេតុដូច្នោះ អ្នកចូរឃើញនូវវិញ្ញាណថាជាមារ ឃើញថា ជាសត្វដែលត្រូវគេសម្លាប់ ឃើញថាតែងស្លាប់ ឃើញថាជារោគ ឃើញថាជាបូស ឃើញថាជាសរ ឃើញថាជាទុក្ខ ឃើញថាជារបស់មានទុក្ខ ពួកជនណា ឃើញនូវវិញ្ញាណនោះយ៉ាងនេះ ពួកជននោះ ឈ្មោះថាឃើញប្រពៃ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការឃើញប្រពៃ តើមានប្រយោជន៍អ្វី ។ ម្នាលរាធៈ ការឃើញប្រពៃ មានប្រយោជន៍ឲ្យកើតសេចក្តីនឿយណាយ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសេចក្តីនឿយណាយ មានប្រយោជន៍អ្វី ។ ម្នាលរាធៈ សេចក្តីនឿយណាយ មានប្រយោជន៍ឲ្យកើតការប្រាសចាកតម្រេក ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការប្រាសចាកតម្រេក មានប្រយោជន៍អ្វី ។ ម្នាលរាធៈ ការប្រាសចាកតម្រេក មានប្រយោជន៍ ឲ្យកើតការផុតស្រឡះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការផុតស្រឡះ មានប្រយោជន៍អ្វី ។ ម្នាលរាធៈ ការផុតស្រឡះ មានប្រយោជន៍ឲ្យបានព្រះនិព្វាន ។

និព្វានំ បន ភន្តេ កិមត្ថិយន្តិ ។ អច្ចសរា(១) រាធ បញ្ហំ នាសក្ខិ បញ្ហស្ស បរិយន្តំ គហេតុំ ។ និព្វានោគធំ ហិ រាធ ព្រហ្មចរិយំ វុស្សតិ និព្វានបរិយោសានន្តិ(២) ។

[៩៤] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថ ខោ អាយស្មា រាធោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច សត្តោ សត្តោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សត្តោតិ វុច្ចតីតិ ។ រូបេ ខោ រាធ យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា តត្រ សត្តោ តត្រ វិសត្តោ តស្មា សត្តោតិ វុច្ចតិ ។ វេទនាយ ។ សញ្ញាយ ។ សង្ខារេសុ ។ វិញ្ញាណេ យោ ឆន្ទោ យោ រាគោ យា នន្ទិ

---

១ ឱ. អស្សូ រាធ ។ ម. អច្ចយា រាធ ។ ២ និព្វានបរាយនំ ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះនិព្វាន មានអ្វីជាប្រយោជន៍ ។ ម្នាលរាធៈ អ្នកប្រព្រឹត្តកន្លង គឺសួរហួសបញ្ហា មិនអាចកាន់យកនូវទីបំផុតនៃបញ្ហាបានឡើយ ។ ម្នាលរាធៈ ព្រោះថា ការប្រព្រឹត្តិព្រហ្មចរិយៈ មានព្រះនិព្វានជាទីពឹង មានព្រះនិព្វានជាទីបំផុត ។

( ៩៤ ) សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរាធៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា សត្វ សត្វ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា សត្វ តើដោយហេតុដូចម្តេច ។ ម្នាលរាធៈ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងរូប បុគ្គលដែលជាប់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ ចំពាក់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ លោកហៅថា សត្វ ។ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។

យា តណ្ហា តត្រ សត្តោ តត្រ វិសត្តោ តស្មា សត្តោតិ វុច្ចតិ ។ សេយ្យថាបិ រាធ កុមារកា វា កុមារិកាយោ វា បំស្វាគារកេហិ កីឡន្តា(១) យាវកីវញ្ច តេសុ បំស្វាគារកេសុ អវីតរាគា ហោន្តិ អវីតច្ឆន្ទា អវីតបេម្មា អវីតបិបាសា អវីតបរិឡាហា អវីតតណ្ហា តាវតា តានិ បំស្វាគារកានិ អាលយន្តិ កេឡាយន្តិ ធនាយន្តិ មមាយន្តិ យតោ ច ខោ រាធ កុមារកា វា កុមារិកាយោ វា តេសុ បំស្វាគារកេសុ វីតរាគា ហោន្តិ វីតច្ឆន្ទា វីតបេម្មា វីតបិបាសា វីតបរិឡាហា វីតតណ្ហា

១ ឱ.ម. កិឡន្តិ ។

ក្នុងវិញ្ញាណ បុគ្គលដែលជាប់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ ចំពាក់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ លោកហៅថា សត្វ ។ ម្នាលរាធៈ ដូចពួកកុមារក្តី ពួកកុមារីក្តី នាំគ្នាលេងកូនផ្ទះធ្វើពីអាចម៍ដី មិនទាន់ប្រាសចាកសេចក្តីត្រេកអរ មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីឆ្អេឆ្អា មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា ក្នុងកូនផ្ទះធ្វើពីអាចម៍ដីទាំងនោះ កំណត់ត្រឹមណា តែងអាល័យ តែងប្រកាន់លេង តែងប្រកាន់ថាជាទ្រព្យ ប្រកាន់ថាជារបស់ខ្លួន ចំពោះកូនផ្ទះធ្វើពីអាចម៍ដី កំណត់ត្រឹមនោះ ម្នាលរាធៈ កាលណាបើពួកកុមារក្តី ពួកកុមារីក្តី លែងត្រេកអរ លែងពេញចិត្ត លែងស្រឡាញ់ លែងស្រេកឃ្លាន លែងឆ្អេឆ្អា លែងប្រាថ្នា

អថខោ តានិ បំស្វាគារកានិ ហត្ថេហិ ច បាទេហិ
ច វិកិរន្តិ វិធមន្តិ វិទ្ធំសេន្តិ វិកីឡនិកំ ករោន្តិ ។
ឯវមេវ ខោ រាធ តុម្ហេបិ រូបំ វិកិរថ វិធមថ វិទ្ធំសេថ
វិកីឡនិកំ ករោថ តណ្ហាក្ខយាយ បដិបជ្ជថ វេទនំ
វិកិរថ វិធមថ វិទ្ធំសេថ វិកីឡនិកំ ករោថ តណ្ហាក្ខ-
យាយ បដិបជ្ជថ ។ សញ្ញំ ។ សង្ខារេ វិកិរថ វិធមថ
វិទ្ធំសេថ វិកីឡនិកំ ករោថ តណ្ហាក្ខយាយ បដិបជ្ជថ
វិញ្ញាណំ វិកិរថ វិធមថ វិទ្ធំសេថ វិកីឡនិកំ ករោថ
តណ្ហាក្ខយាយ បដិបជ្ជថ ។ តណ្ហាក្ខយោ ហិ រាធ
និព្វានន្តិ ។

ក្កងកូនផ្ទះធ្វើពីអាចម៍ដីទាំងនោះហើយ យកដៃនិងជើងទៅកំចាយចោល ឈូសចោល កំចាត់ចោល នូវកូនផ្ទះធ្វើពីអាចម៍ដីទាំងនោះ ធ្វើឲ្យជារបស់លេងមិនកើតក្នុងកាលនោះ យ៉ាងណាមិញ ។ ម្នាលរាធៈ អ្នកទាំងឡាយ ចូរកំចាយចោល ឈូសចោល កំចាត់ចោល នូវរូប ចូរធ្វើឲ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហា ចូរកំចាយចោល ឈូសចោល កំចាត់ចោល នូវវេទនា ចូរធ្វើឲ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហា ។ ចូរកំចាយចោល ឈូសចោល កំចាត់ចោលនូវសញ្ញា ។ នូវសង្ខារទាំងឡាយ ចូរធ្វើឲ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហា ចូរកំចាយចោល ឈូសចោល កំចាត់ចោល នូវវិញ្ញាណ ចូរធ្វើឲ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហា យ៉ាងនោះឯង ។ ម្នាលរាធៈ ព្រោះថា ការអស់ទៅនៃតណ្ហា ឈ្មោះថាព្រះនិព្វាន ។

[៩៥] សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច ភវនេត្តិ ភវនេត្តីតិ(១) ភន្តេ វុច្ចតិ កតមា នុ ខោ ភន្តេ ភវនេត្តិ កតមោ ភវនេត្តិនិរោធោតិ ។ រូបេ ខោ រាធ យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា ។ អយំ វុច្ចតិ ភវនេត្តិ តេសំ និរោធា ភវនេត្តិនិរោធោ ។ វេទនាយ យោ ឆន្ទោ ។បេ។ សញ្ញាយ ។ សង្ខារេសុ យោ ឆន្ទោ ។ វិញ្ញាណេ យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា ។ អយំ វុច្ចតិ ភវនេត្តិ តេសំ និរោធា ភវនេត្តិនិរោធោតិ ។

---

១ ឱ. ភវនេត្តិ ភវនេត្តិនិរោធោតិ ។ ម. ភវនេត្តិនិរោធោ ភវនេត្តិនិរោធោតិ ភន្តេតិ ។

( ៩៥ ) ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា ភវនេត្តិ ភវនេត្តិ(១) ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ភវនេត្តិ តើដូចម្តេច សេចក្តីរលត់នៃភវនេត្តិ តើដូចម្តេច ។ ម្នាលរាធៈ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ឧបាយ(២)និងឧបាទានដែលជាទីឈរ អង្គុយ ដេកនៃចិត្តណា ក្នុងរូប ។ នេះហៅថា ភវនេត្តិ ហៅថា សេចក្តីរលត់នៃភវនេត្តិ ព្រោះការរលត់នៃសេចក្តីពេញចិត្តជាដើមនោះ ។ សេចក្តីពេញចិត្តណា ក្នុងវេទនា ។ បេ ។ ក្នុងសញ្ញា ។ សេចក្តីពេញចិត្តណា ក្នុងសង្ខារទាំងឡាយ ។ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ឧបាយនិងឧបាទាន ដែលជាទីឈរ អង្គុយ ដេក នៃចិត្តណា ក្នុងវិញ្ញាណ ។ នេះហៅថា ភវនេត្តិ ហៅថា សេចក្តីរលត់ទៅនៃភវនេត្តិ ព្រោះការរលត់នៃសេចក្តីពេញចិត្តជាដើមនោះ ។

---

១ ធម្មជាតិជាខ្សែសម្រាប់បងដឹកសត្វនៅក្នុងភពតូច-ធំ បានដល់តណ្ហា ។ ២ ប្រែថា ចូលទៅកាន់តេភូមិកធម៌ បានដល់ តណ្ហា និង ទិដ្ឋិ ។

(៩៦) សាវត្ថី ។ អថ ខោ អាយស្មា រាធោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ រាធំ ភគវា ឯតទវោច បរិញ្ញេយ្យេ ច រាធ ធម្មេ ទេសេស្សាមិ បរិញ្ញញ្ច បរិញ្ញាតាវិញ្ច បុគ្គលំ តំ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា រាធោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច កតមេ ច រាធ បរិញ្ញេយ្យា ធម្មា ។ រូបំ ខោ រាធ បរិញ្ញេយ្យោ ធម្មោ វេទនា បរិញ្ញេយ្យោ ធម្មោ សញ្ញា បរិញ្ញេយ្យោ ធម្មោ សង្ខារា បរិញ្ញេយ្យា ធម្មា វិញ្ញាណំ បរិញ្ញេយ្យោ ធម្មោ ។ ឥមេ វុច្ចន្តិ រាធ បរិញ្ញេយ្យា ធម្មា ។ កតមា ច រាធ បរិញ្ញា ។ យោ ខោ (១)រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ។ អយំ វុច្ចតិ រាធ

---

១ ឱ ម. យោ ខោ រាធ រាគក្ខយោ ។

[៤៧] ក្រុងសាវត្ថី ។ គ្រានោះ ព្រះរាធៈមានអាយុចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ទើបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាធៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលរាធៈ តថាគតនឹងសំដែងនូវធម៌ទាំងឡាយ ដែលបុគ្គលគួរកំណត់ដឹងផង នូវប្រាជ្ញាជាគ្រឿងកំណត់ដឹងផង នូវបុគ្គលជាអ្នកកំណត់ដឹងផង អ្នកចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសំដែង ។ ព្រះរាធៈមានអាយុ ក៏ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលរាធៈ ចុះធម៌ដែលបុគ្គលគួរកំណត់ដឹង តើដូចម្តេច ។ ម្នាលរាធៈ រូបជាធម៌ដែលបុគ្គលគួរកំណត់ដឹង វេទនាជាធម៌ដែលបុគ្គលគួរកំណត់ដឹង សញ្ញាជាធម៌ដែលបុគ្គលគួរកំណត់ដឹង សង្ខារទាំងឡាយជាធម៌ដែលបុគ្គលគួរកំណត់ដឹង វិញ្ញាណជាធម៌ដែលបុគ្គលគួរកំណត់ដឹង ។ ម្នាលរាធៈ បញ្ចក្ខន្ធទាំងនេះ ហៅថា ធម៌ដែលបុគ្គលគួរកំណត់ដឹង ។ ម្នាលរាធៈ ចុះប្រាជ្ញាជាគ្រឿងកំណត់ដឹង តើដូចម្តេច ។ ការអស់នៃរាគៈ ការអស់នៃទោសៈ ការអស់នៃមោហៈណា ។ ម្នាលរាធៈ នេះហៅថា

បរិញ្ញា ។ កតមោ ច រាធ បរិញ្ញាតាវី បុគ្គលោ ។ អរហាតិស្ស វចនីយំ ស្វាយំ(១) អាយស្មា ឯវំនាមោ ឯវំគោត្តោ ។ អយំ វុច្ចតិ រាធ បរិញ្ញាតាវី បុគ្គលោតិ ។

(៩៧) សាវត្ថី ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ រាធំ ភគវា ឯតទវោច បញ្ចិមេ រាធ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោ ។ យេ ហិ កេចិ រាធ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ ន មេ តេ រាធ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បន តេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

---

១ យោយមាយស្មា ។

ប្រាជ្ញាជាគ្រឿងកំណត់ដឹង ។ ម្នាលរាធៈ ចុះបុគ្គលអ្នកកំណត់ដឹង តើដូចម្តេច ។ គប្បីឆ្លើយថា ព្រះអរហន្ត លោកមានអាយុនោះឯង មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ ។ ម្នាលរាធៈ នេះហៅថាបុគ្គលអ្នកកំណត់ដឹង ។

[៩៧] ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុអង្គុយ ក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលរាធៈ ឧបាទានក្ខន្ធទាំងឡាយនេះ មាន ៥ ប្រការ ។ ៥ ប្រការ តើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលរាធៈ សមណៈឬព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់តាមពិត នូវអានិសង្សផង នូវទោសផង នៃឧបាទានក្ខន្ធទាំង ៥ នេះ នូវការរលាស់ចេញនូវឧបាទានក្ខន្ធទាំង ៥ នេះផង ម្នាលរាធៈ សមណៈឬព្រាហ្មណ៍ទាំងនោះ តថាគតមិនបានសន្មតថាជាសមណៈក្នុងពួកសមណៈ ឬ មិនបានសន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទេ អ្នកទាំងនោះ មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានសម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវប្រយោជន៍នៃសមណភាព ឬ ប្រយោជន៍នៃព្រាហ្មណភាពឡើយ ។

(៩៨) យេ ច ខោ កេចិ រាធ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានន្តិ តេ ខោមេ រាធ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

(៩៩) ឯកាមន្តំ និសិន្នំ ខោ អាយស្មន្តំ រាធំ ភគវា ឯតទវោច បញ្ចិមេ រាធ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោ ។ យេ ហិ កេចិ រាធ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ ។បេ។ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

[៩៨] ម្នាលរាធៈ សមណៈឬព្រាហ្មណ៍ណាទីមួយ ដឹងច្បាស់តាមពិត នូវអានិសង្សនិងទោសនៃឧបាទានក្ខន្ធទាំង ៥ នេះផង នូវការរលាស់ចេញ នូវឧបាទានក្ខន្ធទាំង៥ នេះផង ម្នាលរាធៈ សមណៈឬព្រាហ្មណ៍ទាំងនោះ តថាគតបានសន្មតថាជាសមណៈ ក្នុងពួកសមណៈផង សន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង អ្នកទាំងនោះ បានធ្វើឲ្យជាក់ច្បាស់ បានសម្រេច ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវប្រយោជន៍នៃសមណភាពផង នូវប្រយោជន៍នៃព្រាហ្មណភាពផង ។

[៩៩] លុះព្រះរាធៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលរាធៈ ឧបាទានក្ខន្ធទាំងឡាយនេះ មាន ៥ ប្រការ ។ ៥ ប្រការ តើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលរាធៈ ពួកសមណៈឬព្រាហ្មណ៍ណាទីមួយ មិនដឹងច្បាស់តាមពិត នូវការកើតឡើងនិងការអស់ទៅ នូវអានិសង្សនិងទោស នៃឧបាទានក្ខន្ធទាំង៥ នេះផង នូវការរលាស់ចេញ នូវឧបាទានក្ខន្ធទាំង ៥ នេះផង ។ បេ ។ មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានសម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ។

(១០០) សាវត្ថី ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ រាធំ ភគវា ឯតទវោច បញ្ចិមេ រាធ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ ។បេ។ វិញ្ញាណូបាទានក្ខន្ធោ ។ យតោ ខោ រាធ អរិយសាវកោ ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ វុច្ចតិ រាធ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(១០១) សាវត្ថី ។ តត្រ ខោ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ រាធំ ភគវា ឯតទវោច បញ្ចិមេ រាធ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធោ ។ យតោ ខោ រាធ ភិក្ខុ ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច

( ១០០ ) ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលរាធៈ ឧបាទានក្ខន្ធទាំងឡាយនេះ មាន ៥ ប្រការ ។ ៥ ប្រការ តើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលរាធៈ កាលណាបើអរិយសាវ័កដឹងច្បាស់តាមពិត នូវការកើតឡើងនិងការរលត់ទៅ នូវអានិសង្សនិងទោសនៃឧបាទានក្ខន្ធទាំង ៥ នេះផង នូវការរលាស់ចេញនូវឧបាទានក្ខន្ធទាំង ៥ នេះផង ។ ម្នាលរាធៈ អរិយសាវ័កនេះ ហៅថា សោតាបន្នបុគ្គល មានភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

( ១០១ ) ក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ លុះព្រះរាធៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលរាធៈ ឧបាទានក្ខន្ធទាំងឡាយនេះ មាន ៥ ប្រការ ។ ៥ ប្រការ តើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ ។ បេ ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលរាធៈ កាលណាបើភិក្ខុ ដឹងច្បាស់តាមពិត នូវការកើតឡើងនិងការរលត់ទៅ នូវអានិសង្សនិងទោស នៃឧបាទានក្ខន្ធទាំង ៥ នេះផង

និស្សរណញ្ច យថាភូតំ វិទិត្វា អនុបាទា វិមុត្តោ ហោតិ ។ អយំ វុច្ចតិ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោតិ ។

(១០២) សាវត្ថី ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ រាធំ ភគវា ឯតទវោច រូបេ ខោ រាធ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា តំ បជហថ ឯវន្តំ រូបំ បហីនំ ភវិស្សតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្គតំ អាយតឹ អនុប្បាទធម្មំ ។ វេទនាយ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា តំ បជហថ ឯវំ សា វេទនា បហីនា ភវិស្សតិ

នូវការរលាស់ចេញ នូវឧបាទានក្ខន្ធទាំង ៥ នេះផង ហើយមានចិត្តផុតស្រឡះ ដោយមិនប្រកាន់មាំ ។ ម្នាលរាធៈ ភិក្ខុនេះហៅថា អរ-ហន្តខីណាស្រព មានព្រហ្មចរិយធម៌នៅរួចហើយ មានសោឡសកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានសញ្ញោជនៈក្នុងភពគឺតណ្ហាអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ។

[ ១០២ ] ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលរាធៈ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងរូប អ្នកទាំងឡាយចូរលះបង់នូវសេចក្តីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ រូបនោះ មុខជាអ្នកទាំងឡាយ នឹងលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតតទៅ ពុំខាន ។ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងវេទនា អ្នកទាំងឡាយចូរលះបង់នូវសេចក្តីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ វេទនានោះ មុខជាអ្នកទាំងឡាយ

ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អ-នុប្បាទធម្មា ។ សញ្ញាយ ។ សង្ខារេសុ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា តំ បជហថ ឯវន្តេ សង្ខារា បហីនា ភវិស្សន្តិ ឧច្ឆិន្នមូលា តា-លាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ វិញ្ញាណេ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា តំ បជហថ ឯវន្តំ វិញ្ញាណំ បហីនំ ភវិស្សតិ ឧច្ឆិន្ន-មូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទ-ធម្មន្តិ ។

នឹងលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានវិបភាព មានសភាពមិនកើតតទៅ ពុំខាន ។ សេចក្ដីពេញចិត្តណា សេចក្ដីត្រេកអរណា សេចក្ដីរីករាយណា សេចក្ដីប្រាថ្នាណា ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ អ្នកទាំង-ឡាយចូរលះបង់នូវសេចក្ដីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ សង្ខារទាំងនោះ មុខជាអ្នកទាំងឡាយ នឹងលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានវិបភាព មានសភាពមិនកើតតទៅ ពុំខាន ។ សេចក្ដីពេញចិត្តណា សេចក្ដីត្រេកអរណា សេចក្ដីរីករាយណា សេចក្ដីប្រាថ្នាណា ក្នុងវិញ្ញាណ អ្នកទាំងឡាយ ចូរលះបង់នូវសេចក្ដីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ វិញ្ញាណនោះ មុខជាអ្នកទាំងឡាយនឹងលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានវិបភាព មានសភាពមិនកើតតទៅ ពុំខាន ។

[១០៣] សាវត្ថី ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ រាធំ ភគវា ឯតទវោច រូបេ ខោ រាធ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា យេ ឧបាយុបាទានា ចេត-សោ អធិដ្ឋានាភិនិវេសានុសយា តេ បជហថ ឯវន្តំ រូបំ បហីនំ ភវិស្សតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អន-ភាវង្កតំ អាយតឹ អនុប្បាទធម្មំ ។ វេទនាយ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ បជហថ ឯវំ សា វេទនា បហីនា ភវិស្សតិ

(១០៣) ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលរាធៈ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ឧបាយនិងឧបាទាន ជាទីឈរ អង្គុយ ដេក នៃចិត្តណា ក្នុងរូប អ្នកទាំងឡាយចូរលះបង់ នូវសេចក្តីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ រូបនោះ មុខជាអ្នកទាំងឡាយ នឹងលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតតទៅ ពុំខាន ។ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ឧបាយនិងឧបាទាន ជាទីឈរ អង្គុយ ដេក នៃចិត្តណា ក្នុងវេទនា អ្នកទាំងឡាយចូរលះបង់ នូវសេចក្តីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ វេទនានោះ មុខជាអ្នកទាំងឡាយនឹងលះបង់

ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អ-
នុប្បាទធម្មា ។ សញ្ញាយ ។ សង្ខារេសុ យោ ឆន្ទោ
យោ រាគោ យា នន្ទិ យា តណ្ហា យេ ឧបាយុបាទានា
ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ បជហាថ
ឯវន្តេ សង្ខារា បហីនា ភវិស្សន្តិ ឧច្ឆិន្នមូលា តាលា-
វត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ វិញ្ញា-
ណេ យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា
យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុ-
សយា តេ បជហាថ ឯវន្តំ វិញ្ញាណំ បហីនំ ភវិស្សតិ

គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតតទៅ ពុំខាន ។ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ឧបាយនិងឧបាទាន ដែលជាទីឈរ អង្គុយ ដេក នៃចិត្តណា ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ អ្នកទាំងឡាយចូរលះបង់នូវសេចក្តីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ សង្ខារទាំងនោះ មុខជាអ្នកទាំងឡាយ នឹងលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតតទៅ ពុំខាន ។ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ឧបាយនិងឧបាទាន ដែលជាទីឈរ អង្គុយ ដេក នៃចិត្តណា ក្នុងវិញ្ញាណ អ្នកទាំងឡាយចូរលះបង់ នូវសេចក្តីពេញចិត្តជាដើមនោះចេញ កាលបើយ៉ាងនេះ វិញ្ញាណនោះ មុខជាអ្នកទាំងឡាយ នឹងលះបង់

ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មន្តិ ។

មារវគ្គោ បឋមោ ។

តស្សុទ្ទានំ

មារោ សត្តោ ភវនេត្តិ
បរិញ្ញេយ្យា សមណា ទុវេ
សោតាបន្នោ អរហា ច
ឆន្ទរាគា អបរេ ទុវេតិ ។

---

គាស់រំលើងឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតតទៅ ពុំខាន ។

ចប់ មារវគ្គ ទី ១ ។

## ឧទ្ទានក្នុងមារវគ្គនោះ គឺ

និយាយអំពីសេចក្ដីស្លាប់ ១ សត្វ ១ ភវនេត្តិ ១ ធម៌ដែលបុគ្គលគួរកំណត់ដឹង ១ ពួកសមណៈ ២ លើក សោតាបន្នបុគ្គល ១ ព្រះអរហន្ត ១ សេចក្ដីពេញចិត្តនិងសេចក្ដីត្រេកអរ ២ លើក ។

---

# មារធម្មវគ្គោ

[១០៤] សាវត្ថី ។ អថខោ អាយស្មា រាធោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច មារោ មារោតិ ភន្តេ វុច្ចតិ កតមោ នុ ខោ ភន្តេ មារោតិ ។ រូបំ ខោ រាធ មារោ វេទនា មារោ សញ្ញា មារោ សង្ខារា មារោ វិញ្ញាណំ មារោ ។ ឯវំ បស្សំ រាធ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ

# មារវគ្គ

[ ១០៤ ] ក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរាធៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា មារ មារ(១) ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាមារ ។ ម្នាលរាធៈ រូបជាមារ វេទនាជាមារ សញ្ញាជាមារ សង្ខារទាំងឡាយជាមារ វិញ្ញាណជាមារ ។ ម្នាលរាធៈ អរិយសាវកជាអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយទាំងរូបផង នឿយណាយទាំងវេទនាផង នឿយណាយទាំងសញ្ញាផង នឿយណាយទាំងសង្ខារទាំងឡាយផង នឿយណាយទាំងវិញ្ញាណផង

១ សំដៅយកសេចក្ដីស្លាប់ ។

និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(១០៨) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច មារធម្មោ មារធម្មោតិ ភន្តេ វុច្ចតិ កតមោ នុ ខោ ភន្តេ មារធម្មោតិ ។ រូបំ ខោ រាធ មារធម្មោ វេទនា មារធម្មោ សញ្ញា មារធម្មោ សង្ខារា មារធម្មោ វិញ្ញាណំ មារធម្មោ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

កាលបើនឿយណាយ ក៏តែងធុញទ្រាន់ ចិត្តតែងរួចស្រឡះ ព្រោះសេចក្តីធុញទ្រាន់ ។ កាលបើចិត្តរួចស្រឡះហើយ សេចក្តីដឹងថា អាត្មាអញរួចស្រឡះហើយ ។ អរិយសាវ័កនោះតែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

( ១០៥ ) ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា មារធម៌ មារធម៌[1] ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាមារធម៌ ។ ម្នាលរាធៈ រូបជាមារធម៌ វេទនាជាមារធម៌ សញ្ញាជាមារធម៌ សង្ខារទាំងឡាយជាមារធម៌ វិញ្ញាណជាមារធម៌ ។ កាលអរិយសាវ័កនោះឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

---

១ ធម៌គឺសេចក្តីស្លាប់ ។

(១០៦) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច អនិច្ចំ អនិច្ចន្តិ ភន្តេ វុច្ចតិ កតមំ នុ ខោ ភន្តេ អនិច្ចន្តិ ។ រូបំ ខោ រាធ អនិច្ចំ វេទនា អនិច្ចា សញ្ញា ។បេ។ វិញ្ញាណំ អនិច្ចំ ។ ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(១០៧) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច អនិច្ចធម្មោ អនិច្ចធម្មោតិ ភន្តេ វុច្ចតិ កតមោ នុ ខោ ភន្តេ អនិច្ចធម្មោតិ ។ រូបំ ខោ រាធ អនិច្ចធម្មោ វេទនា អនិច្ចធម្មោ សញ្ញា អនិច្ចធម្មោ សង្ខារា អនិច្ចធម្មោ វិញ្ញាណំ អនិច្ចធម្មោ ។ ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[ ១០៦ ] ក្រុងសាវត្ថី ។ លុះព្រះរាធៈ មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា អនិច្ចៈ អនិច្ចៈ(១) ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាអនិច្ចៈ ។ ម្នាលរាធៈ រូបជាអនិច្ចៈ វេទនាជាអនិច្ចា សញ្ញា ។ បេ ។ វិញ្ញាណជាអនិច្ចៈ ។ កាលអរិយសាវ័កឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[ ១០៧ ] ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា អនិច្ចធម៌ អនិច្ចធម៌ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាអនិច្ចធម៌ ។ ម្នាលរាធៈ រូបជាអនិច្ចធម៌ វេទនាជាអនិច្ចធម៌ សញ្ញាជាអនិច្ចធម៌ សង្ខារទាំងឡាយជាអនិច្ចធម៌ វិញ្ញាណជាអនិច្ចធម៌ ។ កាលអរិយសាវ័កឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

---

១ សេចក្តីមិនទៀង ។

(១០៨) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច ទុក្ខំ ទុក្ខន្តិ ភន្តេ វុច្ចតិ កតមំ នុ ខោ ភន្តេ ទុក្ខន្តិ ។ រូបំ ខោ រាធ ទុក្ខំ វេទនា ទុក្ខា សញ្ញា ទុក្ខា សង្ខារា ទុក្ខា វិញ្ញាណំ ទុក្ខំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(១០៩) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច ទុក្ខធម្មោ ទុក្ខធម្មោតិ ភន្តេ វុច្ចតិ កតមោ នុ ខោ ភន្តេ ទុក្ខធម្មោតិ ។ រូបំ ខោ រាធ ទុក្ខធម្មោ វេទនា ទុក្ខធម្មោ សញ្ញា ទុក្ខធម្មោ សង្ខារា ទុក្ខធម្មោ វិញ្ញាណំ ទុក្ខធម្មោ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

( ១០៨ ) ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា ទុក្ខ ទុក្ខ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាទុក្ខ ។ ម្នាលរាធៈ រូបជាទុក្ខ វេទនាជាទុក្ខ សញ្ញាជាទុក្ខ សង្ខារទាំងឡាយជាទុក្ខ វិញ្ញាណជាទុក្ខ ។ កាលអរិយសាវ័កឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

( ១០៩ ) ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា ទុក្ខធម៌ ទុក្ខធម៌(១) ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាទុក្ខធម៌ ។ ម្នាលរាធៈ រូបជាទុក្ខធម៌ វេទនាជាទុក្ខ-ធម៌ សញ្ញាជាទុក្ខធម៌ សង្ខារទាំងឡាយជាទុក្ខធម៌ វិញ្ញាណជាទុក្ខធម៌ ។ កាលអរិយសាវ័កឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

---

១ ធម៌នាំមកនូវសេចក្តីទុក្ខ ។

[១១០] សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច អនត្តា អនត្តាតិ ភន្តេ វុច្ចតិ កតមោ នុ ខោ ភន្តេ អនត្តាតិ ។ រូបំ ខោ រាធ អនត្តា វេទនា អនត្តា សញ្ញា អនត្តា សង្ខារា អនត្តា វិញ្ញាណំ អនត្តា ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[១១១] សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច អនត្តធម្មោ អនត្តធម្មោតិ ភន្តេ វុច្ចតិ កតមោ នុ ខោ ភន្តេ អនត្តធម្មោតិ ។ រូបំ ខោ រាធ អនត្តធម្មោ វេទនា អនត្តធម្មោ សញ្ញា អនត្តធម្មោ សង្ខារា អនត្តធម្មោ វិញ្ញាណំ អនត្តធម្មោ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[ ១១០ ] ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា អនត្តា អនត្តា(១) ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាអនត្តា ។ ម្នាលរាធៈ រូបជាអនត្តា វេទនាជាអនត្តា សញ្ញាជាអនត្តា សង្ខារទាំងឡាយជាអនត្តា វិញ្ញាណជាអនត្តា ។ កាលអរិយសាវកឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[ ១១១ ] ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា អនត្តធម៌ អនត្តធម៌ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាអនត្តធម៌ ។ ម្នាលរាធៈ រូបជាអនត្តធម៌ វេទនាជាអនត្តធម៌ សញ្ញាជាអនត្តធម៌ សង្ខារទាំងឡាយជាអនត្តធម៌ វិញ្ញាណជាអនត្តធម៌ ។ កាលអរិយសាវកឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

---

១ មិនមែនខ្លួនប្រាណ មិនមែនជារបស់ខ្លួន ឥតខ្លឹមសារ ។

(១១២) សាវត្ថិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច ខយធម្មោ ខយធម្មោតិ ភន្តេ វុច្ចតិ កតមោ នុ ខោ ភន្តេ ខយធម្មោតិ ។ រូបំ ខោ រាធ ខយធម្មោ វេទនា ខយធម្មោ សញ្ញា ខយធម្មោ សង្ខារា ខយធម្មោ វិញ្ញាណំ ខយធម្មោ ។ ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(១១៣) សាវត្ថិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច វយធម្មោ វយធម្មោតិ ភន្តេ វុច្ចតិ កតមោ នុ ខោ ភន្តេ វយធម្មោតិ ។ រូបំ ខោ រាធ វយធម្មោ វេទនា វយធម្មោ សញ្ញា វយធម្មោ សង្ខារា វយធម្មោ វិញ្ញាណំ វយធម្មោ ។ ឯវំ បស្សំ ។បេ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[ ១១២ ] ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា ខយធម៌ ខយធម៌(១) ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាខយធម៌ ។ ម្នាលរាធៈ រូបជាខយធម៌ វេទនាជាខយធម៌ សញ្ញាជាខយធម៌ សង្ខារទាំងឡាយជាខយធម៌ វិញ្ញាណជាខយធម៌ ។ កាលអរិយសាវកឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[ ១១៣ ] ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា វយធម៌ វយធម៌(២) ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាវយធម៌ ។ ម្នាលរាធៈ រូបជាវយធម៌ វេទនាជាវយធម៌ សញ្ញាជាវយធម៌ សង្ខារទាំងឡាយជាវយធម៌ វិញ្ញាណជាវយធម៌ ។ កាលអរិយសាវកឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

---

១ ធម៌ដែលអស់ទៅ ។ ២ ធម៌ដែលវិនាសទៅ សូន្យទៅ ។

(១១៤) សាវត្ថិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច សមុទយធម្មោ សមុទយធម្មោតិ ភន្តេ វុច្ចតិ កតមោ នុ ខោ ភន្តេ សមុទយធម្មោតិ ។ រូបំ ខោ រាធ សមុទយធម្មោ វេទនា សមុទយធម្មោ សញ្ញា សមុទយធម្មោ សង្ខារា សមុទយធម្មោ វិញ្ញាណំ សមុទយធម្មោ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

(១១៥) សាវត្ថិ ។ អថខោ អាយស្មា រាធោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច និរោធធម្មោ និរោធធម្មោតិ ភន្តេ វុច្ចតិ កតមោ នុ ខោ ភន្តេ និរោធធម្មោតិ ។ រូបំ ខោ រាធ និរោធធម្មោ ។ វេទនា ។ សញ្ញា ។ សង្ខារា និរោធធម្មោ

(១១៨) ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលហៅថា សមុទយធម៌ សមុទយធម៌[១] ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន អ្វីហ្ន៎ ជាសមុទយធម៌ ។ ម្នាលរាធៈ រូបជាសមុទយធម៌ វេទនាជាសមុទយធម៌ សញ្ញាជាសមុទយធម៌ សង្ខារទាំងឡាយជាសមុទយធម៌ វិញ្ញាណជាសមុទយធម៌ ។ កាលអរិយសាវ័កឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

(១១៩) ក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរាធៈមានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាធៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលហៅថា និរោធធម៌ និរោធធម៌[២] ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន អ្វីហ្ន៎ ជានិរោធធម៌ ។ ម្នាលរាធៈ រូបជានិរោធធម៌ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ជានិរោធធម៌

១ ធម៌ដែលនាំឱ្យកើតឡើង ។ ២ ធម៌ដែលរលត់ទៅ ។

វិញ្ញាណំ និរោធធម្មោ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

មារធម្មវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

មារោ ច មារធម្មោ ច
អនិច្ចេហិ អបរេ ទុវេ(១)
ទុក្ខេហិ ច ទ្វេ វុត្តា
អនត្តេហិ តថេវ ច
ខយវយសមុទយំ
និរោធធម្មេន ទ្វាទសាតិ ។

១ ឱ. ម. បរេ ទុវេ ។

វិញ្ញាណជានិរោធធម៌ ៗ កាលអរិយសាវ័កឃើញយ៉ាងនេះ ៗ បេ ៗ ក៏ដឹងច្បាស់ថា មគ្គការនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ៗ

ចប់ មារធម្មវគ្គ ទី ២ ។

## ឧទ្ទាននៃមារធម្មវគ្គនោះ គឺ

សំដែងអំពីមារ ១ មារធម៌ ១ អនិច្ចៈ ២ លើក ទុក្ខៈ ២ លើក អនត្តា ២ លើក ខយធម៌ ១ វយធម៌ ១ សមុទយធម៌ ១ និរោធធម៌ ១ ត្រូវជា ១២ ៗ

# អាយាចនវគ្គោ

[១១៦] សាវត្ថី ។ អថខោ អាយស្មា រាធោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ យោ ខោ រាធ មារោ តត្រ តេ ឆន្ទោ បហាតព្វោ ។ កោ ច រាធ មារោ ។ រូបំ ខោ រាធ មារោ តត្រ តេ ឆន្ទោ បហាតព្វោ វេទនា មារោ តត្រ តេ ឆន្ទោ បហាតព្វោ ។ សញ្ញា ។ សង្ខារា មារោ តត្រ តេ ឆន្ទោ បហាតព្វោ ។ វិញ្ញាណំ មារោ តត្រ តេ ឆន្ទោ បហាតព្វោ ។

# អាយាចនវគ្គ

[១១៦] ក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរាធៈ មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរ ហើយក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ នឹងចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ព្រោះបានស្តាប់ធម៌ណា របស់ព្រះមានព្រះភាគ សូមព្រះមានព្រះភាគសំដែងធម៌នោះ ដល់ខ្ញុំព្រះអង្គដោយសង្ខេប ។ ម្នាលរាធៈ មារណាដែលកើតមាន សេចក្តីពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ ម្នាលរាធៈ ចុះអ្វីជាមារ ។ ម្នាលរាធៈ រូបជាមារ សេចក្តីពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ វេទនាជាមារ សេចក្តីពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ សញ្ញា ។ សង្ខារទាំងឡាយជាមារ សេចក្តីពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ វិញ្ញាណជាមារ សេចក្តីពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ ។

យោ ខោ រាធ មារោ តត្រ តេ ឆន្ទោ បហាតព្ពោ ។ រាគោ បហាតព្ពោ ។ ឆន្ទរាគោ បហាតព្ពោតិ ។

(១១៧) យោ ខោ រាធ មារធម្មោ តត្រ តេ ឆន្ទោ បហាតព្ពោ ។ រាគោ បហាតព្ពោ ។ ឆន្ទរាគោ បហាតព្ពោ ។

(១១៨) យំ ខោ រាធ អនិច្ចំ ។

(១១៩) យោ ខោ រាធ អនិច្ចធម្មោ ។

(១២០) យំ ខោ រាធ ទុក្ខំ ។

(១២១) យោ ខោ រាធ ទុក្ខធម្មោ ។

(១២២) យោ ខោ រាធ អនត្តា ។

(១២៣) យោ ខោ រាធ អនត្តធម្មោ ។

(១២៤) យោ ខោ រាធ ខយធម្មោ ។

(១២៥) យោ ខោ រាធ វយធម្មោ ។

(១២៦) យោ ខោ រាធ សមុទយធម្មោ តត្រ តេ ឆន្ទោ បហាតព្ពោ ។ រាគោ បហាតព្ពោ ។ ឆន្ទរាគោ បហាតព្ពោតិ ។

ម្នាលរាធៈ មារណាដែលកើតមាន សេចក្ដីពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។

( ១១៧ ) ម្នាលរាធៈ មារធម៌ណា ដែលកើតមាន សេចក្ដីពេញចិត្តក្នុងមារធម៌នោះ អ្នកគួរលះបង់ចេញ សេចក្ដីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។

( ១១៨ ) ម្នាលរាធៈ អនិច្ចៈណា ដែលកើតមាន ។

( ១១៩ ) ម្នាលរាធៈ អនិច្ចធម៌ណា ។

( ១២០ ) ម្នាលរាធៈ ទុក្ខណា ។

( ១២១ ) ម្នាលរាធៈ ទុក្ខធម៌ណា ។

( ១២២ ) ម្នាលរាធៈ អនត្តាណា ។

( ១២៣ ) ម្នាលរាធៈ អនត្តធម៌ណា ។

( ១២៤ ) ម្នាលរាធៈ ខយធម៌ណា ។

( ១២៥ ) ម្នាលរាធៈ វយធម៌ណា ។

( ១២៦ ) ម្នាលរាធៈ សមុទយធម៌ណា ដែលកើតមាន សេចក្ដីពេញចិត្តក្នុងសមុទយធម៌នោះ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។

(១២៧) សាវត្ថី ។ អថខោ អាយស្មា រាធោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។ បេ ។ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ យោ ខោ រាធ និរោធធម្មោ តត្រ តេ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ កោ ច រាធ និរោធធម្មោ ។ រូបំ ខោ រាធ និរោធធម្មោ តត្រ តេ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និរោធធម្មោ តត្រ តេ ឆន្ទោ បហាតព្វោ ។

(១២៧) ក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរាធៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ។បេ។ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ នឹងចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ព្រោះបានស្តាប់ធម៌ណា របស់ព្រះមានព្រះភាគ សូមព្រះមានព្រះភាគ សំដែងធម៌នោះដល់ខ្ញុំព្រះអង្គដោយសង្ខេប ។ ម្នាលរាធៈ និរោធធម៌ណា ដែលកើតមាន សេចក្តីពេញចិត្តក្នុងនិរោធធម៌នោះ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។ ម្នាលរាធៈ ចុះអ្វីជានិរោធធម៌ ។ ម្នាលរាធៈ រូបជានិរោធធម៌ សេចក្តីពេញចិត្តក្នុងនិរោធធម៌នោះ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណជានិរោធធម៌ សេចក្តីពេញចិត្តក្នុងនិរោធធម៌នោះ អ្នកគួរលះបង់ចេញ ។

រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ យោ ខោ រាធ និរោធធម្មោ តត្រ តេ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោតិ ។

អាយាចនវគ្គោ តតិយោ ។

## តស្សុទ្ទានំ

មារោ ច មារធម្មោ ច
អនិច្ចេហិ(១) អបរេ ទុវេ
ទុក្ខេហិ ទ្វេ វុត្តា
អនត្តេហិ តថេវ ច
ខយវយសមុទយំ
និរោធធម្មេន ទ្វាទសាតិ ។

---

១ ឱ. ម. អនិច្ចេន ។

សេចក្តីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។ ម្នាលរាធៈ និរោធធម៌ណាដែលកើតមាន សេចក្តីពេញចិត្តក្នុងនិរោធធម៌នោះ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។

ចប់ អាយាចនវគ្គ ទី ៣ ។

## ឧទ្ទានក្នុងអាយាចនវគ្គនោះ គឺ

សំដែងអំពីមារ ១ មារធម៌ ១ អនិច្ចៈ ២ លើក ទុក្ខ ២ លើក អនត្តា ២ លើក ខយធម៌ ១ វយធម៌ ១ សមុទយធម៌ ១ និរោធធម៌ ១ត្រូវជា ១២ ។

# ឧបនិសិន្នវគ្គោ

(១២៨) សាវត្ថី ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ រាធំ ភគវា ឯតទវោច យោ ខោ រាធ មារោ តត្រ តេ ឆន្ទោ បហាតព្វោ ។ កោ ច រាធ មារោ ។ រូបំ ខោ រាធ មារោ តត្រ តេ ឆន្ទោ បហាតព្វោ ។ បេ ។ វិញ្ញាណំ មារោ តត្រ តេ ឆន្ទោ បហាតព្វោ ។ យោ ខោ រាធ មារោ តត្រ តេ ឆន្ទោ បហាតព្វោតិ ។

(១២៩) សាវត្ថី ។ យោ ខោ រាធ មារោ តត្រ តេ រាគោ បហាតព្វោ ។ បេ ។

(១៣០) យោ ខោ រាធ មារោ តត្រ តេ ឆន្ទរាគោ បហាតព្វោ ។

(១៣១) យោ ខោ រាធ មារធម្មោ តត្រ តេ ឆន្ទោ បហាតព្វោ ។

# ឧបនិសិន្នវគ្គ

( ១២៨ ) ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយគង់ទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ ដូច្នេះថា ម្នាលរាធៈ មារណា ដែលកើតមាន សេចក្តីពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ ម្នាលរាធៈ ចុះអ្វីជាមារ ។ ម្នាលរាធៈ រូបជាមារ សេចក្តីពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ បេ ។ វិញ្ញាណជាមារ សេចក្តីពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ ម្នាលរាធៈ មារណា ដែលកើតមាន សេចក្តីពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ ។

( ១២៩ ) ក្រុងសាវត្ថី ។ ម្នាលរាធៈ មារណា ដែលកើតមាន សេចក្តីត្រេកអរក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ បេ ។

( ១៣០ ) ម្នាលរាធៈ មារណា ដែលកើតមាន សេចក្តីត្រេកត្រអាលក្នុងមារនោះ អ្នកគួរលះបង់ចេញ ។

( ១៣១ ) ម្នាលរាធៈ មារធម៌ណា ដែលកើតមាន សេចក្តីពេញចិត្តក្នុងមារធម៌នោះ អ្នកគួរលះបង់ចេញ ។

## រាធសំយុត្ត ឧបនិសិន្នវគ្គោ ចតុត្ថោ

(១៣២) យោ ខោ រាធ មារធម្មោ តត្រ តេ រាគោ បហាតព្វោ ។

(១៣៣) យោ ខោ រាធ មារធម្មោ តត្រ តេ ឆន្ទរាគោ បហាតព្វោ ។

(១៣៤) យំ ខោ រាធ អនិច្ចំ ។

(១៣៥) យោ ខោ រាធ អនិច្ចធម្មោ ។

(១៣៦) យំ ខោ រាធ ទុក្ខំ ។

(១៣៧) យោ ខោ រាធ ទុក្ខធម្មោ ។

(១៣៨) យោ ខោ រាធ អនត្តា ។

(១៣៩) យោ ខោ រាធ អនត្តធម្មោ ។

(១៤០) យោ ខោ រាធ ខយធម្មោ ។

(១៤១) យោ ខោ រាធ វយធម្មោ ។

(១៤២) យោ ខោ រាធ សមុទយធម្មោ តត្រ តេ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោតិ ។

[ ១៣២ ] ម្នាលរាធៈ មារធម៌ណា ដែលកើតមាន សេចក្តីត្រេកអរក្នុងមារធម៌នោះ អ្នកគួរលះបង់ចេញ ។

[ ១៣៣ ] ម្នាលរាធៈ មារធម៌ណា ដែលកើតមាន សេចក្តីត្រេកត្រអាលក្នុងមារធម៌នោះ អ្នកគួរលះបង់ចេញ ។

[ ១៣៤ ] ម្នាលរាធៈ អនិច្ចៈណា ដែលកើតមាន ។

[ ១៣៥ ] ម្នាលរាធៈ អនិច្ចធម៌ណា ។

[ ១៣៦ ] ម្នាលរាធៈ ទុក្ខណា ។

[ ១៣៧ ] ម្នាលរាធៈ ទុក្ខធម៌ណា ។

[ ១៣៨ ] ម្នាលរាធៈ អនត្តាណា ។

[ ១៣៩ ] ម្នាលរាធៈ អនត្តធម៌ណា ។

[ ១៤០ ] ម្នាលរាធៈ ខយធម៌ណា ។

[ ១៤១ ] ម្នាលរាធៈ វយធម៌ណា ។

[ ១៤២ ] ម្នាលរាធៈ សមុទយធម៌ណា ដែលកើតមាន សេចក្តីពេញចិត្តក្នុងសមុទយធម៌នោះ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។

(១៤៣) សាវត្ថី ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ រាធំ ភគវា ឯតទវោច យោ ខោ រាធ និរោធធម្មោ តត្រ តេ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ កោ ច រាធ និរោធធម្មោ ។ រូបំ ខោ រាធ និរោធធម្មោ តត្រ តេ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និរោធធម្មោ តត្រ តេ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ យោ ខោ រាធ និរោធធម្មោ តត្រ តេ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោតិ ។

ឧបនិសិន្នវគ្គោ ចតុត្ថោ ។

[ ១៤៣ ] ក្រុងសាវត្ថី ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ ដូច្នេះថា ម្នាលរាធៈ និរោធធម៌ណាដែលកើតមាន សេចក្ដីពេញចិត្តក្នុងនិរោធធម៌នោះ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។ ម្នាលរាធៈ ចុះអ្វីជានិរោធធម៌ ។ ម្នាលរាធៈ រូបជានិរោធធម៌ សេចក្ដីពេញចិត្តក្នុងនិរោធធម៌នោះ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។ វេទនា ។ សញ្ញា ។ សង្ខារទាំង-ឡាយ ។ វិញ្ញាណជានិរោធធម៌ សេចក្ដីពេញចិត្តក្នុងនិរោធធម៌នោះ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។ ម្នាលរាធៈ និរោធធម៌ណាដែលកើតមាន សេចក្ដីពេញចិត្តក្នុងនិរោធធម៌នោះ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្ដីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។

ចប់ ឧបនិសិន្នវគ្គ ទី ៤ ។

## តត្រុទ្ទានំ

មារោ ច មារធម្មោ ច
អនិច្ចេហិ អបរេ ទុវេ[១]
ទុក្ខេហិ ទ្វេ វុត្តា[២]
អនត្តេហិ អបរេ ទ្វេ[៣]
ខយវយសមុទយំ
និរោធធម្មេន ទ្វាទសាតិ ។

រាធសំយុត្តំ សមត្តំ ។

---

១ ឱ. អនិច្ចា អបរេន ទ្វេ ។ ម. អនិច្ចេន អបរេ ទុវេ ។ ២ ទុក្ខំ ច ទ្វេ វុត្តាតិបិ ។ ៣ ទ្វេ អនត្តេហិ អដ្ឋមន្តិបិ ។

## ឧទ្ទានក្នុងឧបនិសិន្នវគ្គនោះ គឺ

*សម្ដែងអំពីមារ ១ មារធម៌ ១ អនិច្ចៈ ២ លើក ទុក្ខ ២ លើក អនត្តា ២ លើក ខយធម៌ ១ វយធម៌ ១ សមុទយធម៌ ១ និរោធធម៌ ១ ត្រូវជា ១២ ។*

ចប់ រាធសំយុត្ត ។

# ទិដ្ឋិសំយុត្តំ

## សោតាបត្តិវគ្គោ

[១៤៤] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ ។បេ។ ភគវា ឯតទវោច កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ន វាតា វាយន្តិ ន នជ្ជោ សន្ទន្តិ ន គព្ភិនិយោ វិជាយន្តិ ន ចន្ទិមសុរិយា ឧទេន្តិ វា អបេន្តិ វា ឯសិកដ្ឋាយិដ្ឋិតាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តញ្ញេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ ធម្មំ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ

# ទិដ្ឋិសំយុត្ត

## សោតាបត្តិវគ្គ

[ ១៨៤ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី ។ បេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់(១) ស្ទឹងមិនហូរ ស្រីមានគភ៌មិនសម្រាល ព្រះចន្ទព្រះអាទិត្យមិនរះឬមិនលិច តាំងនៅនឹងដដែលដូចជាសសរខឿន ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះមានព្រះភាគជាមូល មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សំដែងសេចក្ដីនៃភាសិតនេះ ពួកភិក្ខុបានស្ដាប់ធម៌របស់ព្រះមានព្រះភាគហើយ នឹងចាំទុក ។ ម្នាលភិក្ខុ

---

១ សេចក្ដីយល់ឃើញផ្សេងថា ខ្យល់ដែលបក់បំបាក់រំលើងរុក្ខជាតិជាដើម មិនមែនជាខ្យល់មែនទែនទេ ហៅថា វាតលេស គឺគ្រាន់តែជាសំអាងរបស់ខ្យល់ ឯខ្យល់មែនទែននោះឋិតនៅនឹងថ្កល់ដូចជាសសរគោលឬកំពូលភ្នំ ។ ស្ទឹង ស្រីមានគ័ភ៌ និងព្រះចន្ទព្រះអាទិត្យក៏មានន័យដូចគ្នាដែរ ។

សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ន វាតា វាយន្តិ ន នជ្ជោ សន្ទន្តិ ន គព្ភិនិយោ វិជាយន្តិ ន ចន្ទិមសុរិយា ឧទេន្តិ វា អបេន្តិ វា ឯសិកដ្ឋាយិដ្ឋិតា ។ វេទនាយ សតិ ។ បេ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ន វាតា វាយន្តិ ន នជ្ជោ សន្ទន្តិ ន គព្ភិនិយោ វិជាយន្តិ ន ចន្ទិមសុរិយា ឧទេន្តិ វា អបេន្តិ វា ឯសិកដ្ឋាយិដ្ឋិតា ។

(១៤៥) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ ន វាតា វាយន្តិ ន នជ្ជោ សន្ទន្តិ

ទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ស្ទឹងមិនហូរ ស្រីមានគភ៌មិនសម្រាល ព្រះចន្ទព្រះអាទិត្យមិនរះឬមិនលិច តាំងនៅនឹងដដែលដូចជាសសរខឿន ។ កាលបើវេទនាមាន ។ បេ ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ស្ទឹងមិនហូរ ស្រីមានគភ៌មិនសម្រាល ព្រះចន្ទព្រះអាទិត្យមិនរះឬមិនលិច តាំងនៅនឹងដដែលដូចជាសសរខឿន ។

[ ១៦៥ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ស្ទឹងមិនហូរ

ន គព្ភិនិយោ វិជាយន្តិ ន ចន្ទិមសុរិយា ឧទេន្តិ វា អបេន្តិ វា ឯសិកដ្ឋាយិដ្ឋិតាតិ ។ នោ ហេតំ ភន្តេ ។ វេទនា និច្ចា វា អនិច្ចា វាតិ ។បេ។ សញ្ញា ។ សង្ខារា និច្ចា វា អនិច្ចា វាតិ ។បេ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ ន វាតា វាយន្តិ ន នជ្ជោ សន្ទន្តិ ន គព្ភិនិយោ វិជាយន្តិ ន ចន្ទិមសុរិយា ឧទេន្តិ វា អបេន្តិ វា ឯសិកដ្ឋាយិដ្ឋិតាតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ

ស្រីមានគភ៌មិនសម្រាល ព្រះចន្ទព្រះអាទិត្យមិនរះឬមិនលិច តាំងនៅនឹងដែលដូចជាសសរខឿនដែរឬ ៗ មិនមែនដូច្នោះទេ ព្រះអង្គ ។ វេទនាទៀង ឬមិនទៀង ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយទៀង ឬមិនទៀង ។ បេ ។ វិញ្ញាណទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ស្ទឹងមិនហូរ ស្រីមានគភ៌មិនសម្រាល ព្រះចន្ទព្រះអាទិត្យមិនរះឬមិនលិច តាំងនៅនឹងដែលដូចជាសសរខឿនដែរឬ ៗ មិនមែនដូច្នោះទេ ព្រះអង្គ ។ ចុះរបស់ណាដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ(១) បានដឹងច្បាស់(២) បានដល់ បានស្វែងរក បានពិចារណារឿយៗដោយចិត្ត របស់នោះទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា

---

១ ពាក្យថា ពាល់ត្រូវ គឺធុំក្លិនដោយច្រមុះ ក្រេបជញ្ជាប់ដោយអណ្តាត ប៉ះពាល់ដោយកាយ ។ ២ ពាក្យថា ដឹងច្បាស់ គឺយល់ប្រាកដដោយចិត្ត ។

ន វាតា វាយន្តិ ន នជ្ជោ សន្ទន្តិ ន គព្ភិនិយោ វិជាយន្តិ ន ចន្ទិមសុរិយា ឧទេន្តិ វា អបេន្តិ វា ឯសិកដ្ឋាយិដ្ឋិតាតិ ។ នោ ហេតំ ភន្តេ ។ យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមេសុ ឆសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា បហីនា ហោតិ ទុក្ខសមុទយេបិស្ស កង្ខា បហីនា ហោតិ ទុក្ខនិ-រោធេបិស្ស កង្ខា បហីនា ហោតិ ទុក្ខនិរោធគា-មិនិយា បដិបទាយបិស្ស កង្ខា បហីនា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិ-និបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(១៤៦) សាវត្ថី ។ កស្មិំ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបា-ទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ឯតំ មម

ខ្យល់មិនបក់ ស្ទឹងមិនហូរ ស្រីមានគភ៌មិនសម្រាល ព្រះចន្ទព្រះអាទិត្យ មិនរះឬមិនលិច តាំងនៅនឹងដែលដូចជាសសរខឿនដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវក លះបង់សេចក្តីសង្ស័យ ក្នុងឋានទាំង ៦ នេះ បានហើយ សេចក្តីសង្ស័យក្នុងទុក្ខ អរិយសាវកនោះ ក៏លះបង់បាន សេចក្តីសង្ស័យក្នុងហេតុនាំឲ្យកើតទុក្ខ អរិយសាវកនោះ ក៏លះបង់បាន សេចក្តីសង្ស័យក្នុងការរលត់ទុក្ខ អរិយសាវកនោះ ក៏លះបង់បាន សេចក្តីសង្ស័យក្នុងបដិបទាជាដំណើរទៅកាន់ការរលត់ទុក្ខ អរិយសាវកនោះ ក៏លះបង់បាន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកនេះ ហៅថា សោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

( ១៤៦ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា នុ៎ះរបស់អញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា នុ៎ះរបស់

ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ វេទនាយ សតិ ។បេ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។

(១៤៧) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ។បេ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ

អញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ កាលបើវេទនាមាន ។ បេ ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា នុ៎ះរបស់អញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។

(១៤៧) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា នុ៎ះរបស់អញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀង ឬមិនទៀង ។ មិនទៀងទេ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា នុ៎ះរបស់អញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ របស់ណាដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់

បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តំបិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមេសុ ឆសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា បហីនា ហោតិ ។បេ។ ទុក្ខនិរោធគាមិនិយា បដិបទាយបិស្ស កង្ខា បហីនា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

បានដល់ បានស្វែងរក បានពិចារណារឿយៗដោយចិត្ត របស់នោះទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា ដែលមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា នុ៎ះរបស់អញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវ័កលះបង់សេចក្តីសង្ស័យក្នុងឋានទាំង ៦ នេះបានហើយ សេចក្តីសង្ស័យក្នុងទុក្ខ អរិយសាវ័កនោះក៏លះបង់បាន ។ បេ ។ សេចក្តីសង្ស័យក្នុងបដិបទាជាដំណើរទៅកាន់ការរលត់ទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះ ហៅថា សោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(២៤៨) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ សោ អត្តា សោ លោកោ សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ សោ អត្តា ។បេ។ អវិបរិណាមធម្មោ វេទនាយ សតិ ។បេ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ សោ អត្តា សោ លោកោ សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ ។

[ ១៤៨ ] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា អត្តាអញ្ញនោះជាខ្លួន អត្តាអញ្ញនោះជាលោក អត្តាអញ្ញនោះ លុះទៅកាន់បរលោកហើយ នឹងទៀងទាត់ ឋិតថេរ មិនប្រែប្រួលទៅជាធម្មតា ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយរបស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើង យ៉ាងនេះថា អត្តាអញ្ញនោះជាខ្លួន ។ បេ ។ មិនប្រែប្រួលទៅជាធម្មតា កាលបើវេទនាមាន ។ បេ ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា អត្តាអញ្ញនោះជាខ្លួន អត្តាអញ្ញនោះជាលោក អត្តាអញ្ញនោះ លុះទៅកាន់បរលោកហើយ នឹងទៀងទាត់ ឋិតថេរ មិនប្រែប្រួលទៅជាធម្មតា ។

ទិដ្ឋិសំយុត្តេ សោតាបត្តិវគ្គោ បឋមោ

[១៤៩] តំ កិំ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សោ អត្តា ។ បេ ។ អវិបរិណាមធម្មោតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សោ អត្តា ។ បេ ។ អវិបរិណាមធម្មោតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តំបិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ។បេ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សោ អត្តា សោ លោកោ សោ បេច្ច ភវិស្សាមិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោតិ ។ នោ ហេតំ ភន្តេ ។ យតោ ខោ ភិក្ខវេ

(១៨៩) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា អាត្មាអញនោះជាខ្លួន ។ បេ ។ មានសភាពមិនប្រែប្រួលទៅដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា អាត្មាអញនោះជាខ្លួន ។ បេ ។ មានសភាពមិនប្រែប្រួលទៅដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ របស់ណាដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ បានដល់ បានស្វែងរក បានពិចារណារឿយ ៗ ដោយចិត្ត របស់នោះទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាដែលមិនទៀង ។ បេ ។ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា អាត្មាអញនោះជាខ្លួន អាត្មាអញនោះជាលោក អាត្មាអញនោះ លុះទៅកាន់បរលោកហើយ នឹងទៀងទាត់ ឋិតថេរ មិនប្រែប្រួលទៅជាធម្មតាដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើ

អរិយសាវកស្ស ឥមេសុ ចតូសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា បហីនា ហោតិ ។ បេ ។ ទុក្ខនិរោធគាមិនិយា បដិបទាយបិស្ស កង្ខា បហីនា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(១៨០) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ(១) ន មេ ភវិស្សតីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ។ វេទនាយ សតិ ។ សញ្ញាយ សតិ ។

---

១ ឱ. ន ភវិស្សាមិ ។ ម. នាភវិស្សំ ។

អរិយសាវ័កលះបង់សេចក្ដីសង្ស័យក្នុងឋានៈទាំង ៦ នេះបានហើយ សេចក្ដីសង្ស័យក្នុងទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។ បេ ។ សេចក្ដីសង្ស័យក្នុងបដិបទាជាដំណើរទៅកាន់សេចក្ដីរលត់ទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះ ហៅថាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៩០) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា បើអាត្មាអញនឹងមិនកើតទេ (បរិក្ខារ) របស់អាត្មាអញ ក៏នឹងមិនមាន (បើកម្មសង្ខារជាទីញុំាងខន្ធឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញ ក៏នឹងមិនមានដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយ របស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា បើអាត្មាអញនឹងមិនកើតទេ (បរិក្ខារ) របស់អាត្មាអញ ក៏នឹងមិនមាន (បើកម្មសង្ខារជាទីញុំាងខន្ធឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញ នឹងមិនមានដែរ ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។

សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ។

(១៨១) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ

កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើង យ៉ាងនេះថា បើអាត្មាអញនឹងមិនកើតទេ (បរិក្ខារ) របស់អាត្មាអញ នឹងមិនមាន (បើកម្មសង្ខារជាទីញុំាងខ្លួនឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញ នឹងមិនមានដែរ ។

(១៩១) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា បើអាត្មាអញនឹងមិនកើតទេ (បរិក្ខារ) របស់អាត្មាអញ ក៏នឹងមិនមាន (បើកម្មសង្ខារជាទីញុំាងខ្លួនឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញ នឹងមិនមានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ ទៀង

វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ។បេ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តំបិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សតិ ន មេ ភវិស្សតីតិ ។ នោ ហេតំ ភន្តេ ។ យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមេសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា បហីនា ហោតិ ។បេ។ ទុក្ខនិរោធគាមិនិយា បដិបទាយបិស្ស កង្ខា បហីនា ហោតិ ។

ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ។ បេ ។ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើង យ៉ាងនេះថា បើអាត្មាអញនឹងមិនកើតទេ (បរិក្ខារ) របស់អាត្មាអញ ក៏នឹងមិនមាន (បើកម្មសង្ខារជាទីញុំាងខន្ធឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញ នឹងមិនមានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ របស់ណាដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ បានដល់ បានស្វែងរក បានពិចារណារឿយៗ ដោយចិត្ត របស់នោះ ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើង យ៉ាងនេះថា បើអាត្មាអញនឹងមិនកើតទេ (បរិក្ខារ) របស់អាត្មាអញ ក៏នឹងមិនមាន (បើកម្មសង្ខារជាទីញុំាងខន្ធឲ្យកើតក្នុងអនាគត) នឹងមិនមានទេ (បដិសន្ធិក្នុងអនាគត) របស់អាត្មាអញ នឹងមិនមានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវ័ក លះបង់សេចក្តីសង្ស័យ ក្នុងឋានទាំង ៦ នេះបានហើយ សេចក្តីសង្ស័យក្នុងទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។ បេ ។ សេចក្តីសង្ស័យក្នុងបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។

អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(១៥២) សាវត្ថិ ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កិំ ឧបាទាយ កិំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរលោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបា-តិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ ចាតុម្មហាភូតិ-កោយំ បុរិសោ យទា កាលំ ករោតិ បឋវី បឋវី-កាយំ អនុបេតិ អនុបគច្ឆតិ អាបោ អាបោកាយំ អនុបេតិ អនុបគច្ឆតិ តេជោ តេជោកាយំ អនុបេតិ អនុបគច្ឆតិ វាយោ វាយោកាយំ អនុបេតិ អនុបគច្ឆតិ

ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះ ហៅថា សោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

( ១៥២ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលនិងវិបាកនៃកម្មល្អនិងអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមាន(១) បិតាមិនមាន (២) សត្វទាំងឡាយជាឧបបាតិកៈមិនមាន សមណៈនិងព្រាហ្មណ៍ណា ដែលបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង បំពោះលោកនេះនិងលោកខាងមុខ ហើយអាចនឹងប្រកាសបាន សមណព្រាហ្មណ៍នោះ ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិល្អ មិនមានក្នុងលោកឡើយ បុរសនេះ មានកាយប្រកបដោយមហាភូតរូបទាំង ៤ កាលណាបើធ្វើមរណកាលទៅ បឋវីធាតុខាងក្នុង ក៏ប្រែក្លាយទៅជាបឋវីធាតុខាងក្រៅ អាបោធាតុខាងក្នុងក៏ប្រែក្លាយទៅជាអាបោធាតុខាងក្រៅ តេជោធាតុខាងក្នុងក៏ប្រែក្លាយទៅជាតេជោ-ធាតុខាងក្រៅ វាយោធាតុខាងក្នុងក៏ប្រែក្លាយទៅជាវាយោធាតុខាងក្រៅ

១ សេចក្តីប្រតិបត្តិល្អ ឬ អាក្រក់បំពោះមាតា មិនមានផលបុណ្យ ឬ បាប ។ ២ បំណែកបិតា ក៏ដូចគ្នា ។

អាកាសំ ឥន្ទ្រិយានិ សង្កមន្តិ អាសន្ទិបញ្ចមា បុរិសា មតំ អាទាយ គច្ឆន្តិ យាវ អាឡាហនា(១) បទានិ បញ្ញាយន្តិ កាបោតកានិ អដ្ឋីនិ ភវន្តិ ភស្សន្តា(២) អាហុតិយោ ទត្តុបញ្ញត្តំ យទិទំ ទានំ តេសំ តុច្ឆំ មុសា វិលាបោ យេ កេចិ អត្ថិកវាទំ វទន្តិ ពាលេ ច បណ្ឌិតេ ច កាយស្ស ភេទា ឧច្ឆិជ្ជន្តិ វិនស្សន្តិ ន ហោន្តិ បរម្មរណាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។ បេ ។ កាយស្ស ភេទា ឧច្ឆិជ្ជន្តិ វិនស្សន្តិ ន ហោន្តិ បរម្មរណា ។ វេទនាយ សតិ ។ បេ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស

---

១ ឱ. អាឡាហនា បទានិ ។ ម. អាឡហនា ។ ២ ភស្មន្តាហុតិយោតិបិ បាឋោ ។

ឥន្ទ្រិយក៏អណ្តែតទៅឰដ៏អាកាស បុរស (៤ នាក់) មានគ្រែជាគម្រប់ ៥ សែងយកបុរសដែលស្លាប់ ហើយទៅត្រាតែដល់ទីប៉ាឆា បំណែកគុណ និងផេះសក៏ប្រាកដឡើង ឆ្អឹងមានសម្បុរដូចជាកូនព្រាប គ្រឿងបូជាមានផេះជាទីបំផុត ទានទេះ មនុស្សខ្លៅបានបញ្ញត្តទុកមកហើយ ជនទាំងឡាយណានីមួយ ទាំងពាលទាំងបណ្ឌិត តែងពោលពាក្យថា ទានមានផល ពាក្យរបស់ជនទាំងនោះ ជាពាក្យកុហកទទេ ជនទាំងនោះលុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏សូន្យទទេមិនកើតទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ។ បេ ។ ជនទាំងនោះ លុះមានរាងកាយបែកធ្លាយទៅខាងមុខបន្ទាប់អំពីមរណៈ ក៏សូន្យទទេមិនកើតទៀត ។ កាលបើវេទនាមាន ។ បេ ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ

ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។បេ។ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ។

(១៨៣) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។បេ។ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។បេ។ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ

ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំមិនមានផល ។ បេ ។ ជនទាំងនោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏សូន្យទេ មិនកើតទៀត ។

( ១៥៣ ) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ។បេ។ ជនទាំងនោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏សូន្យទេ មិនកើតទៀតដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំមិនមានផល ។ បេ ។ ជនទាំងនោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏សូន្យទេ មិនកើតទៀតដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ របស់ណាដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ បានដល់ បានស្វែងរក បានពិចារណារឿយ ៗ

មនសា តំបិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។ បេ ។ យេ កេចិ អត្ថិកវាទំ វទន្តិ ពាលេ ច បណ្ឌិតេ ច កាយស្ស ភេទា ឧច្ឆិជ្ជន្តិ វិនស្សន្តិ ន ហោន្តិ បរម្មរណាតិ ។ នោ ហេតំ ភន្តេ ។ យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមេសុ ឆសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា បហីនា ហោតិ ។ បេ ។ ទុក្ខនិរោធគាមិនិយា បដិបទាយបិស្ស កង្ខា បហីនា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។

ដោយចិត្ត របស់នោះ ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើង យ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ។ បេ ។ ជនទាំងឡាយណាមួយ ទាំងពាលទាំងបណ្ឌិត តែងពោលពាក្យថា ទានមានផល ជនទាំងនោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខ បន្ទាប់អំពីមរណៈ ក៏សូន្យទេ មិនកើតទៀតដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវ័កលះបង់សេចក្តីសង្ស័យក្នុងឋានទាំង ៦ នេះបានហើយ សេចក្តីសង្ស័យក្នុងទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។ បេ ។ សេចក្តីសង្ស័យក្នុងបដិបទាជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះ ហៅថាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៩៤) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ករោតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បចាបយតោ(១) សោចតោ សោចាបយតោ កិលមតោ កិលមាបយតោ ផន្ទតោ ផន្ទាបយតោ បាណមតិបាតាបយតោ អទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា ភណតោ ករោតោ ន ករីយតិ បាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បឋវិយា បាណេ ឯកំ មំសខលំ ឯកំ មំសបុញ្ជំ ករេយ្យ នត្ថិ តតោនិទានំ បាបំ នត្ថិ បាបស្ស អាគមោ ទក្ខិណញ្ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ

---

១ ឱ. វធតោ វធាបយតោ ។

(១៥៤) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វី ហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ កាត់ (នូវអវយវៈមានដៃជាដើម) របស់អ្នកដទៃដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យបៀតបៀន សោយសោកដោយខ្លួនឯង ឬញុំាងអ្នកដទៃឲ្យសោយសោក លំបាកដោយខ្លួនឯង ឬញុំាងអ្នកដទៃឲ្យលំបាក ញាប់ញ័រដោយខ្លួនឯង ឬធ្វើគេឲ្យញាប់ញ័រ សម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់នូវទីត ប្លន់អ្នកស្រុក ប្លន់យកទ្រព្យតែផ្ទះមួយ ចាំស្ទាក់ផ្លូវ លួចប្រពន្ធអ្នកដទៃ ពោលពាក្យកុហក បាបរបស់បុគ្គលអ្នកធ្វើនោះមិនមានឡើយ មួយវិញទៀត បើបុគ្គលណាធ្វើនូវសត្វទាំងឡាយលើផែនដីនេះ ឲ្យមានលាននៃសាច់តែ ១ ឲ្យមានគំនរនៃសាច់តែ ១ ដោយគ្រឿងចក្រមានខ្នងកង់ដ៏មុតដូចជាមុខកាំបិតកោរ បាបរបស់បុគ្គលនោះមិនមាន ព្រោះអំពើនោះជាហេតុ បាបមិនមានមកឡើយ ទោះបីបុគ្គលនោះ ឆ្លងទៅកាន់ត្រើយខាងស្តាំនៃទន្លេគង្គា ហើយសម្លាប់សត្វដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់ (នូវអវយវៈមានដៃជាដើម) ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនខ្លួនឯង

បចាបេន្តោ នត្ថិ តតោនិទានំ បាបំ នត្ថិ បាបស្ស អាគមោ ឧត្តរញ្ចេបិ គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទាបេន្តោ យជន្តោ យជាបេន្តោ នត្ថិ តតោនិទានំ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោ ទានេន ទមេន សំយមេន សច្ចវជ្ជេន នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ការតោ ការយតោ ។បេ។ នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោ ។ វេទនាយ សតិ ។បេ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ការតោ ការយតោ ។បេ។ នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោ ។

ឬប្រើអ្នកដទៃឲ្យបៀតបៀន បាបរបស់បុគ្គលនោះមិនមាន ព្រោះអំពើនោះជាហេតុ បាបមិនមានមកឡើយ ទោះបីបុគ្គលនោះ ធ្វើទៅកាន់ត្រើយខាងត្បូងនៃទន្លេគង្គា ឲ្យទានដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យឲ្យ បូជាដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យបូជា បុណ្យរបស់បុគ្គលនោះមិនមាន ព្រោះអំពើនោះជាហេតុ បុណ្យមិនមានមកឡើយ បុណ្យមិនមានដោយទាន ដោយទូន្មាននូវឥន្ទ្រិយ ដោយសង្រួមកាយ វាចា ដោយពោលពាក្យសច្ចៈ បុណ្យមិនមានមកឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ របស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។បេ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា បុគ្គលកាលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ ។បេ។ បុណ្យមិនមាន បុណ្យមិនមានមកឡើយ ។ កាលបើវេទនាមាន ។បេ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ ។បេ។ បុណ្យមិនមាន បុណ្យមិនមានមកឡើយ ។

(១៨៨) តំ កិំ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ ករោតោ ការយតោ ។ បេ ។ នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ ករោតោ ការយតោ ។ បេ ។ នត្ថិ បុញ្ញស្ស អាគមោតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ ករោតោ ការយតោ ។ បេ ។ នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។

(១៥៥) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ មានសភាពប្រែប្រួលទៅ ចុះបើមិនអាស្រ័យនូវរបស់នោះ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ ។ បេ ។ បុណ្យមិនមាន បុណ្យមិនមានមកឡើយ ដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ ។ បេ ។ បុណ្យមិនមានមកឡើយដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ របស់ណាដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ បានដល់ បានស្វែងរក បានពិចារណារឿយៗដោយចិត្ត របស់នោះទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ ។ បេ ។ បុណ្យមិនមាន បុណ្យមិនមានមកឡើយដែរឬ ។

ធោ ហោតិ ភន្តេ ។ យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមេសុ ឆសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា បហីនា ហោតិ ។បេ។ ទុក្ខនិរោធគាមិនិយា បដិបទាយបិស្ស កង្ខា បហីនា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(១៥៦) សាវត្ថី ។ កឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ អហេតូ អប្បច្ចយា សត្តា សង្កិលិស្សន្តិ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ វិសុទ្ធិយា អហេតូ អប្បច្ចយា សត្តា វិសុជ្ឈន្តិ នត្ថិ ពលំ នត្ថិ វីរិយំ នត្ថិ បុរិសត្ថាមោ នត្ថិ បុរិសបរក្កមោ សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា

មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើ អរិយសាវ័កលះបង់សេចក្ដីសង្ស័យក្នុងឋានទាំង ៦ នេះបានហើយ សេចក្ដីសង្ស័យក្នុងទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។បេ។ សេចក្ដីសង្ស័យក្នុងបដិបទា ជាដំណើរទៅកាន់សេចក្ដីរលត់ទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះ ហៅថាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៩៦) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វី ហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ហេតុបច្ច័យដែលនាំឲ្យសៅហ្មងនៃសត្វទាំងឡាយ មិនមានឡើយ សត្វទាំង-ឡាយរមែងសៅហ្មង ដោយឥតហេតុឥតបច្ច័យ ហេតុបច្ច័យដែលនាំឲ្យបរិសុទ្ធនៃសត្វទាំងឡាយ មិនមានឡើយ សត្វទាំងឡាយរមែងបរិសុទ្ធ ដោយឥតហេតុឥតបច្ច័យ កម្លាំងក៏មិនមាន ព្យាយាមក៏មិនមាន កម្លាំងរបស់បុរសក៏មិនមាន សេចក្ដីស្វាតរបស់បុរស ក៏មិនមាន សត្វទាំងអស់ (មានឧដ្ឋ គោ លា ជាដើម) បាណៈទាំងអស់[១] ភូតទាំងអស់

១ សត្វដែលមានឥន្ទ្រិយ ១ គឺរូបជីវិតិន្ទ្រិយ បានដល់អសញ្ញីសត្វ សត្វដែលមានឥន្ទ្រិយ ២ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ បានដល់រូបព្រហ្ម ១៤ ជាន់ វៀរលែងអសញ្ញីព្រហ្មចេញ ។

សព្វេ ជីវា អវសា អពលា អវីរិយា និយតិសង្គតិភា-
វបរិណតា ឆស្វេវាភិជាតីសុ សុខទុក្ខំ បដិសំវេទេន្តី-
តិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ រូបេ ខោ
ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ
ឧប្បជ្ជតិ នត្ថិ ហេតុ នត្ថិ បច្ចយោ ។ បេ ។ សុខទុក្ខំ
បដិសំវេទេន្តីតិ ។ វេទនាយ សតិ ។ បេ ។ សញ្ញាយ
សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ
ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នត្ថិ
ហេតុ នត្ថិ បច្ចយោ ។ បេ ។ សុខទុក្ខំ បដិសំវេទេន្តីតិ ។

(មានសត្វកើតក្នុងស្រោមស៊ុតជាដើម) ជីវៈទាំងអស់ គឺជញ្ញាជាតិ ឥតមានអំណាច ឥតមានកម្លាំង ឥតមានសេចក្តីព្យាយាម (ក្នុងការធ្វើឲ្យសៅហ្មង ឬ បរិសុទ្ធ) មានសេចក្តីប្រែប្រួលដោយនិយតិ និងសង្គតិ និងសភាវៈ(១) តាំងនៅក្នុងអភិជាតិទាំង ៦ ហើយរងនូវសេចក្តីសុខនិងទុក្ខ យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។បេ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ហេតុបច្ច័យមិនមានឡើយ ។បេ។ តែងរងនូវសេចក្តីសុខនិងទុក្ខ ។ កាលបើវេទនាមាន ។បេ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ហេតុបច្ច័យមិនមានឡើយ ។បេ។ តែងរងនូវសេចក្តីសុខនិងទុក្ខ ។

---

១ សេចក្តីជិតស្និទ្ធមិនបែកធ្លាយ ដូចដុំកែវមណីដែលមិនប្រេះឆា ឈ្មោះថានិយតិ ។ ការត្រាច់រង្គាត់ទៅក្នុងអភិជាតិទាំង ៦ ឈ្មោះថាសង្គតិ ។ ធម្មតាដែលបានកើតឡើងដូចៗគ្នា ឈ្មោះថាសភាវៈ ដូចបន្លាដែលស្រួចឯង ផ្លែទទឹមមានសណ្ឋានមូលដោយខ្លួនឯង សត្វម្រឹគបក្សីទាំងពួង មានរូបរាងវិចិត្រផ្សេងៗ ដោយធម្មតាឯង យ៉ាងណាមិញ លោកទាំងអស់មានសេចក្តីប្រែប្រួលទៅជាដូច្នោះៗ មិនបាច់អាស្រ័យហេតុបច្ច័យឡើយ ដូចបន្លាជាដើម យ៉ាងនោះឯង ឈ្មោះថាសភាវៈ ។

(១៥៧) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នត្ថិ ហេតុ នត្ថិ បច្ចយោ ។ បេ ។ សុខទុក្ខំ បដិសំវេទេន្តីតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នត្ថិ ហេតុ នត្ថិ បច្ចយោ ។ បេ ។ សុខទុក្ខំ បដិសំវេទេន្តីតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តំបិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នត្ថិ ហេតុ នត្ថិ បច្ចយោ ។ បេ ។ សុខទុក្ខំ បដិសំវេទេន្តីតិ ។ នោ ហេតំ ភន្តេ ។ យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមេសុ ឆសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា

(១៩៧) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ មានសភាពប្រែប្រួលទៅ ចុះបើមិនអាស្រ័យនូវរបស់នោះ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា ហេតុបច្ច័យមិនមាន ។ បេ ។ តែងវេងនូវសេចក្តីសុខនិងទុក្ខដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា ហេតុបច្ច័យមិនមាន ។ បេ ។ តែងវេងនូវសេចក្តីសុខនិងទុក្ខ ដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ របស់ណា ដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ បានដល់ បានស្វែងរក បានពិចារណារឿយ ៗ ដោយចិត្ត របស់នោះទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា ហេតុបច្ច័យមិនមាន ។ បេ ។ តែងវេងនូវសេចក្តីសុខនិងទុក្ខ ដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវ័កលះបង់សេចក្តីសង្ស័យក្នុងឋានទាំង ៦ នេះបានហើយ សេចក្តីសង្ស័យក្នុងទុក្ខ អរិយ-

បហីនា ហោតិ ។បេ។ ទុក្ខនិរោធគាមិនិយា បដិប-
ទាយបិស្ស កង្ខា បហីនា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ
អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ
សម្ពោធិបរាយណោតិ ។

(១៥៨) សាវត្ថី ។ តស្មិំ នុ ខោ ភិក្ខវេ សតិ
កិំ ឧបាទាយ កិំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជ-
តិ សត្តិមេ កាយា អកដា អកដវិធា អនិម្មិតា
អនិម្មិតវិធា(១) វញ្ឈា កូដដ្ឋា ឯសិកដ្ឋាយិដ្ឋិតា តេ
ន ឥញ្ជន្តិ ន វិបរិណាមន្តិ(២) ន អញ្ញមញ្ញំ ព្យាធេន្តិ(៣)
នាលំ អញ្ញមញ្ញស្ស សុខាយ វា ទុក្ខាយ វា កត-
មេ សត្ត ។ បឋវីកាយោ អាបោកាយោ តេជោកា-
យោ វាយោកាយោ សុខេ ទុក្ខេ ជីវេ ។ សត្តិមេ
កាយា អកដា អកដវិធា អនិម្មិតា អនិម្មិតវិធា

---

១ ឱ. អនិម្មាតា ។ ២ ឱ. ម. ន វិបរិណាមេន្តិ ។ ៣ ឱ. ព្យាពាធេន្តិ ។ ម. ព្យាបាទេន្តិ ។

សាវ័កនោះ ក៏លះបង់បាន ។បេ។ សេចក្តីសង្ស័យក្នុងបដិបទាជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះ ហៅថា សោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៥៨) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា កាយទាំងនេះ មាន ៧ ប្រការ គ្មានអ្នកធ្វើបាន គ្មានអ្នកបង្គាប់ឲ្យធ្វើបាន គ្មានអ្នកតាក់តែងបាន(១) មិនគប្បីតាក់តែងបាន ជាសភាវៈអារ(២) តាំងនៅដូចជាកំពូលភ្នំ ឋិតនៅនឹងថ្កល់ដូចជាសសរគោល កាយទាំងនោះមិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនគ្នាទៅវិញទៅមក មិនអាចឲ្យសេចក្តីសុខឬទុក្ខដល់គ្នាទៅវិញទៅមកទេ ។ កាយទាំង ៧ តើដូចម្តេច ។ កាយគឺដី ១ កាយគឺទឹក ១ កាយគឺភ្លើង ១ កាយគឺខ្យល់ ១ សុខ ១ ទុក្ខ ១ ជីវិត ១ ។ កាយទាំង ៧ នេះឯង គ្មានអ្នកធ្វើបាន គ្មានអ្នកបង្គាប់ឲ្យធ្វើបាន គ្មានអ្នកតាក់តែងបាន មិនគប្បីតាក់តែងបាន

---

១ តាក់តែងដោយឫទ្ធិមិនបាន ។ ២ គ្មានផលជាពូជតទៅ ដូចសត្វបិញ្ជៀមដែលគ្មានកូននិងដើមត្នោតឈ្មោលជាដើម

វញ្ឈា កូដដ្ឋា ឯសិកដ្ឋាយិដ្ឋិតា តេ ន ឥញ្ជន្តិ ន វិបរិណាមន្តិ ន អញ្ញមញ្ញំ ព្យាពាធេន្តិ នាលំ អញ្ញមញ្ញស្ស សុខាយ វា ទុក្ខាយ វា ។ យោបិ តិណ្ហេន សត្ថេន សីសំ ឆិន្ទតិ ន កោចិ កតិំ(១) ជីវិតា វោរោបេតិ ។ សត្តន្នំ ត្វេវ កាយានមន្តរេន សត្ថំ វិវរមនុបតតិ ។ ចុទ្ទស ខោ បនិមានិ យោនិប្បមុខសតសហស្សានិ សដ្ឋី ច សតានិ ឆ ច សតានិ បញ្ច ច កម្មុនោ សតានិ ច បញ្ច ច កម្មានិ តីណិ ច កម្មានិ កម្មេ ច អឌ្ឍកម្មេ ច ទ្វដ្ឋិបដិបទា ទ្វដ្ឋន្តរកប្បា

១ ន កោចំ កិញ្ចីតិបិ ។

ជាសភាវៈការ តាំងនៅដូចជាកំពូលភ្នំ ឋិតនៅនឹងថ្កល់ដូចជាសសរគោល កាយទាំងនោះ មិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនគ្នាទៅវិញទៅមក មិនអាចឲ្យសុខឬទុក្ខដល់គ្នាទៅវិញទៅមកបានឡើយ ។ ទុកជាអ្នកណាកាត់នូវក្បាល ដោយគ្រឿងសស្ត្រាដ៏មុត ក៏គ្មានបុគ្គលណាមួយ សម្លាប់បុគ្គលនោះវិញបានឡើយ ។ គ្រឿងសស្ត្រាមែនចូលទៅកាន់ចន្លោះ ក្នុងចន្លោះនៃកាយទាំង ៧ ។ ឯកំណើតជាប្រធាន[១]ទាំងនេះ មានចំនួន ១ លាន ៤ សែន ៦ ពាន់ ៦ រយ កម្មមានចំនួន ៥០០ កម្មមានចំនួន ៥ កម្មមានចំនួន ៣ និងកម្មគឺកាយកម្មវចីកម្ម កម្មពាក់កណ្តាលគឺមនោកម្ម សេចក្តីប្រតិបត្តិមានចំនួន ៦២ អន្តរកប្ប[២]មានចំនួន ៦២

១ មានកំណើត មនុស្ស ក្សត្រិយ៍ និងព្រាហ្មណ៍ជាដើម ។ ២ ក្នុងមហាកប្បមួយមានអន្តរកប្ប ៦៤ តែបុគ្គលជាមិច្ឆាទិដ្ឋិមិនដឹងដូច្នោះទេ បានជាយល់ថា ៦២ វិញ ។

ឆឡាភិជាតិយោ អដ្ឋ បុរិសភូមិយោ ឯកូនបញ្ញាស

អាជីវកសតេ ឯកូនបញ្ញាស បរិព្វាជកសតេ ឯកូន-

បញ្ញាស នាគាវាសសតេ វីសេ ឥន្ទ្រិយសតេ តឹសេ

និរយសតេ ឆត្តឹស រជោធាតុយោ សត្ត សញ្ញិគព្ភា

*អភិជាតិ (១) មានចំនួន ៦ បុរិសភូមិ (២) មានចំនួន ៨ ពួកអាជីវកមានចំនួន ៤ ពាន់ ៩ រយ ពួកបរិព្វាជកមានចំនួន ៤ ពាន់ ៩ រយ លំនៅនាគមានចំនួន ៤ ពាន់ ៩ រយ ឥន្ទ្រិយមានចំនួន ២ ពាន់ នរកមានចំនួន ៣ ពាន់ ធាតុដែលប្រកបដោយធូលី (មានខ្លួនដៃខ្លួនជើងជាដើម) មានចំនួន ៣៦ ពួកគភ៌នៃសត្វដែលមានសញ្ញា(៣)មានចំនួន ៧*

---

១ ឯអភិជាតិទាំង ៦ នោះគឺ កណ្ហាភិជាតិ (ជាតិខ្មៅ) បានដល់ព្រានម្រឹគ ព្រានបក្សីជាដើម ១ និលាភិជាតិ (ជាតិខៀវ) បានដល់ភិក្ខុដែលបួសក្នុងព្រះពុទ្ធសាសនា ១ លោហិតាភិជាតិ (ជាតិក្រហម) បានដល់ពួកនិគ្រន្ថ ១ ហលិទ្ទាភិជាតិ (ជាតិលឿងដូចរមៀត) បានដល់ពួកអចេលសាវ័ក ១ សុក្កាភិជាតិ (ជាតិស) បានដល់ពួកអាជីវក ១ បរមសុក្កាភិជាតិ (ជាតិសណាស់) បានដល់ពួកជនជានន្ទគោត្រនិងវច្ឆគោត្រជាដើម ១ ។ ២ ឯបុរិសភូមិទាំង ៨ នោះគឺ មន្ទភូមិ (កាលដែលនៅល្ងង់ខ្លៅ) បានដល់ទារកដែលទើបប្រសូតមកបាន ៧ ថ្ងៃនៅល្ងង់វង្វេង ១ ខិឌ្ឌាភូមិ (កាលដែលមានល្បែង) បានដល់ទារកដែលមកអំពីទុគ្គតិ យំស្រែកច្រើន ឬទារកដែលមកអំពីសុគតិ រឭកឃើញសុគតិហើយសើចរីករាយសប្បាយច្រើន ១ បទវីមំសភូមិ (កាលដែលទើបរៀនដើរ) បានដល់ទារកដែលទើបបេះកាន់ដៃមាតាបិតារៀនដើរ ១ ឧជុគតភូមិ (កាលដែលដើរត្រង់បាន) បានដល់ទារកដែលបេះដើររឹងប៉ឹងហើយ ១ សេក្ខភូមិ (កាលដែលសិក្សាសិល្ប) ១ សមណភូមិ (កាលដែលចេញបួស) ១ ជិនភូមិ (កាលដែលរៀនសិល្បអំពីសំណាក់អាចារ្យចេះដឹងស្រេចហើយ) ១ បន្នភូមិ (កាលបួសហើយត្រាច់ទៅបិណ្ឌបាត ឬប្រតិបត្តិធម៌ ឬចាស់គ្រាំគ្រា) ១ ។ ៣ សត្វដែលមានសញ្ញា ៧ នោះគឺ ឧដ្ឋ ១ គោ ១ លា ១ ពពែ ១ សត្វចិញ្ចឹម ១ ម្រឹគ ១ ក្របី ១ (អដ្ឋកថា) ។

សត្ត អសញ្ញិគព្ភា សត្ត និគណ្ឋិគព្ភា សត្ត ទិព្វា សត្ត មានុសា សត្ត បិសាចា សត្ត សរា សត្ត បវុដា(១) សត្ត ច បវុដសតានិ សត្ត បបាតា សត្ត ច បបាតសតានិ សត្ត សុបិនា សត្ត ច សុបិនសតានិ ចុល្លាសីតិ(២) មហាកប្បិនោ សតសហស្សានិ យានិ ពាលេ ច បណ្ឌិតេ ច សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករិស្សន្តិ តត្ថ នត្ថិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា អបរិបក្កំ វា កម្មំ បរិបាចេស្សាមិ បរិបក្កំ វា កម្មំ ផុស្ស ផុស្ស ព្យន្តីករិស្សាមីតិ ហេវំ នត្ថិ ទោណមិតេ សុខទុក្ខេ បរិយន្តកតេ សំសារេ នត្ថិ ហាយនវឌ្ឍនេ នត្ថិ ឧក្កំសាវកំសេ ។ សេយ្យថាបិ នាម សុត្តគុឡេ ខិត្តេ និព្វេឋិយមានមេវ បលេតិ ។

---

១ ឱ. បវុធា ។ ម. សបុដា ។ ២ ចតុរាសីតីតិ អដ្ឋកថាយំ ទិស្សតិ ។

ពួកគ័ភ៌នៃវត្ថុដែលឥតសញ្ញា (១) មាន ៧ ពួកគ័ភ៌នៃជាតិដែលដុះអំពីថ្នាំង (មានអំពៅជាដើម) មានចំនួន ៧ ពួកទេវតាមានចំនួន ៧ ពួកមនុស្ស មានចំនួន ៧ ពួកបិសាចមានចំនួន ៧ ស្រះមានចំនួន ៧ រអាងភ្នំធំមាន ចំនួន ៧ រអាងភ្នំតូចមានចំនួន ៧០០ ជ្រោះធំមានចំនួន ៧ ជ្រោះតូចមាន ចំនួន ៧០០ សុបិនធំមានចំនួន ៧ សុបិនតូចមានចំនួន ៧០០ ជនពាល ក្ដី ជនជាបណ្ឌិតក្ដី អន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងវដ្ដសង្សារ) អស់ កាលចំនួន ៨ លាន ៤ សែនមហាកប្បហើយ នឹងធ្វើនូវទីបំផុតនៃទុក្ខបាន បុគ្គលកំណត់ទុកថា អាត្មាអញ នឹងធ្វើកម្មដែលមិនទាន់ចាស់ឲ្យចាស់ផង អាត្មាអញបានពាល់ត្រូវរឿយ ៗ នូវកម្មចាស់ស្រាប់ហើយ ៗ ធ្វើឲ្យអស់ទៅ ដោយសីលនេះក្ដី ដោយវត្តនេះក្ដី ដោយតបៈនេះក្ដី ដោយព្រហ្មចរិយៈ នេះក្ដី ដូច្នេះ មិនមានក្នុងមហាកប្បទាំងនោះឡើយ សេចក្ដីសុខទុក្ខដែល ធ្វើឲ្យមានទីបំផុត ដូចគេវាល់របស់ ដោយទោណៈ មិនមានក្នុងសង្សារ- វដ្ដយ៉ាងនេះឡើយ សង្សារ មិនមានសេចក្ដីសាបសូន្យសេចក្ដីចម្រើន មិន មានខ្ពស់ទាប ៗ ដូចរមូរនៃអម្បោះដែលគេបោះចោលទៅ រមូរអម្បោះ នោះក៏រលាអស់ (ត្រឹមតែកំណត់អម្បោះប៉ុណ្ណោះ) យ៉ាងណាមិញ ៗ

---

១ ធញ្ញជាតិ ៧ គឺ ស្រូវសាលី ១ ស្រូវខ្សាយ ១ ស្រូវដំណើប ១ ស្រងែ ១ កន្ទុយដំរី ១ ស្គួយ ១ គែលលក ១ ។

ឯវមេវ ពាលេ ច បណ្ឌិតេ ច និព្វេឋិយមានា សុខ-ទុក្ខំ បលេន្តីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិ-និវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ សត្តិមេ កាយា អកដា អកដវិធា ។ បេ ។ សុខទុក្ខំ បលេន្តីតិ ។ វេទនាយ សតិ ។ បេ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិ-និវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ សត្តិមេ កាយា អកដា អកដវិធា ។ បេ ។ សុខទុក្ខំ បលេន្តីតិ ។

(១៥៩) តំ កិំ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធ-ម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សត្តិមេ កាយា អកដា អកដវិធា ។ បេ ។ សុខ-ទុក្ខំ បលេន្តីតិ ។ នោ ហេតំ ភន្តេ ។ វេទនា

ជនពាលក្តី ជនជាបណ្ឌិតក្តី មានសង្សារលោទៅ ក៏អណ្តែតហើយទៅកាន់សេចក្តីសុខទុក្ខបាន យ៉ាងដូច្នេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា កាយទាំង ៧ នេះ គ្មានអ្នកធ្វើទេ គ្មានអ្នកបង្គាប់ឲ្យធ្វើទេ ។ បេ ។ រមែងអណ្តែតហើយទៅកាន់សេចក្តីសុខទុក្ខ ។ កាលបើវេទនាមាន ។ បេ ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា កាយទាំង ៧ នេះ គ្មានអ្នកធ្វើទេ គ្មានអ្នកបង្គាប់ឲ្យធ្វើទេ ។ បេ ។ រមែងអណ្តែតហើយទៅកាន់សេចក្តីសុខទុក្ខ ។

(១៥៩) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា កាយទាំង ៧ នេះ គ្មានអ្នកធ្វើទេ គ្មានអ្នកបង្គាប់ឲ្យធ្វើទេ ។ បេ ។ រមែងអណ្តែតហើយទៅកាន់សេចក្តីសុខទុក្ខដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ វេទនា

។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សត្តិមេ កាយា អកដា អកដវិធា ។បេ។ សុខទុក្ខំ បលេន្តីតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាណំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តំបិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សត្តិមេ កាយា អកដា អកដវិធា ។បេ។ និព្ឋិយ-ឋាណា សុខទុក្ខំ បលេន្តីតិ ។ នោ ហេតំ ភន្តេ ។ យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមេសុ ឆសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា

ៗ ពេ ៗ សញ្ញា ៗ សង្ខារទាំងឡាយ ៗ វិញ្ញាណទៀងឬមិនទៀង ៗ មិនទៀងទេ ព្រះអង្គ ៗ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា កាយទាំង ៧ នេះ គ្មានអ្នកធ្វើទេ គ្មានអ្នកបង្គាប់ឲ្យធ្វើទេ ៗ ពេ ៗ រមែងអណ្តែតហើរទៅកាន់សេចក្តីសុខទុក្ខដែរឬ ៗ មិនមែនដូច្នោះទេ ព្រះអង្គ ៗ របស់ណាដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ បានដល់ បានស្វែងរក បានពិចារណារឿយៗដោយចិត្ត របស់នោះ ទៀងឬមិនទៀង ៗ មិនទៀងទេ ព្រះអង្គ ៗពេៗ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា កាយទាំង ៧ នេះ គ្មានអ្នកធ្វើទេ គ្មានអ្នកបង្គាប់ឲ្យធ្វើទេ ៗ ពេ ៗ ជនពាលក្តី ជនជាបណ្ឌិតក្តី មានសង្សារលោះចេញ អណ្តែតហើរទៅកាន់សេចក្តីសុខទុក្ខ ដែរឬ ៗ មិនមែនដូច្នោះទេ ព្រះអង្គ ៗ ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវក លះបង់សេចក្តីសង្ស័យក្នុងឋានទាំង ៦ នេះបានហើយ សេចក្តីសង្ស័យក្នុងទុក្ខ អរិយសាវកនោះ

បហីនា ហោតិ ។បេ។ ទុក្ខនិរោធគាមិនិយា បដិបទាយបិស្ស កង្ខា បហីនា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(១៦០) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ សស្សតោ លោកោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ សស្សតោ លោកោតិ ។ វេទនាយ សតិ ។បេ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ សស្សតោ លោកោតិ ។

កិលេះបន់បាន ។ បេ ។ សេចក្ដីសង្ស័យក្នុងបដិបទា ជាដំណើរទៅកាន់សេចក្ដីរលត់ទុក្ខ អរិយសាវ័កនោះ កិលេះបន់បាន ។ ម្នាលភិក្ខុទាំង-ឡាយ អរិយសាវ័កនេះ ហៅថា សោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៦០) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា លោកទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា លោកទៀង ។ កាលបើវេទនាមាន ។ បេ ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា លោកទៀង ។

[១៦១] តំ កិំ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ។ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សស្សតោ លោកោតិ ។ នោ ហេតំ ភន្តេ ។ វេទនា ។បេ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សស្សតោ លោកោតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ សស្សតោ លោកោតិ ។ នោ ហេតំ ភន្តេ ។ យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមេសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា បហីនា ហោតិ ។បេ។

(១៦១) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះ ដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា លោកទៀងដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា លោកទៀងដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ របស់ណាដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ បានដល់ បានស្វែងរក បានពិចារណារឿយ ៗ ដោយចិត្ត របស់នោះ ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា លោកទៀងដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវ័ក លះបង់សេចក្តីសង្ស័យក្នុងឋានទាំង ៦ នេះបានហើយ សេចក្តីសង្ស័យក្នុងទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។ បេ ។

ទុក្ខនិរោធគាមិនិយា បដិបទាយបិស្ស កង្ខា បហីនា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(១៦២) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ អសស្សតោ លោកោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ ។បេ។ វេទនាយ សតិ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ(១) វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ អ-សស្សតោ លោកោតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តំបិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ ។ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ

---

១ ឯត្ថន្តរេ បេ ឥតិ បទំ យុត្តតរំ ។

សេចក្តីសង្ស័យក្នុងបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ អរិយ-សាវ័កនោះ ក៏លះបង់បាន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះ ហៅថា សោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

[ ១៦៤ ] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា លោកមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំង-ឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ។ បេ ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា លោកមិនទៀងដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ របស់ណាដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ បានដល់ បានស្វែងរក បានពិចារណារឿយៗដោយចិត្ត របស់នោះទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចុះបើមិនអាស្រ័យ នូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះ

អសស្សតោ លោកោតិ ។ នោ ហេតំ ភន្តេ ។ យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមេសុ ឆសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា បហីនា ហោតិ ។បេ។ ទុក្ខនិរោធគាមិនិយា បដិបទាយបិស្ស កង្ខា បហីនា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(១៦៣) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ អន្តវា លោកោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ និយតោ សម្ពោធិបរាយណោតិ ។

(១៦៤) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ អនន្តវា លោកោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ និយតោ សម្ពោធិបរាយណោតិ ។

ថា លោកមិនទៀងដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវក លះបង់សេចក្តីសង្ស័យក្នុងឋានទាំង ៦ នេះបានហើយ សេចក្តីសង្ស័យក្នុងទុក្ខ អរិយសាវកនោះ ក៏លះបង់បាន ។ បេ ។ សេចក្តីសង្ស័យក្នុងបដិបទា ជាដំណើរទៅកាន់ការរលត់ទុក្ខ អរិយសាវកនោះ ក៏លះបង់បាន ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកនេះ ហៅថា សោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៦៣) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា លោកមានទីបំផុត ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំង-ឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៦៤) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា លោកមិនមានទីបំផុត ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៦៥) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ តំ ជីវំ តំ សរីរន្តិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ និយតោ សម្ពោធិបរាយនោតិ ។

(១៦៦) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ និយតោ សម្ពោធិបរាយនោតិ ។

(១៦៧) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ហោតិ តថាគតោ បរម្មរណាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ និយតោ សម្ពោធិបរាយនោតិ ។

[ ១៦៥ ] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ជីវិតនោះគឺសរីរៈនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ជាបុគ្គលទៀងមានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

[ ១៦៦ ] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ជាបុគ្គលទៀងមានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

[ ១៦៧ ] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា សត្វបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងកើតទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ របស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៦៨) សាវត្ថី ។ តត្រ ខោ ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ន ហោតិ តថាគតោ បរម្មរណាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ និយតោ សម្ពោធិបរាយណោតិ ។

(១៦៩) សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ និយតោ សម្ពោធិបរាយណោតិ ។

( ១៦៨ ) ក្រុងសាវត្ថី ។ កន្លែងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា សត្វបន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងមិនកើតទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

( ១៦៩ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា សត្វបន្ទាប់អំពីសេចក្ដីស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៧០) សាវត្ថិ ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ។បេ។

(១៧១) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។បេ។ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ។ នោ ហេតំ ភន្តេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ

( ១៧០ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមាន អ្វីហ្ន៎ ព្រោះអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើង យ៉ាងនេះថា សត្វបន្ទាប់អំពីសេចក្តីស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយរបស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា សត្វបន្ទាប់អំពីសេចក្តីស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ បេ ។

( ១៧១ ) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា សត្វបន្ទាប់អំពីសេចក្តីស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ របស់ណា ដែលបុគ្គលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់

បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តំបិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ។ នោ ហេតំ ភន្តេ ។ យតោ ច ខោ ភិក្ខវេ អរិយសាវកស្ស ឥមេសុ ឋានេសុ កង្ខា បហីនា ហោតិ ទុក្ខេបិស្ស កង្ខា បហីនា ហោតិ ទុក្ខសមុទយេបិស្ស កង្ខា បហីនា ហោតិ ។បេ។ និយតោ សម្ពោធិបរាយនោតិ ។

សោតាបត្តិវគ្គោ បឋមោ ។

អដ្ឋារសវេយ្យាករណំ និដ្ឋិតំ[១] ។

---

១ វាតំ ឯតំ មម សោ អត្តា នោ ច មេ សិយា នត្ថិ ករោតោ ហេតុ ច មហាទិដ្ឋេន អដ្ឋមំ ។ សស្សតោ លោកោ ច អសស្សតោ ច អន្តវា ច អនន្តវា ច តំ ជីវំ តំ សរីរន្តិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ ច ហោតិ តថាគតោ បរម្មរណាតិ ន ហោតិ តថាគតោ ... បរម្មរណាតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ឥទំ ឧទ្ទានំ ឱ. ម. បោត្ថកេសុ អាគតំ ។

បានដល់ បានស្វែងរក បានពិចារណារឿយៗដោយចិត្ត របស់នោះទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ របស់ណាមិនទៀង ជាទុក្ខ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា សត្វបន្ទាប់អំពីសេចក្តីស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវ័កលះបង់សេចក្តីសង្ស័យក្នុងឋានទាំង ៦ នេះបានហើយ សេចក្តីសង្ស័យក្នុងទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន សេចក្តីសង្ស័យក្នុងហេតុជាទីកើតឡើងនៃទុក្ខ អរិយសាវ័កនោះ ក៏លះបង់បាន ។ បេ ។ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

ចប់ សោតាបត្តិវគ្គ ទី ១ ។

ចប់ វេយ្យាករណ៍ ១៨ ។

# ទិដ្ឋិសំយុត្តេ ទុតិយបេយ្យាលោ

[១៧៦] សាវត្ថី ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ន វាតា វាយន្តិ ន នជ្ជោ សន្ទន្តិ ន គព្ភិនិយោ វិជាយន្តិ ន ចន្ទិមសុរិយា ឧទេន្តិ វា អបេន្តិ វា ឯសិកដ្ឋាយិដ្ឋិតាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ន វាតា វាយន្តិ ។បេ។ ឯសិកដ្ឋាយិដ្ឋិតាតិ ។ វេទនាយ សតិ ។បេ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ន វាតា វាយន្តិ ។បេ។ ឯសិកដ្ឋាយិដ្ឋិតាតិ ។

## ទិដ្ឋិសំយុត្ត បេយ្យាលៈ ទី ២

( ១៧៤ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមាន អ្វីហ្ន៎ ព្រោះតែអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ទឹកស្ទឹងមិនហូរ ស្រីមានគភ៌មិនសម្រាលកូន ព្រះចន្ទ្រ និងព្រះអាទិត្យមិនរះឡើងឬមិនលិចទៅ តាំងនៅនឹងថ្កល់ ដូចជាសសរគោល ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានរូប ព្រោះតែអាស្រ័យរូប ប្រកាន់រូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ។ បេ ។ តាំងនៅនឹងថ្កល់ដូចជាសសរគោល ។ កាលបើមានវេទនា ។ បេ ។ កាលបើមានសញ្ញា ។ កាលបើមានសង្ខារទាំងឡាយ ។ កាលបើមានវិញ្ញាណ ព្រោះតែអាស្រ័យវិញ្ញាណ ប្រកាន់វិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ។ បេ ។ តាំងនៅនឹងថ្កល់ដូចជាសសរគោល ។

(១៧៣) តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ ន វាតា វាយន្តិ ។ បេ ។ ឯសិកដ្ឋាយិដ្ឋិតាតិ ។ នោ ហេតំ ភន្តេ ។ ឥតិ ខោ ភិក្ខវេ ទុក្ខេ សតិ ទុក្ខំ ឧបាទាយ ទុក្ខំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ន វាតា វាយន្តិ ។ បេ ។ ឯសិកដ្ឋាយិដ្ឋិតាតិ ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារា ។ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឯវំ ទិដ្ឋិ ឧប្បជ្ជេយ្យ ន វាតា វាយន្តិ ។ បេ ។ ឯសិកដ្ឋាយិដ្ឋិតាតិ ។ នោ ហេតំ ភន្តេ ។

(១៧៣) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ មានសេចក្តីប្រែប្រួលជាធម្មតា បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ។ បេ ។ តាំងនៅនឹងថ្កល់ដូចជាសសរគោលដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានទុក្ខ ព្រោះតែអាស្រ័យទុក្ខ ប្រកាន់ទុក្ខដូច្នេះឯង ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ។ បេ ។ តាំងនៅនឹងថ្កល់ដូចជាសសរគោល ។ វេទនា ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ មានសេចក្តីប្រែប្រួលជាធម្មតា បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ។ បេ ។ តាំងនៅនឹងថ្កល់ដូចជាសសរគោលបានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។

ឥតិ ខោ ភិក្ខវេ ទុក្ខេ សតិ ទុក្ខំ ឧបាទាយ ទុក្ខំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ(១) ន វាតា វាយន្តិ ន នជ្ជោ សន្ទន្តិ ន គព្ភិនិយោ វិជាយន្តិ ន ចន្ទិមសុរិយា ឧទេន្តិ វា អបេន្តិ វា ឯសិកដ្ឋាយិដ្ឋិតាតិ ។ (បុរិម-គមនានិ ហិ អដ្ឋារស វេយ្យាករណានិ វិត្ថារានិ) ។

[១៧៤] សាវត្ថី ។ តត្រ ខោ ។ កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ រូបេ ខោ ភិក្ខវេ សតិ រូបំ ឧបាទាយ រូបំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ។ វេទនាយ សតិ ។ បេ ។ សញ្ញាយ សតិ ។ សង្ខារេសុ សតិ ។ វិញ្ញាណេ សតិ វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវិស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ។

---

១ ម. ឧប្បជ្ជេយ្យ ។

ម្នាលភិក្ខុទាំងឡាយ កាលបើមានទុក្ខ ព្រោះតែអាស្រ័យទុក្ខ ប្រកាន់ទុក្ខដូច្នេះឯង ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ទឹកស្ទឹងមិនហូរ ស្រីមានគភ៌មិនសម្រាលកូន ព្រះចន្ទ្រនិងព្រះអាទិត្យមិនរះឡើង ឬមិនលិចទៅ តាំងនៅនឹងថ្កល់ដូចជាសសរគោល ។ ( ឯវេយ្យាករណ៍ដ៏ពិស្តារទាំង ១៨ មានដំណើរដូចមុន ) ។

(២២៨) សាវត្ថី ។ យោ ភិក្ខវេ ចក្ខុវិញ្ញាណស្មឹ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យោ សោតវិញ្ញាណស្មឹ ។ យោ ឃានវិញ្ញាណស្មឹ ។ យោ ជិវ្ហាវិញ្ញាណស្មឹ ។ យោ កាយវិញ្ញាណស្មឹ ។ យោ មនោវិញ្ញាណស្មឹ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ ឥមេសុ ឆសុ ឋានេសុ ចេតសោ ឧបក្កិលេសោ បហីនោ ហោតិ នេក្ខម្មនិន្នំ ចស្ស ចិត្តំ ហោតិ នេក្ខម្មបរិភាវិតំ ចិត្តំ កម្មនិយំ ខាយតិ អភិញ្ញា សច្ឆិករណីយេសុ ធម្មេសូតិ ។

[២២៧] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងរូប នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ក្នុងសំឡេង ។ ក្នុងក្លិន ។ ក្នុងរស ។ ក្នុងផោដ្ឋព្វៈ ។ ឆន្ទរាគណា ក្នុងធម្មារម្មណ៍ នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុលះបង់នូវឧបក្កិលេសរបស់ចិត្តក្នុងហេតុទាំង ៦ នេះបានហើយ ចិត្តរបស់ភិក្ខុនោះ តែងបង្អោនទៅរកនេក្ខម្មៈផង ជាចិត្តអប់រំដោយនេក្ខម្មៈផង ជាចិត្តគួរដល់ការនាកម្ម ប្រាកដក្នុងធម៌ទាំងឡាយ ដែលខ្លួនគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមផង ។

[២២៨] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងចក្ខុវិញ្ញាណ នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ក្នុងសោតវិញ្ញាណ ។ ក្នុងឃានវិញ្ញាណ ។ ក្នុងជិវ្ហាវិញ្ញាណ ។ ក្នុងកាយវិញ្ញាណ ។ ឆន្ទរាគណា ក្នុងមនោវិញ្ញាណ នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ម្នាលភិក្ខុទាំង-ឡាយ កាលណាបើភិក្ខុ លះបង់នូវឧបក្កិលេសរបស់ចិត្តក្នុងហេតុទាំង ៦ នេះបានហើយ ចិត្តរបស់ភិក្ខុនោះ តែងបង្អោនទៅរកនេក្ខម្មៈផង ជាចិត្តអប់រំដោយនេក្ខម្មៈផង ជាចិត្តគួរដល់ការនាកម្ម ប្រាកដក្នុងធម៌ទាំងឡាយ ដែលខ្លួនគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមផង ។

[២២៩] សាវត្ថិ ។ យោ ភិក្ខវេ ចក្ខុសម្ផស្សស្មឹ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យោ សោតសម្ផស្សស្មឹ ។ យោ ឃានសម្ផស្សស្មឹ ។ យោ ជិវ្ហាសម្ផស្សស្មឹ ។ យោ កាយសម្ផស្សស្មឹ ។ យោ មនោសម្ផស្សស្មឹ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ ។បេ។ អភិញ្ញា សច្ឆិករណីយេសុ ធម្មេសូតិ ។

[២៣០] សាវត្ថិ ។ យោ ភិក្ខវេ ចក្ខុសម្ផស្សជាយ វេទនាយ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យោ សោតសម្ផស្សជាយ វេទនាយ ។ យោ ឃានសម្ផស្សជាយ វេទនាយ ។ យោ ជិវ្ហាសម្ផស្សជាយ វេទនាយ ។ យោ កាយសម្ផស្សជាយ វេទនាយ ។ យោ មនោសម្ផស្សជាយ វេទនាយ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ ។បេ។ អភិញ្ញា សច្ឆិករណីយេសុ ធម្មេសូតិ ។

( ៦២៩ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងចក្ខុសម្ផស្ស នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ក្នុងសោតសម្ផស្ស ។ ក្នុងឃានសម្ផស្ស ។ ក្នុងជិវ្ហាសម្ផស្ស ។ ក្នុងកាយសម្ផស្ស ។ ឆន្ទរាគណា ក្នុងមនោសម្ផស្ស នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុ ។ បេ ។ ក្នុងធម៌ទាំងឡាយដែលខ្លួនគួរធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។

( ៦៣០ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងចក្ខុសម្ផស្សជាវេទនា នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ក្នុងសោតសម្ផស្សជាវេទនា ។ ក្នុងឃានសម្ផស្សជាវេទនា ។ ក្នុងជិវ្ហាសម្ផស្សជាវេទនា ។ ក្នុងកាយសម្ផស្សជាវេទនា ។ ឆន្ទរាគណា ក្នុងមនោសម្ផស្សជាវេទនា នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុ ។ បេ ។ ក្នុងធម៌ទាំងឡាយដែលខ្លួនគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។

(២៣១) សាវត្ថិ ។ យោ ភិក្ខវេ រូបសញ្ញាយ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យោ សទ្ទសញ្ញាយ ។ យោ គន្ធសញ្ញាយ ។ យោ រសសញ្ញាយ ។ យោ ផោដ្ឋព្វសញ្ញាយ ។ យោ ធម្មសញ្ញាយ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ ។បេ។ អភិញ្ញា សច្ឆិករណីយេសុ ធម្មេសូតិ ។

(២៣២) សាវត្ថិ ។ យោ ភិក្ខវេ រូបសញ្ចេតនាយ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យោ សទ្ទសញ្ចេតនាយ ។ យោ គន្ធសញ្ចេតនាយ ។ យោ រសសញ្ចេតនាយ ។ យោ ផោដ្ឋព្វសញ្ចេតនាយ ។ យោ ធម្មសញ្ចេតនាយ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ ។បេ។ អភិញ្ញា សច្ឆិករណីយេសុ ធម្មេសូតិ ។

(២៣១) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងរូបសញ្ញា នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ក្នុងសទ្ទសញ្ញា ។ ក្នុងគន្ធសញ្ញា ។ ក្នុងរសសញ្ញា ។ ក្នុងផោដ្ឋព្វសញ្ញា ។ ឆន្ទរាគណា ក្នុងធម្មសញ្ញា នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុ ។ បេ ។ ក្នុងធម៌ទាំងឡាយដែលខ្លួនគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។

(២៣២) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងរូបសញ្ចេតនា នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ក្នុងសទ្ទសញ្ចេតនា ។ ក្នុងគន្ធសញ្ចេតនា ។ ក្នុងរសសញ្ចេតនា ។ ក្នុងផោដ្ឋព្វសញ្ចេតនា ។ ឆន្ទរាគណា ក្នុងធម្មសញ្ចេតនា នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុ ។ បេ ។ ក្នុងធម៌ទាំងឡាយដែលខ្លួនគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។

កិលេសសំយុត្តំ

[២៣៣] សាវត្ថី ។ យោ ភិក្ខវេ រូបតណ្ហាយ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យោ សទ្ទតណ្ហាយ ។ យោ គន្ធតណ្ហាយ ។ យោ រសតណ្ហាយ ។ យោ ផោដ្ឋព្វតណ្ហាយ ។ យោ ធម្មតណ្ហាយ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ ។ បេ ។ អភិញ្ញា សច្ឆិករណីយេសុ ធម្មេសូតិ ។

[២៣៤] សាវត្ថី ។ យោ ភិក្ខវេ បឋវីធាតុយា ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យោ អាបោធាតុយា ។ យោ តេជោធាតុយា ។ យោ វាយោធាតុយា ។ យោ អាកាសធាតុយា ។ យោ វិញ្ញាណធាតុយា ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ ឥមេសុ ឆសុ ឋានេសុ ចេតសោ ឧបក្កិលេសោ បហីនោ ហោតិ នេក្ខម្មនិន្នំ ចស្ស ចិត្តំ ហោតិ នេក្ខម្មបរិភាវិតំ ចិត្តំ កម្មនិយំ ខាយតិ អភិញ្ញា សច្ឆិករណីយេសុ ធម្មេសូតិ ។

[២៣៣] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងរូបតណ្ហា នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ក្នុងសទ្ទតណ្ហា ។ ក្នុងគន្ធតណ្ហា ។ ក្នុងរសតណ្ហា ។ ក្នុងផោដ្ឋព្វតណ្ហា ។ ឆន្ទរាគណា ក្នុងធម្មតណ្ហា នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុ ។ បេ ។ ក្នុងធម៌ទាំងឡាយដែលខ្លួនគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។

[២៣៤] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងបឋវីធាតុ នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ក្នុងអាបោធាតុ ។ ក្នុងតេជោធាតុ ។ ក្នុងវាយោធាតុ ។ ក្នុងអាកាសធាតុ ។ ឆន្ទរាគណា ក្នុងវិញ្ញាណធាតុ នុ៎ះ ជាឧបក្កិលេសរបស់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុលះបង់នូវឧបក្កិលេសរបស់ចិត្តក្នុងហេតុទាំង ៦ នេះបានហើយ ចិត្តរបស់ភិក្ខុនោះ រមែងបង្អោនទៅរកនេក្ខម្មៈផង ជាចិត្តអប់រំក្នុងនេក្ខម្មៈផង ជាចិត្តគួរដល់ការនាកម្ម ប្រាកដក្នុងធម៌ទាំងឡាយដែលខ្លួនគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមផង ។

[២៣៨] សាវត្ថិ ។ យោ ភិក្ខវេ រូបស្មឹ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។បេ។ យោ វិញ្ញាណស្មឹ ឆន្ទរាគោ ចិត្តស្សេសោ ឧបក្កិលេសោ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ ឥមេសុ ឆសុ(១) ឋានេសុ ចេតសោ ឧបក្កិលេសោ បហីនោ ហោតិ នេក្ខម្មនិន្នញ្ចស្ស ចិត្តំ ហោតិ នេក្ខម្មបរិភាវិតំ ចិត្តំ កម្មនិយំ ខាយតិ អភិញ្ញា សច្ឆិករណីយេសុ ធម្មេសូតិ ។

កិលេសសំយុត្តំ ។

## តស្សុទ្ទានំ

ចក្ខុ រូបញ្ច វិញ្ញាណំ
ផស្សោ ច វេទនាយ ច
សញ្ញា ច ចេតនា តណ្ហា
ធាតុ ខន្ធេន តេ ទសាតិ ។

---

១ ឱ. ម. ឥមេសុ បញ្ចសុ ។

(៦៣៩) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងរូប + នុះ ជាឧបក្កិលេសរបស់ចិត្ត ។ បេ ។ ឆន្ទរាគណា ក្នុងវិញ្ញាណ + នុះ ជាឧបក្កិលេសរបស់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុ លះបង់នូវឧបក្កិលេសរបស់ចិត្តក្នុងហេតុទាំង ៦ នេះបានហើយ ចិត្តរបស់ ភិក្ខុនោះ រមែងបង្អោនទៅរកនេក្ខម្មៈផង ជាចិត្តអប់រំក្នុងនេក្ខម្មៈផង ជា ចិត្តគួរដល់ការនោកម្ម ប្រាកដក្នុងធម៌ទាំងឡាយ ដែលខ្លួនគប្បីធ្វើឲ្យជាក់ ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមផង ។

ចប់ កិលេសសំយុត្ត ។

# ឧទ្ទាននៃកិលេសសំយុត្តនោះគឺ

និយាយអំពីចក្ខុ ១ រូប ១ វិញ្ញាណ ១ ផស្សៈ ១ វេទនា ១ សញ្ញា ១ ចេតនា ១ តណ្ហា ១ ធាតុ ១ ខន្ធ ១ ទាំងអស់ នោះត្រូវជា ១០ ។

# សារីបុត្តសំយុត្តំ

[២៣៦] ឯកំ សមយំ អាយស្មា សារីបុត្តោ សា-
វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
អថខោ អាយស្មា សារីបុត្តោ បុព្វណ្ហសមយំ និវា-
សេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ
សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្ប-
ដិក្កន្តោ យេន អន្ធវនំ តេនុបសង្កមិ ទិវាវិហារាយ
អន្ធវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវា-
វិហារំ និសីទិ ។ អថខោ អាយស្មា សារីបុត្តោ សា-
យណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ជេតវនំ
អនាថបិណ្ឌិកស្ស អារាមោ តេនុបសង្កមិ ។ អទ្ទសា
ខោ អាយស្មា អានន្ទោ អាយស្មន្តំ សារីបុត្តំ ទូរតោ
វ អាគច្ឆន្តំ ទិស្វាន អាយស្មន្តំ សារីបុត្តំ ឯតទវោ-
ច វិប្បសន្នានិ ខោ តេ អាវុសោ សារីបុត្ត ឥន្ទ្រិ-
យានិ បរិសុទ្ធោ មុខវណ្ណោ បរិយោទាតោ កតមេ-
នាយស្មា សារីបុត្តោ អជ្ជ វិហារេន វិហាសីតិ ។

# សារីបុត្តសំយុត្ត

(២៣៦) សម័យមួយ ព្រះសារីបុត្តមានអាយុ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះសារីបុត្តមានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅក្នុងក្រុងសាវត្ថី ដើម្បីបិណ្ឌបាតហើយ ត្រឡប់អំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្តហើយ សំដៅទៅកាន់អន្ធវ័នដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលស៊ប់ក្នុងអន្ធវ័នហើយ គង់សម្រាកក្នុងវេលាថ្ងៃទៀបគល់ឈើមួយ ។ គ្រានោះ ព្រះសារីបុត្តមានអាយុចេញអំពីទីពួនសម្ងំ ក្នុងសាយណ្ហសម័យហើយ ចូលទៅកាន់វត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ។ ព្រះអានន្ទមានអាយុ បានឃើញព្រះសារីបុត្តមានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយ ក៏ពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ឥន្ទ្រិយរបស់លោកជ្រះថ្លា សម្បុរមុខក៏ស្អាតផូរផង់ថ្ងៃនេះ តើព្រះសារីបុត្តមានអាយុ នៅដោយធម៌ជាគ្រឿងនៅដូចម្តេច ។

ឥធាហំ អាវុសោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អាវុសោ ន ឯវំ ហោតិ អហំ បឋមំ ឈានំ សមាបជ្ជាមីតិ វា អហំ បឋមំ ឈានំ សមាបន្នោតិ វា អហំ បឋមា ឈានា វុដ្ឋិតោតិ វាតិ ។ តថា ហិ បនាយស្មតោ សារីបុត្តស្ស ទីឃរត្តំ អហង្ការមមង្ការមានានុសយា សុសមូហតា តស្មា អាយស្មតោ សារីបុត្តស្ស ន ឯវំ ហោតិ អហំ បឋមំ ឈានំ សមាបជ្ជាមីតិ វា អហំ បឋមំ ឈានំ សមាបន្នោតិ វា អហំ បឋមា ឈានា វុដ្ឋិតោតិ វាតិ ។

ម្នាលអាវុសោ កន្លងទៅឯណោះ ខ្ញុំស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានចូលបឋមជ្ឈានដែលប្រកបដោយវិតក្កៈវិចារៈ មានបីតិនិងសុខៈដែលកើតអំពីសេចក្តីស្ងាត់ ហើយសម្រេចសម្រាន្តនៅ ។ ម្នាលអាវុសោ ខ្ញុំនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកំពុងចូលបឋមជ្ឈាន ឬថា អាត្មាអញបានចូលបឋមជ្ឈានហើយ ឬក៏ថា អាត្មាអញបានចេញអំពីបឋមជ្ឈានហើយ ដូច្នេះឡើយ ។ ព្រះអានន្ទតបថា ពិតដូច្នោះមែន ព្រោះព្រះសារីបុត្តមានអាយុ បានគាស់រំលើងនូវអនុស័យ គឺសេចក្តីប្រកាន់ថាអញ ថារបស់អញ អស់កាលយូរមកហើយ ហេតុនោះ បានជាព្រះសារីបុត្តមានអាយុ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកំពុងចូលបឋមជ្ឈាន ឬថា អាត្មាអញបានចូលបឋមជ្ឈានហើយ ឬក៏ថា អាត្មាអញបានចេញអំពីបឋមជ្ឈានហើយ ដូច្នេះឡើយ ។

## សារីបុត្តសំយុត្តំ

(២៣៧) សាវត្ថិ ។ អទ្ធសា ខោ អាយស្មា អានន្ទោ ។ បេ ។ អាយស្មន្តំ សារីបុត្តំ ឯតទវោច វិប្បសន្នានិ ខោ តេ អាវុសោ សារីបុត្ត ឥន្ទ្រិយានិ បរិសុទ្ធោ មុខវណ្ណោ បរិយោទាតោ កតមេនាយស្មា សារីបុត្តោ អជ្ជ វិហារេន វិហាសីតិ ។ ឥធាហំ អាវុសោ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហាសិំ ។ តស្ស មយ្ហំ អាវុសោ ន ឯវំ ហោតិ អហំ ទុតិយំ ឈានំ សមាបជ្ជាមីតិ វា អហំ ទុតិយំ ឈានំ សមាបន្នោតិ វា អហំ ទុតិយា ឈានា វុដ្ឋិតោតិ វាតិ ។ តថា ហិ បនាយស្មតោ សារីបុត្តស្ស ទីឃរត្តំ អហង្ការមមង្ការមានានុសយា សុសមូហតា តស្មា អាយស្មតោ សារីបុត្តស្ស ន ឯវំ ហោតិ អហំ ទុតិយំ ឈានំ សមាបជ្ជាមីតិ វា អហំ ទុតិយំ ឈានំ សមាបន្នោតិ វា អហំ ទុតិយា ឈានា វុដ្ឋិតោតិ វាតិ ។

## សារីបុត្តសំយុត្ត

[ ២៣៧ ] ក្រុងសាវត្ថី ។ ព្រះអានន្ទមានអាយុ បានឃើញហើយ ។ បេ ។ ក៏បានពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ឥន្ទ្រិយរបស់លោកជ្រះថ្លា សម្បុរមុខក៏ស្អាតផូរផង់ ថ្ងៃនេះតើព្រះសារីបុត្តមានអាយុ គង់សម្រាន្តនៅដោយធម៌ជាគ្រឿងនៅដូចម្តេច ។ ម្នាលអាវុសោ ក្នុងទីឯណោះ ព្រោះរម្ងាប់វិតក្កៈវិចារៈ ខ្ញុំក៏បានចូលដល់ទុតិយជ្ឈានជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈវិចារៈ មានតែបីតិនិងសុខកើតអំពីសមាធិ ហើយសម្រេចសម្រាន្តនៅ ។ ម្នាលអាវុសោ ខ្ញុំនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកំ-ពុងចូលទុតិយជ្ឈាន ឬថា អាត្មាអញបានចូលទុតិយជ្ឈានហើយ ឬក៏ថា អាត្មាអញបានចេញអំពីទុតិយជ្ឈាន ដូច្នេះឡើយ ។ ព្រះអានន្ទតបថា ពិតដូច្នោះមែនហើយ ដ្បិតព្រះសារីបុត្តមានអាយុ បានគាស់រំលើងនូវអនុស័យគឺសេចក្តីប្រកាន់ថាអញ ថារបស់អញ អស់កាលយូរមកហើយ ហេតុនោះ បានជាព្រះសារីបុត្តមានអាយុ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកំពុងចូលទុតិយជ្ឈាន ឬថា អាត្មាអញបានចូលទុតិយជ្ឈានហើយ ឬក៏ថា អាត្មាអញបានចេញអំពីទុតិយជ្ឈាន ដូច្នេះឡើយ ។

(២៣៨) សាវត្ថី ។ អថខោ អាយស្មា អានន្ទោ ។បេ។ វិប្បសន្នានិ ខោ តេ អាវុសោ សារីបុត្ត ឥន្ទ្រិយានិ បរិសុទ្ធោ មុខវណ្ណោ បរិយោទាតោ កតមេនាយស្មា សារីបុត្តោ អជ្ជ វិហារេន វិហាសីតិ ។ ឥធាហំ អាវុសោ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរាមិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេមិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អាវុសោ ន ឯវំ ហោតិ អហំ តតិយំ ឈានំ សមាបជ្ជាមីតិ វា អហំ តតិយំ ឈានំ សមាបន្នោតិ វា អហំ តតិយា ឈានា វុដ្ឋិតោតិ វាតិ ។ តថា ហិ បនាយស្មតោ សារីបុត្តស្ស ទីឃរត្តំ អហង្ការមមង្ការមានានុសយា សុសមូហតា តស្មា អាយស្មតោ សារីបុត្តស្ស ន ឯវំ ហោតិ អហំ តតិយំ ឈានំ សមាបជ្ជាមីតិ វា អហំ តតិយំ ឈានំ សមាបន្នោតិ វា អហំ តតិយា ឈានា វុដ្ឋិតោតិ វាតិ ។

( ៦៣៨ ) ក្រុងសាវត្ថី ។ ព្រះអានន្ទមានអាយុ បានឃើញហើយ ។ បេ ។ ម្នាលអាវុសោសារីបុត្ត ឥន្ទ្រិយរបស់លោកជ្រះថ្លា សម្បុរមុខរបស់លោកក៏ស្អាតផូរផង់ ថ្ងៃនេះ តើព្រះសារីបុត្តមានអាយុគង់សម្រាន្តនៅដោយធម៌ជាគ្រឿងនៅដូចម្តេច ។ ម្នាលអាវុសោ ក្នុងទីឯណោះ ព្រោះនឿយណាយចាកបីតិផង ជាអ្នកព្រងើយផង មានសតិនិងសេចក្តីដឹងខ្លួនផង សោយសុខដោយនាមកាយផង អរិយបុគ្គលទាំងឡាយ តែងសរសើរនូវបុគ្គលដែលបានតតិយជ្ឈាននោះថា ជាអ្នកមានចិត្តព្រងើយ ជាអ្នកមានស្មារតី មានប្រក្រតីនៅជាសុខ ខ្ញុំក៏បានចូលតតិយជ្ឈាន ហើយសម្រេចសម្រាន្តនៅ ។ ម្នាលអាវុសោ ខ្ញុំនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកំពុងចូលតតិយជ្ឈាន ឬថា អាត្មាអញបានចូលតតិយជ្ឈានហើយ ឬក៏ថា អាត្មាអញបានចេញអំពីតតិយជ្ឈាន ដូច្នេះឡើយ ។ ព្រះអានន្ទតបថា ពិតដូច្នោះមែនហើយ ដ្បិតព្រះសារីបុត្តមានអាយុ បានគាស់រំលើងនូវអនុស័យគឺសេចក្តីប្រកាន់ថាអញ ថារបស់អញ អស់កាលយូរមកហើយ ហេតុនោះ បានជាព្រះសារីបុត្តមានអាយុមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកំពុងចូលតតិយជ្ឈាន ឬថា អាត្មាអញបានចូលតតិយជ្ឈានហើយ ឬក៏ថា អាត្មាអញបានចេញអំពីតតិយជ្ឈាន ដូច្នេះឡើយ ។

## សារីបុត្តសំយុត្តំ

(២៣៩) សាវត្ថិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ ។បេ។ វិប្បសន្នានិ ខោ តេ អាវុសោ សារីបុត្ត ឥន្ទ្រិយានិ បរិសុទ្ធោ មុខវណ្ណោ បរិយោទាតោ កតមេនាយស្មា សារីបុត្តោ អជ្ជ វិហារេន វិហាសីតិ ។ ឥធាហំ អាវុសោ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។ តស្ស មយ្ហំ អាវុសោ ន ឯវំ ហោតិ អហំ ចតុត្ថំ ឈានំ សមាបជ្ជាមីតិ វា អហំ ចតុត្ថំ ឈានំ សមាបន្នោតិ វា អហំ ចតុត្ថា ឈានា វុដ្ឋិតោតិ វាតិ ។ តថា ហិ បនាយស្មតោ សារីបុត្តស្ស ទីឃរត្តំ អហង្ការមមង្ការមានានុសយា សុសមូហតា តស្មា អាយស្មតោ សារីបុត្តស្ស ន ឯវំ ហោតិ អហំ ចតុត្ថំ ឈានំ សមាបជ្ជាមីតិ វា អហំ ចតុត្ថំ ឈានំ សមាបន្នោតិ វា អហំ ចតុត្ថា ឈានា វុដ្ឋិតោតិ វាតិ ។

## សារីបុត្តសំយុត្ត

[ ២៣៩ ] ក្រុងសាវត្ថី ។ ព្រះអានន្ទមានអាយុ បានឃើញហើយ ។ បេ ។ ម្នាលអាវុសោសារីបុត្ត ឥន្ទ្រិយរបស់លោកជ្រះថ្លា សម្បុរមុខក៏ស្អាតផូរផង់ ថ្ងៃនេះ តើព្រះសារីបុត្តមានអាយុ គង់សម្រាន្តនៅដោយធម៌ជាគ្រឿងនៅដូចម្តេច ។ ម្នាលអាវុសោ ក្នុងទីឯណោះ ខ្ញុំ លះបង់សេចក្តីសុខផង លះបង់ទុក្ខផង ព្រោះរំលត់សោមនស្សនិងទោមនស្សអំពីមុនផង បានចូលចតុត្ថជ្ឈាន ឥតទុក្ខឥតសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅ ។ ម្នាលអាវុសោ ខ្ញុំនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកំពុងចូលចតុត្ថជ្ឈាន ឬថា អាត្មាអញបានចូលចតុត្ថជ្ឈានហើយ ឬក៏ថា អាត្មាអញបានចេញអំពីចតុត្ថជ្ឈាន ដូច្នេះឡើយ ។ ព្រះអានន្ទតបថា ពិតដូច្នោះមែន ដ្បិតព្រះសារីបុត្តមានអាយុ បានគាស់រំលើងនូវអនុស័យ គឺសេចក្តីប្រកាន់ថា អញ ថារបស់អញ អស់កាលយូរមកហើយ ព្រោះហេតុនោះ បានជាព្រះសារីបុត្តមានអាយុមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកំពុងចូលចតុត្ថជ្ឈាន ឬថា អាត្មាអញបានចូលចតុត្ថជ្ឈានហើយ ឬក៏ថា អាត្មាអញបានចេញអំពីចតុត្ថជ្ឈាន ដូច្នេះឡើយ ។

(២៨០) សាវត្ថី ។ អទ្ទសា ខោ អាយស្មា អានន្ទោ ។ បេ ។ ឥធាហំ អាវុសោ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរាមិ ។ បេ ។ វុដ្ឋិតោតិ ភតិ ។

(២៨១) សាវត្ថី ។ អទ្ទសា ខោ អាយស្មា អានន្ទោ ។ បេ ។ ឥធាហំ អាវុសោ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរាមិ ។ បេ ។ វុដ្ឋិតោតិ ភតិ ។

(២៨២) សាវត្ថី ។ អថខោ អាយស្មា សារីបុត្តោ ។ បេ ។ ឥធាហំ អាវុសោ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរាមិ ។ បេ ។ វុដ្ឋិតោតិ ភតិ ។

[ ៦៦០ ] ក្រុងសាវត្ថី ។ ព្រះអានន្ទមានអាយុ បានឃើញហើយ ។ បេ ។ ម្នាលអាវុសោ ក្នុងទីឯណោះ ខ្ញុំ កន្លងបង់នូវរូបសញ្ញា រំលត់នូវបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ហើយចូលអាកាសានញ្ចាយតនជ្ឈាន ដោយពិចារណាថា អាកាសមិនមានទីបំផុតដូច្នេះ ហើយសម្រេចសម្រាន្តនៅ ។ បេ ។ ចេញហើយ ដូច្នេះឡើយ ។

[ ៦៦១ ] ក្រុងសាវត្ថី ។ ព្រះអានន្ទមានអាយុ បានឃើញហើយ ។ បេ ។ ម្នាលអាវុសោ ក្នុងទីឯណោះ ខ្ញុំកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលវិញ្ញាណញ្ចាយតនជ្ឈាន ដោយពិចារណាថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ហើយសម្រេចសម្រាន្តនៅ ។ បេ ។ ចេញហើយ ដូច្នេះឡើយ ។

[ ៦៦២ ] ក្រុងសាវត្ថី ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ ។ បេ ។ ម្នាលអាវុសោ ក្នុងទីឯណោះ ខ្ញុំកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលអាកិញ្ចញ្ញាយតនជ្ឈាន ដោយពិចារណាថា អ្វីបន្តិចបន្តួចមិនមានដូច្នេះ ហើយសម្រេចសម្រាន្តនៅ ។ បេ ។ ចេញហើយ ដូច្នេះឡើយ ។

សារីបុត្តសំយុត្តំ

(២៤៣) សាវត្ថី ។ អថខោ អាយស្មា សារីបុត្តោ ។ បេ ។ ឥធាហំ អាវុសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរាមិ ។ បេ ។ វុដ្ឋិតោតិ ភតិ ។

(២៤៤) ឯកំ សមយំ អាយស្មា សារីបុត្តោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា សារីបុត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ សាវត្ថឹ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន អន្ធវនំ តេនុបសង្កមិ ទិវាវិហារាយ អន្ធវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ជេតវនំ អនាថបិណ្ឌិកស្ស អារាមោ តេនុបសង្កមិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ អាយស្មន្តំ សារីបុត្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន អាយស្មន្តំ សារីបុត្តំ ឯតទវោច

សារីបុត្តសំយុត្ត

[ ៤៤៣ ] ក្រុងសាវត្ថី ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ ។ បេ ។ ម្នាលអាវុសោ ក្នុងទីឯណោះ ខ្ញុំកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន បានចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយសម្រេចសម្រាន្តនៅ ។ បេ ។ ចេញហើយ ដូច្នេះឡើយ ។

[ ៤៤៤ ] សម័យមួយ ព្រះសារីបុត្តមានអាយុ គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាតហើយ បានត្រឡប់មកពីបិណ្ឌបាតក្នុងវេលាបច្ឆាភត្ត ហើយសំដៅទៅកាន់អន្ធវ័នដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ លុះចូលស៊ប់ក្នុងអន្ធវ័នហើយ ក៏គង់សម្រាកក្នុងវេលាថ្ងៃ ទៀបគល់ឈើមួយ ។ គ្រានោះ ព្រះសារីបុត្តមានអាយុ បានចេញអំពីទីពួនសម្ងំក្នុងវេលាសាយណ្ហសម័យ បានចូលទៅកាន់វត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ។ ព្រះអានន្ទមានអាយុ បានឃើញព្រះសារីបុត្តមានអាយុកំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយ បានពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា

វិប្បសន្នានិ ខោ តេ អាវុសោ សារីបុត្ត ឥន្ទ្រិយានិ
បរិសុទ្ធោ មុខវណ្ណោ បរិយោទាតោ កតមេនាយស្មា
សារីបុត្តោ អជ្ជ វិហារេន វិហាសីតិ ។ ឥធាហំ អាវុ-
សោ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម
សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហាសឹ ។ តស្ស
មយ្ហំ អាវុសោ ន ឯវំ ហោតិ អហំ សញ្ញាវេទ-
យិតនិរោធំ សមាបជ្ជាមីតិ វា អហំ សញ្ញាវេទយិត-
និរោធំ សមាបន្នោតិ វា អហំ សញ្ញាវេទយិតនិរោ-
ធា វុដ្ឋិតោតិ វាតិ ។ តថា ហិ បនាយស្មតោ
សារីបុត្តស្ស ទីឃរត្តំ អហង្ការមមង្ការមានានុសយា
សុសមូហតា តស្មា អាយស្មតោ សារីបុត្តស្ស ន ឯវំ
ហោតិ អហំ សញ្ញាវេទយិតនិរោធំ សមាបជ្ជាមីតិ វា
អហំ សញ្ញាវេទយិតនិរោធំ សមាបន្នោតិ វា អហំ
សញ្ញាវេទយិតនិរោធា វុដ្ឋិតោតិ វាតិ ។

ម្នាលអាវុសោសារីបុត្ត ឥន្ទ្រិយរបស់លោកជ្រះថ្លា សម្បុរមុខក៏ស្អាតផូរ-
ផង់ ព្រះសារីបុត្តមានអាយុ ក្នុងថ្ងៃនេះ តើគង់នៅដោយធម៌ជាគ្រឿង
នៅដូចម្តេច ។ ម្នាលអាវុសោ ក្នុងទីឯណោះ ខ្ញុំបានកន្លងបង់នូវនេវ-
សញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានចូលសញ្ញាវេទ-
យិតនិរោធ ហើយសម្រេចសម្រាន្តនៅ ។ ម្នាលអាវុសោ ខ្ញុំនោះ មិន
មានសេចក្តីបរិវិតក្កយ៉ាងនេះថា អាត្មាអញកំពុងចូលសញ្ញាវេទយិតនិរោធ
ឬថា អាត្មាអញបានចូលសញ្ញាវេទយិតនិរោធហើយ ឬក៏ថា អាត្មាអញ
បានចេញអំពីសញ្ញាវេទយិតនិរោធ ដូច្នេះឡើយ ។ ព្រះអានន្ទតបថា
ពិតដូច្នោះមែន ដ្បិតព្រះសារីបុត្តមានអាយុបានគាស់រំលើងនូវអនុស័យគឺ
សេចក្តីប្រកាន់ថាអញ ថារបស់អញ អស់កាលយូរមកហើយ ព្រោះ
ហេតុនោះ បានជាព្រះសារីបុត្តមានអាយុ មិនមានសេចក្តីត្រិះរិះយ៉ាងនេះ
ថា អាត្មាអញកំពុងចូលសញ្ញាវេទយិតនិរោធ ឬថា អាត្មាអញបានចូល
សញ្ញាវេទយិតនិរោធហើយ ឬក៏ថា អាត្មាអញបានចេញអំពីសញ្ញាវេទ-
យិតនិរោធ ដូច្នេះឡើយ ។

## សារីបុត្តសំយុត្តំ

(២៦៥) ឯកំ សមយំ អាយស្មា សារីបុត្តោ រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ អាយស្មា សារីបុត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ រាជគហេ សបទានំ បិណ្ឌាយ ចរិត្វា តំ បិណ្ឌបាតំ អញ្ញតរំ កុឌ្ឌមូលំ(១) និស្សាយ ភុញ្ជតិ ។ អថខោ សុចិមុខី បរិព្វាជិកា យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោច កឹ នុ ខោ សមណ អធោមុខោ ភុញ្ជសីតិ ។ ន ខ្វាហំ ភគិនិ អធោមុខោ ភុញ្ជាមីតិ ។ តេនហិ សមណ ឧព្ភមុខោ ភុញ្ជសីតិ ។ ន ខ្វាហំ ភគិនិ ឧព្ភមុខោ ភុញ្ជាមីតិ ។ តេនហិ សមណ ទិសាមុខោ ភុញ្ជសីតិ ។ ន ខ្វាហំ ភគិនិ ទិសាមុខោ ភុញ្ជាមីតិ ។ តេនហិ សមណ

---

១ ឱ. កុឌ្ឌំ ។

## សារីបុត្តសំយុត្ត

(២៤៥) សម័យមួយ ព្រះសារីបុត្តមានអាយុ គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យហើយចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត លុះចូលទៅបិណ្ឌបាតតាមលំដាប់ច្រកក្នុងក្រុងរាជគ្រឹះហើយ បាននៅគង់អាស្រ័យ ក្បែរជើងជញ្ជាំងមួយ ឆាន់ចង្ហាន់បិណ្ឌបាតនោះ ។ គ្រានោះ បរិព្វាជិកាឈ្មោះសូចិមុខី បានចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះសារីបុត្តមានអាយុដូច្នេះថា បពិត្រសមណៈលោកឱនមុខឆាន់ឬអ្វី ។ នែប្អូនស្រី អាត្មាមិនមែនឱនមុខឆាន់ទេ ។ បពិត្រសមណៈ បើដូច្នោះ លោកងើយមុខឆាន់ឬ ។ ម្នាលប្អូនស្រី អាត្មាមិនមែនងើយមុខឆាន់ទេ ។ បពិត្រសមណៈ បើដូច្នោះ លោកបែរមុខទៅកាន់ទិសធំ (ទាំងបួន) ឆាន់ឬអ្វី ។ ម្នាលប្អូនស្រី អាត្មាមិនមែនបែរមុខទៅកាន់ទិសធំឆាន់ទេ ។ បពិត្រសមណៈ បើដូច្នោះ

វិទិសាមុខោ ភុញ្ជសីតិ ។ ន ខ្វាហំ ភគិនិ វិទិសាមុខោ ភុញ្ជាមីតិ ។ កឹ នុ សមណ អធោមុខោ ភុញ្ជសីតិ ឥតិ បុដ្ឋោ សមានោ ន ខ្វាហំ ភគិនិ អធោមុខោ ភុញ្ជាមីតិ វទេសិ តេនហិ សមណ ឧព្ភមុខោ ភុញ្ជសីតិ ឥតិ បុដ្ឋោ សមានោ ន ខ្វាហំ ភគិនិ ឧព្ភមុខោ ភុញ្ជាមីតិ វទេសិ តេនហិ សមណ ទិសាមុខោ ភុញ្ជសីតិ ឥតិ បុដ្ឋោ សមានោ ន ខ្វាហំ ភគិនិ ទិសាមុខោ ភុញ្ជាមីតិ វទេសិ តេនហិ សមណ វិទិសាមុខោ ភុញ្ជសីតិ ឥតិ បុដ្ឋោ សមានោ ន ខ្វាហំ ភគិនិ វិទិសាមុខោ ភុញ្ជាមីតិ វទេសិ កថញ្ចរហិ សមណ ភុញ្ជសីតិ ។ យេ ហិ កេចិ ភគិនិ សមណព្រាហ្មណា វត្ថុវិជ្ជាតិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ឥមេ វុច្ចន្តិ ភគិនិ សមណព្រាហ្មណា អធោមុខា ភុញ្ជន្តិ ។

លោកងាកមុខទៅកាន់ទិសតូច (ទាំងបួន) ឆាន់ឬអ្វី ។ ម្នាលប្អូនស្រី អាត្មាមិនមែនងាកមុខទៅកាន់ទិសតូចឆាន់ទេ ។ ចុះព្រោះហេតុដូចម្តេច កាលដែលខ្ញុំសួរលោកថា បពិត្រសមណៈ លោកឱនមុខឆាន់ឬអ្វី លោកឆ្លើយថា នែប្អូនស្រី អាត្មាមិនមែនឱនមុខឆាន់ទេ កាលដែលខ្ញុំសួរលោកថា បពិត្រសមណៈ បើដូច្នោះ លោកងើយមុខឆាន់ឬអ្វី លោកឆ្លើយថា នែប្អូនស្រី អាត្មាមិនមែនងើយមុខឆាន់ទេ កាលដែលខ្ញុំសួរលោកថា បពិត្រសមណៈ បើដូច្នោះ លោកបែរមុខទៅកាន់ទិសធំឆាន់ ឬអ្វី លោកឆ្លើយថា នែប្អូនស្រី អាត្មាមិនមែនបែរមុខទៅកាន់ទិសធំឆាន់ទេ កាលដែលខ្ញុំសួរថា បពិត្រសមណៈ បើដូច្នោះ លោកងាកមុខទៅកាន់ទិសតូចឆាន់ឬអ្វី លោកឆ្លើយថា នែប្អូនស្រី អាត្មាមិនមែនងាកមុខទៅកាន់ទិសតូចឆាន់ទេ បពិត្រសមណៈ ចុះលោកឆាន់ដូចម្តេចវិញ ។ នែប្អូនស្រី ពួកសមណព្រាហ្មណ៍ណានីមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាមើលទាយចំការទីដី ម្នាលប្អូនស្រី សមណព្រាហ្មណ៍ពួកនេះ ហៅថាអ្នកឱនមុខឆាន់ ។

## សារីបុត្តសំយុត្តំ

យេ ហិ កេចិ ភគិនិ សមណព្រាហ្មណា នក្ខត្ត-
វិជ្ជាតិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ឥមេ
វុច្ចន្តិ ភគិនិ សមណព្រាហ្មណា ឧព្ភមុខា ភុញ្ជន្តិ ។
យេ ហិ កេចិ ភគិនិ សមណព្រាហ្មណា ទូតេយ្យប្ប-
ហិណគមនានុយោគា មិច្ឆាជីវេន ជីវិកំ កប្បេន្តិ
ឥមេ វុច្ចន្តិ ភគិនិ សមណព្រាហ្មណា ទិសាមុខា
ភុញ្ជន្តិ ។ យេ ហិ កេចិ ភគិនិ សមណព្រាហ្មណា
អង្គវិជ្ជាតិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ឥ-
មេ វុច្ចន្តិ ភគិនិ សមណព្រាហ្មណា វិទិសាមុខា
ភុញ្ជន្តិ ។ សោ ខ្វាហំ ភគិនិ ន វត្ថុវិជ្ជាតិរច្ឆានវិជ្ជាយ
មិច្ឆាជីវេន ជីវិកំ កប្បេមិ ន នក្ខត្តវិជ្ជាតិរច្ឆាន-
វិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេមិ ន ទូតេយ្យប្ប-
ហិណគមនានុយោគា មិច្ឆាជីវេន ជីវិកំ កប្បេមិ
ន អង្គវិជ្ជាតិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេមិ
ធម្មេន ភិក្ខំ បរិយេសាមិ ធម្មេន ភិក្ខំ បរិយេសិត្វា

ម្នាលប្អូនស្រី ពួកសមណព្រាហ្មណ៍ណាមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាមើលខាងនក្ខត្តឫក្ស នែប្អូនស្រី សមណព្រាហ្មណ៍ពួកនេះ ហៅថាអ្នកងើយមុខឆាន់ នែប្អូនស្រី ពួកសមណព្រាហ្មណ៍ណាមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះការប្រកបរឿយៗ នូវទូតកម្មនិងការបញ្ជូនដំណឹង នែប្អូនស្រី សមណព្រាហ្មណ៍ពួកនេះ ហៅថាបែរមុខទៅកាន់ទិសធំឆាន់ ។ នែប្អូនស្រី ពួកសមណព្រាហ្មណ៍ណាមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាមើលខាងអង្គសម្បត្តិ (ទាយលក្ខណៈ) នែប្អូនស្រី សមណព្រាហ្មណ៍ពួកនេះ ហៅថាបែរមុខទៅកាន់ទិសតូចឆាន់ ។ នែប្អូនស្រី អាត្មាមិនមែនចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាមើលទាយបំការទេ អាត្មាមិនមែនចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាទាយនក្ខត្តឫក្សទេ អាត្មាមិនមែនចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះការប្រកបរឿយៗ នូវទូតកម្មនិងការបញ្ជូនដំណឹងទេ អាត្មាមិនមែនចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាទាយអង្គសម្បត្តិទេ អាត្មាតែងស្វែងរកភិក្ខាដោយធម៌ លុះស្វែងរកភិក្ខាបានដោយធម៌ហើយ

ភុញ្ជាមីតិ ។ អថខោ សូចិមុខី បរិព្វាជិកា រាជគហេ រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា ឯវមារោចេសិ ធម្មិកំ សមណា សក្យបុត្តិយា អាហារំ អាហារេន្តិ អនវជ្ជំ សមណា សក្យបុត្តិយា អាហារំ អាហារេន្តិ ទេថ សមណានំ សក្យបុត្តិយានំ បិណ្ឌន្តិ ។

សារីបុត្តសំយុត្តំ ។

## តស្សុទ្ទានំ

វិវេកំ អវិតក្កំ ច
បីតិ ឧបេក្ខា ចតុត្ថំ(១)
អាកាសញ្ចេវ វិញ្ញាណំ
អាកិញ្ចេ នេវសញ្ញិតា(២)
និរោធោ នវមោ វុត្តោ
ទសមំ សូចិមុខី ចាតិ ។

១ ឱ. ម. បត្តកំ ។ ២ អាកិញ្ចញ្ញេវសញ្ញិតា ។

ទើបនាំ ។ គ្រានោះ សុចិមុខីបរិព្វាជិកា ចេញអំពីច្រកចូលទៅកាន់ច្រក ចេញពីផ្លូវត្រៀងកែងចូលទៅកាន់ផ្លូវត្រៀងកែង ក្នុងក្រុងរាជគ្រឹះ ប្រាប់គេយ៉ាងនេះថា សមណសក្យបុត្រទាំងឡាយ តែងនាំអាហារប្រកបដោយធម៌ សមណសក្យបុត្រទាំងឡាយ តែងនាំអាហារដែលមិនមានទោស អ្នកទាំងឡាយ ចូរប្រគេនដុំបាយដល់ពួកសមណសក្យបុត្រផងចុះ ។

ចប់ សារីបុត្តសំយុត្ត ។

## ឧទ្ទាននៃសារីបុត្តសំយុត្តនោះគឺ

និយាយអំពី បឋមជ្ឈានប្រកបដោយវិវេក ១ ទុតិយជ្ឈានមិនមានវិតក្កៈ ១ តតិយជ្ឈានប្រាសចាកបីតិ ១ ចតុត្ថជ្ឈានប្រកបដោយឧបេក្ខា ១ អាកាសានញ្ចាយតនជ្ឈាន ១ វិញ្ញាណញ្ចាយតនជ្ឈាន ១ អាកិញ្ចញ្ញាយតនជ្ឈាន ១ នេវសញ្ញានាសញ្ញាយតនជ្ឈាន ១ សញ្ញាវេទយិតនិរោធ ជាគម្រប់ប្រាំបួន ១ គម្រប់ ១០ និងរឿងសុចិមុខីបរិព្វាជិកា ។

# នាគសំយុត្តំ

[៣៤៦] សាវត្ថី ។ តត្រ ខោ ។ ចតស្សោ ឥមា ភិក្ខវេ នាគយោនិយោ ។ កតមា ចតស្សោ ។ អណ្ឌជា នាគា ជលាពុជា នាគា សំសេទជា នាគា ឧបបាតិកា នាគា ។ ឥមា ខោ ភិក្ខវេ ចតស្សោ នាគយោនិយោតិ ។

[២៤៧] សាវត្ថី ។ ចតស្សោ ឥមា ភិក្ខវេ នាគយោនិយោ ។ កតមា ចតស្សោ ។ អណ្ឌជា នាគា ជលាពុជា នាគា សំសេទជា នាគា ឧបបាតិកា នាគា ។ តត្រ ភិក្ខវេ អណ្ឌជេហិ នាគេហិ ជលាពុជា ច សំសេទជា ច ឧបបាតិកា ច នាគា បណីតតរា ។ តត្រ ភិក្ខវេ អណ្ឌជេហិ ច ជលាពុជេហិ ច នាគេហិ សំសេទជា ច ឧបបាតិកា ច នាគា បណីតតរា ។

# នាគសំយុត្ត

( ១៤៦ ) ក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កំណើតរបស់នាគនេះមាន ៤ យ៉ាង ។ ចុះកំណើត ៤ គឺអ្វីខ្លះ ។ កំណើត ៤ គឺ ពួកនាគជាអណ្ឌជៈកំណើត ១ ពួកនាគជាជលាពុជៈកំណើត ១ ពួកនាគជាសំសេទជៈកំណើត ១ ពួកនាគជាឱបបាតិកៈកំណើត ១ ។ ម្នាលភិក្ខុទាំងឡាយ កំណើតរបស់នាគ មាន ៤ យ៉ាងនេះឯង ។

( ២៤៧ ) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កំណើតរបស់នាគនេះ មាន ៤ យ៉ាង ។ ចុះកំណើត ៤ គឺអ្វីខ្លះ ។ កំណើត ៤ គឺ ពួកនាគជាអណ្ឌជៈកំណើត ១ ពួកនាគជាជលាពុជៈកំណើត ១ ពួកនាគជាសំសេទជៈកំណើត ១ ពួកនាគជាឱបបាតិកៈកំណើត ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្តានាគទាំងនោះ ពួកនាគជាជលាពុជៈកំណើតក្តី ពួកនាគជាសំសេទជៈកំណើតក្តី ពួកនាគជាឱបបាតិកៈកំណើតក្តី ប្រសើរជាងពួកនាគជាអណ្ឌជៈកំណើត ។ ម្នាលភិក្ខុទាំងឡាយ បណ្តានាគទាំងនោះ ពួកនាគជាសំសេទជៈកំណើតក្តី ពួកនាគជាឱបបាតិកៈកំណើតក្តី ប្រសើរជាងពួកនាគជាអណ្ឌជៈកំណើតនិងពួកនាគជាជលាពុជៈកំណើត ។

តត្រ ភិក្ខវេ អណ្ឌជេហិ ច ជលាពុជេហិ ច សំសេទជេហិ ច នាគេហិ ឧបបាតិកា នាគា បណីតតរា ។ ឥមា ខោ ភិក្ខវេ ចតស្សោ នាគយោនិយោតិ ។

(២៤៨) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចេ អណ្ឌជា នាគា ឧបោសថំ ឧបវសន្តិ វោស្សដ្ឋកាយា(១) ច ភវន្តីតិ ។ ឥធ ភិក្ខុ ឯកច្ចានំ អណ្ឌជានំ នាគានំ ឯវំ ហោតិ មយំ ខោ បុព្វេ កាយេន ទ្វយការិនោ អហុម្ហា វាចាយ ទ្វយការិនោ មនសា ទ្វយការិនោ តេ មយំ

១ ឱ. ឱស្សដ្ឋកាយា ប ។

ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកនាគទាំងនេះ ពួកនាគជាឧបបាតិកៈកំណើត ប្រសើរជាងពួកនាគជាអណ្ឌជៈកំណើតផង ជាងពួកនាគជាជលាពុជៈកំណើតផង ជាងពួកនាគជាសំសេទជៈកំណើតផង ។ ម្នាលភិក្ខុទាំងឡាយ កំណើតរបស់នាគ មាន ៤ យ៉ាងនេះឯង ។

(២៤៨) សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ មានភិក្ខុមួយរូប បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យពួកនាគខ្លះជាអណ្ឌជៈកំណើត ក្នុងលោកនេះ រក្សាឧបោសថផង មានកាយដ៏ស្ងួត (ព្រោះមិនអើពើនឹងសេចក្ដីអន្តរាយអំពីអាលម្ពាយន៍) ផង ។ ម្នាលភិក្ខុ ពួកនាគជាអណ្ឌជៈខ្លះក្នុងលោកនេះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលពីដើម ពួកយើងធ្វើអំពើទាំងពីរគឺកុសលនិងអកុសលដោយកាយ ធ្វើអំពើទាំងពីរគឺកុសលនិងអកុសលដោយវាចា ធ្វើអំពើទាំងពីរគឺកុសលនិងអកុសលដោយចិត្ត ពួកយើងទាំងនោះ (ព្រោះតែ)

កាយេន ទ្វយការិនោ វាចាយ ទ្វយការិនោ មនសា ទ្វយការិនោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ នាគានំ សហព្យតំ ឧបបន្នា សចេ មយំ កាយេន សុចរិតំ ចរេយ្យាម វាចាយ សុចរិតំ ចរេយ្យាម មនសា សុចរិតំ ចរេយ្យាម ឯវំ មយំ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យាម ហន្ទ មយំ ឯតរហិ កាយេន សុចរិតំ ចរាម វាចាយ សុចរិតំ ចរាម មនសា សុចរិតំ ចរាមាតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ អណ្ឌជា នាគា ឧបោសថំ ឧបវសន្តិ វោស្សដ្ឋកាយា ច ភវន្តីតិ ។

(២៤៩) សាវត្ថី ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា ។បេ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចេ ជលាពុជា នាគា ឧបោសថំ ឧបវសន្តិ វោស្សដ្ឋកាយា ច ភវន្តីតិ ។ (សព្វំ វិត្ថា-

ធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកនាគជាអណ្ឌជៈកំណើត ប្រសិនបើឥឡូវនេះ ពួកយើងប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះពួកយើងបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ នឹងបានទៅកើតក្នុងសុគតិសួគ៌ទេវលោក ដោយហេតុយ៉ាងនេះពុំខាន បើដូច្នោះមានតែ ពួកយើង ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យពួកនាគខ្លះជាអណ្ឌជៈកំណើតក្នុងលោកនេះ រក្សាឧបោសថផង មានកាយដ៏ស្និទ្ធ (ព្រោះមិនអើពើនឹងសេចក្តីអន្តរាយអំពីអាលម្ពាយន៍ ) ផង ។

[ ៤៤៩ ] ក្រុងសាវត្ថី ។ គ្រានោះ មានភិក្ខុមួយរូប (ចូលទៅគាល់) ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកនាគខ្លះជាជលាពុជៈកំណើតក្នុងលោកនេះ រក្សាឧបោសថផង មានកាយដ៏ស្និទ្ធ (ព្រោះមិនអើពើនឹងសេចក្តីអន្តរាយអំពីអាលម្ពាយន៍ ) ផង ។ (សេចក្តីទាំងអស់

រេតព្វំ) ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ ជលាពុជា នាគា ឧបោសថំ ឧបវសន្តិ វោស្សដ្ឋកាយា ច ភវន្តីតិ ។

(២៨០) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចេ សំសេទជា នាគា ឧបោសថំ ឧបវសន្តិ វោស្សដ្ឋកាយា ច ភវន្តីតិ ។ (សព្វំ វិត្ថារេតព្វំ) ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ សំសេទជា នាគា ឧបោសថំ ឧបវសន្តិ វោស្សដ្ឋកាយា ច ភវន្តីតិ ។

បណ្ឌិតគប្បីឲ្យពិស្តារផងចុះ) ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យពួកនាគខ្លះជាផលាពុផ:កំណើតក្នុងលោកនេះ រក្សាឧបោសថផង មានកាយដ៏ស្អិទ្ធ (ព្រោះមិនអើពើនឹងសេចក្តីអន្តរាយអំពីអាលម្ពាយន៍) ផង ។

[ ២៩០ ] ក្រុងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកនាគខ្លះជាសំសេទជ:កំណើតក្នុងលោកនេះ រក្សាឧបោសថផង មានកាយដ៏ស្អិទ្ធ ( ព្រោះមិនអើពើនឹងសេចក្តីអន្តរាយអំពីអាលម្ពាយន៍ ) ផង ( សេចក្តីទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ) ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យពួកនាគខ្លះជាសំសេទជ:កំណើតក្នុងលោកនេះ រក្សាឧបោសថផង មានកាយដ៏ស្អិទ្ធ (ព្រោះមិនអើពើនឹងសេចក្តីអន្តរាយអំពីអាលម្ពាយន៍) ផង ។

(២៥៣) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចេ ឧបោសថិកា នាគា ឧបោសថំ ឧបវសន្តិ វោស្សដ្ឋកាយា ច ភវន្តីតិ ។ ឥធ ភិក្ខុ ឯកច្ចានំ ឧបោសថិកានំ នាគានំ ឯវំ ហោតិ មយំ ខោ បុព្វេ កាយេន ទ្វយការិនោ អហុម្ហ វាចាយ ទ្វយការិនោ មនសា ទ្វយការិនោ តេ មយំ កាយេន ទ្វយការិនោ វាចាយ ទ្វយការិនោ មនសា ទ្វយការិនោ កាយស្ស ភេទា បរំ មរណា ឧបោសថិកានំ នាគានំ សហព្យតំ ឧបបន្នា សចេ មយំ កាយេន សុចរិតំ ចរេយ្យាម វាចាយ សុចរិតំ ចរេយ្យាម មនសា សុចរិតំ ចរេយ្យាម ឯវំ មយំ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យាម ហន្ទ មយំ

(២៥១) ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរ ហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកនាគខ្លះ ជាឧបបាតិកៈកំណើតក្នុងលោកនេះ រក្សាឧបោសថផង មានកាយដ៏ស្ងួត (ព្រោះមិនអើពើនឹងសេចក្តីអន្តរាយអំពីអាលម្ពាយន៍) ផង ។ ម្នាលភិក្ខុ ពួកនាគខ្លះជាឧបបាតិកៈកំណើតក្នុងលោកនេះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីដើម ពួកយើងធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត ព្រោះពួកយើងទាំងនោះ ធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត លុះបែកធ្លាយរាងកាយ បន្ទាប់អំពីស្លាប់ទៅ ក៏បានកើតជាមួយនឹងពួកនាគជាឧបបាតិកៈកំណើត បើក្នុងកាលឥឡូវនេះ ពួកយើងប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះពួកយើងបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោកដោយហេតុយ៉ាងនេះពុំខាន បើដូច្នោះមានតែ ពួកយើង

ឯតរហិ កាយេន សុចរិតំ ចរាម វាចាយ សុចរិតំ ចរាម មនសា សុចរិតំ ចរាមាតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ ឱបបាតិកា នាគា ឧបោសថំ ឧបវសន្តិ វោស្សដ្ឋកាយា ច ភវន្តីតិ ។

(១៥២) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ នាគានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន ទ្វយការី ហោតិ វាចាយ ទ្វយការី មនសា ទ្វយការី តស្ស សុតំ ហោតិ អណ្ឌជា នាគា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ នាគានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ នាគានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ

ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងកាលឥឡូវនេះក៏ខាន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យពួកនាគខ្លះ ជាឧបបាតិកៈកំណើត ក្នុងលោកនេះ រក្សាឧបោសថផង មានកាយដ៏ស្ងួត (ព្រោះមិនអើពើនឹងសេចក្តីអន្តរាយអំពីអាលម្ពាយន៍) ផង ។

[២៥២] ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅខាងមុខ ទៅកើតជាមួយនឹងពួកនាគ ជាអណ្ឌជៈកំណើត ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត បុគ្គលនោះ បានឮថា ពួកនាគជាអណ្ឌជៈកំណើតមានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញដល់បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកនាគជាអណ្ឌជៈកំណើត ។ បុគ្គលនោះដល់រំលាងខន្ធ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ក៏បានទៅកើតជាមួយនឹងពួកនាគ ជាអណ្ឌជៈកំណើតមែន ។ ម្នាលភិក្ខុ នេះជាហេតុ

អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ នាគានំ សហព្យតំ ឧបបជ្ជតិ ។

(២៥៣) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ជលាពុជានំ នាគានំ សហព្យតំ ឧបបជ្ជតិ ។បេ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ជលាពុជានំ នាគានំ សហព្យតំ ឧបបជ្ជតិ ។

(២៥៤) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា សំសេទជានំ នាគានំ សហព្យតំ ឧបបជ្ជតិ ។បេ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា សំសេទជានំ នាគានំ សហព្យតំ ឧបបជ្ជតិ ។

នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ បានទៅកើតជាមួយនឹងពួកនាគ ជាអណ្ឌជៈកំណើត ។

[៤៩៣] ក្រុងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ បានទៅកើតជាមួយនឹងពួកនាគជាជលាពុជៈកំណើត ។ បេ ។ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតជាមួយនឹងពួកនាគជាជលាពុជៈកំណើត ។

[៤៩៤] ក្រុងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតជាមួយនឹងពួកនាគជាសំសេទជៈកំណើត ។ បេ ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតជាមួយនឹងពួកនាគជាសំសេទជៈកំណើត ។

(២៨៨) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ឱបបាតិកានំ នាគានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន ទ្វយការី ហោតិ វាចាយ ទ្វយការី មនសា ទ្វយការី តស្ស សុតំ ហោតិ ឱបបាតិកា នាគា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា ឱបបាតិកានំ នាគានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ កាយស្ស ភេទា បរំ មរណា ឱបបាតិកានំ នាគានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ឱបបាតិកានំ នាគានំ សហព្យតំ ឧបបជ្ជតីតិ ។

( ២៥៥ ) ក្រុងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតជាមួយនឹងពួកនាគជាឧបបាតិកៈកំណើត ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត បុគ្គលនោះ បានឮថា ពួកនាគជាឧបបាតិកៈកំណើត មានអាយុវែង មានសម្បុរល្អ មានសេចក្ដីសុខច្រើន ។ បុគ្គលនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ អាត្មាអញដល់បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកនាគ ជាឧបបាតិកៈកំណើត ។ ដល់បុគ្គលនោះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកនាគ ជាឧបបាតិកៈកំណើតមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតជាមួយនឹងពួកនាគ ជាឧបបាតិកៈកំណើត ។

(៤៩៦) សាវត្ថិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ នាគានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន ទ្វយការី ហោតិ វាចាយ ទ្វយការី មនសា ទ្វយការី តស្ស សុតំ ហោតិ អណ្ឌជា នាគា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ នាគានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ អន្នំ ទេតិ បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ គន្ធំ ទេតិ វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតិ ។ សោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ នាគានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ នាគានំ សហព្យតំ ឧបបជ្ជតីតិ ។

នាគសំយុត្ត

[ ២៥៦ ] ក្រុងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតជាមួយនឹងពួកនាគជាអណ្ឌជៈកំណើត ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត បុគ្គលនោះបានឮថា ពួកនាគជាអណ្ឌជៈកំណើតមានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ ដល់បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកនាគជាអណ្ឌជៈកំណើត ។ ទើបបុគ្គលនោះឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយានជំនិះ ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសម្រាប់សំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ។ លុះបុគ្គលនោះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកនាគជាអណ្ឌជៈកំណើតមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតជាមួយនឹងពួកនាគជាអណ្ឌជៈកំណើត ។

(២៤៧) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ជលាពុជានំ នាគានំ ។បេ។ សំសេទជានំ នាគានំ ។ ឱបបាតិកានំ នាគានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន ទ្វយការី ហោតិ វាចាយ ទ្វយការី មនសា ទ្វយការី តស្ស សុតំ ហោតិ ឱបបាតិកា នាគា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា ឱបបាតិកានំ នាគានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ អន្នំ ទេតិ បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ គន្ធំ ទេតិ វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតិ ។ សោ កាយស្ស ភេទា

(៤៩៧) ក្រុងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតជាមួយនឹងពួកនាគជាជលាពុជៈកំណើត ។ បេ ។ នឹងពួកនាគជាសំសេទជៈកំណើត ។ ទៅកើតជាមួយនឹងពួកនាគជាឧបបាតិកៈកំណើត ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត បុគ្គលនោះ បានឮថា ពួកនាគជាឧបបាតិកៈកំណើតមានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ ដល់បែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកនាគជាឧបបាតិកៈកំណើត ។ បុគ្គលនោះក៏ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយានជំនិះ ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសម្រាប់សំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ។ លុះបុគ្គលនោះបែកធ្លាយរាង-

បរំ មរណា ឧបបាតិកានំ នាគានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ឧបបាតិកានំ នាគានំ សហព្យតំ ឧបបជ្ជតីតិ ។ (ឥមិនា បេយ្យាលេន សហ ទស សុត្តន្តា វិត្ថារា ចតូសុ យោនីសុ ចត្តាឡីសំ វេយ្យាករណា កាតញ្ញ ទស សុត្តន្តា ហោន្តិ បណ្ណាសំ សុត្តន្តា ហោន្តិ) ។

នាគសំយុត្តំ ។

## តស្សុទ្ទានំ

សុទ្ធកញ្ច[១] បណីតតរំ
ចតុធា ច ឧបោសថា
តស្ស សុតំ ចតុធា ច
ទានូបការេ ចតុធា
នាគេហិ សុប្បកាសិតាតិ ។

១ ឱ. ម. សុទ្ធិកញ្ច ។

កាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកនាគជាឧបបាតិកៈកំណើតមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតជាមួយនឹងពួកនាគជាឧបបាតិកៈកំណើត ។ (សូត្រ ១០ ព្រមទាំងបេយ្យាលនេះ មានសេចក្តីពិស្តារហើយ វេយ្យាករណ៍ ៤០ ក្នុងកំណើតទាំង ៤ មានសូត្រ ១០ មានសូត្រ ៥០ ) ។

ចប់ នាគសំយុត្ត ។

## ឧទ្ទានក្នុងនាគសំយុត្តនោះ គឺ

និយាយអំពីកំណើតនាគសុទ្ធ ១ កំណើតនាគប្រសើរជាងគ្នា
ជាលំដាប់ ១ នាគរក្សាឧបោសថមាន ៤ លើក បុគ្គលនោះ
បានឮកំណើតនាគមាន ៤ លើក ឧបការទានមាន ៤ លើក
ដែលទ្រង់ប្រកាសល្អហើយដោយរឿងនាគ ។

# សុបណ្ណសំយុត្តំ

[២៤៨] សាវត្ថី ។ តត្រ ខោ ។ ចតស្សោ ឥមា ភិក្ខវេ សុបណ្ណយោនិយោ ។ កតមា ចតស្សោ ។ អណ្ឌជា សុបណ្ណា ជលាពុជា សុបណ្ណា សំសេទជា សុបណ្ណា ឱបបាតិកា សុបណ្ណា ។ ឥមា ខោ ភិក្ខវេ ចតស្សោ សុបណ្ណយោនិយោតិ ។

[២៤៩] សាវត្ថី ។ ចតស្សោ ឥមា ភិក្ខវេ សុបណ្ណយោនិយោ ។ កតមា ចតស្សោ ។ អណ្ឌជា សុបណ្ណា ជលាពុជា សុបណ្ណា សំសេទជា សុបណ្ណា ឱបបាតិកា សុបណ្ណា ។ តត្រ ភិក្ខវេ អណ្ឌជា សុបណ្ណា អណ្ឌជេ នាគេ ហរន្តិ ន ជលាពុជេ ន សំសេទជេ ន ឱបបាតិកេ ។ តត្រ ភិក្ខវេ ជលាពុជា សុបណ្ណា អណ្ឌជេ ច ជលាពុជេ ច នាគេ ហរន្តិ ន សំសេទជេ ន ឱបបាតិកេ ។ តត្រ ភិក្ខវេ

# សុបណ្ណសំយុត្ត

(៤៥៨) ក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កំណើតគ្រុឌនេះ មាន ៤ ។ ចុះកំណើតគ្រុឌទាំង ៤ គឺអ្វីខ្លះ ។ គឺពួកគ្រុឌជាអណ្ឌជៈកំណើត ១ ពួកគ្រុឌជាជលាពុជៈកំណើត ១ ពួកគ្រុឌជាសំសេទជៈកំណើត ១ ពួកគ្រុឌជាឧបបាតិកៈកំណើត ១ ។ ម្នាលភិក្ខុទាំងឡាយ កំណើតគ្រុឌមាន ៤ នេះឯង ។

(៤៥៩) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កំណើតគ្រុឌនេះមាន ៤ ។ ចុះកំណើតគ្រុឌទាំង ៤ គឺអ្វីខ្លះ ។ គឺពួកគ្រុឌជាអណ្ឌជៈកំណើត ១ ពួកគ្រុឌជាជលាពុជៈកំណើត ១ ពួកគ្រុឌជាសំសេទជៈកំណើត ១ ពួកគ្រុឌជាឧបបាតិកៈកំណើត ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាគ្រុឌទាំងនោះ គ្រុឌជាអណ្ឌជៈកំណើត ឆាបបានតែពួកនាគជាអណ្ឌជៈកំណើត ឆាបពួកនាគជាជលាពុជៈកំណើតមិនបាន ឆាបពួកនាគជាសំសេទជៈកំណើតមិនបាន ឆាបពួកនាគជាឧបបាតិកៈកំណើតមិនបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាគ្រុឌទាំងនោះ ពួកគ្រុឌជាជលាពុជៈកំណើត ឆាបនាគជាអណ្ឌជៈកំណើត និងនាគជាជលាពុជៈកំណើតបាន ឆាបពួកនាគជាសំសេទជៈកំណើតមិនបាន ឆាបពួកនាគជាឧបបាតិកៈកំណើតមិនបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាគ្រុឌទាំងនោះ

សំសេទជា សុបណ្ណា អណ្ឌជេ ច ជលាពុជេ ច
សំសេទជេ ច នាគេ ហរន្តិ ន ឧបបាតិកេ ។ តត្រ
ភិក្ខវេ ឧបបាតិកា សុបណ្ណា អណ្ឌជេ ច ជលាពុជេ
ច សំសេទជេ ច ឧបបាតិកេ ច នាគេ ហរន្តិ ។
ឥមា ខោ ភិក្ខវេ ចតស្សោ សុបណ្ណយោនិយោតិ ។

(២៦០) សាវត្ថី ។ អញ្ញតរោ ភិក្ខុ យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ
ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ
យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា អណ្ឌ-
ជានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ
ឯកច្ចោ កាយេន ទ្វយការី ហោតិ វាចាយ ទ្វយការី
មនសា ទ្វយការី តស្ស សុតំ ហោតិ អណ្ឌជា
សុបណ្ណា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។
តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា

ពួកគ្រុឌជាសំសេទជៈកំណើត ឆាបនាគជាអណ្ឌជៈកំណើត ឆាបនាគជាជលាពុជៈកំណើតនិងនាគជាសំសេទជៈកំណើតបាន ឆាបពួកនាគជាឧបបាតិកៈកំណើតមិនបានទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាគ្រុឌទាំងនោះ ពួកគ្រុឌជាឧបបាតិកៈកំណើត ឆាបពួកនាគជាអណ្ឌជៈកំណើតក៏បាន ឆាបពួកនាគជាជលាពុជៈកំណើតក៏បាន ឆាបពួកនាគជាសំសេទជៈកំណើតក៏បាន ឆាបពួកនាគជាឧបបាតិកៈកំណើតក៏បាន ។ ម្នាលភិក្ខុទាំងឡាយ កំណើតគ្រុឌ មាន ៤ នេះឯង ។

[២៦០] គ្រងសាវត្ថី ។ មានភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកគ្រុឌជាអណ្ឌជៈកំណើតបាន ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត បុគ្គលនោះបានឮថា ពួកគ្រុឌជាអណ្ឌជៈ មានអាយុវែង មានសម្បុរល្អ មានសេចក្ដីសុខច្រើន ។ បុគ្គលនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ អាត្មាអញ ដល់បែកធ្លាយកាយ

បរំ មរណា អណ្ឌជានំ សុបណ្ណានំ សហព្យតំ ឧប-បជ្ជេយ្យន្តិ ។ សោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតីតិ ។

(២៦១) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ជលាពុជានំ សុបណ្ណានំ ។បេ។ សំសេទជានំ សុបណ្ណានំ ។ ឱបបាតិកានំ សុ-បណ្ណានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯ-កច្ចោ កាយេន ទ្វយការី ហោតិ វាចាយ ទ្វយ-ការី មនសា ទ្វយការី តស្ស សុតំ ហោតិ ឱបបាតិកា សុបណ្ណា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។

ស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកគ្រុឌជាអណ្ឌជៈ ។ លុះបុគ្គលនោះបែកធ្លាយកងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកគ្រុឌជាអណ្ឌជៈបានមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយកងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកគ្រុឌជាអណ្ឌជៈ ។

[ ២៦១ ] ក្រុងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយកងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកគ្រុឌជាជលាពុជៈ ។ បេ ។ ពួកគ្រុឌជាសំសេទជៈ ។ ទៅកើតជាមួយនឹងពួកគ្រុឌជាឱបបាតិកៈ ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត បុគ្គលនោះ បានឮថា ពួកគ្រុឌជាឱបបាតិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្ដីសុខច្រើន ។

តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា ឱបបាតិកានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ កាយស្ស ភេទា បរំ មរណា ឱបបាតិកានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ឱបបាតិកានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតីតិ ។

(២៦២) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន ទ្វយការី ហោតិ វាចាយ ទ្វយការី មនសា ទ្វយការី តស្ស សុតំ ហោតិ អណ្ឌជា សុបណ្ណា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ អន្នំ ទេតិ បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ

បុគ្គលនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ ដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានកើតជាមួយនឹងពួកគ្រុឌជាឧប-បាតិកៈ ។ លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកគ្រុឌជាឧបបាតិកៈមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកគ្រុឌជាឧបបាតិកៈ ។

[២៦២] គ្រងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកគ្រុឌជាអណ្ឌជៈ ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត បុគ្គលនោះ បានឮថា ពួកគ្រុឌជាអណ្ឌជៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ ដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកគ្រុឌជាអណ្ឌជៈ ។ បុគ្គលនោះក៏ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយានជំនិះ

មាលំ នេតិ គន្ធំ នេតិ វិលេបនំ នេតិ សេយ្យំ នេតិ អាវសថំ នេតិ បទីបេយ្យំ នេតិ ។ សោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា អណ្ឌជានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតីតិ ។

(២៦៣) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ជលាពុជានំ សុបណ្ណានំ ។បេ។ សំសេទជានំ សុបណ្ណានំ ។ ឧបបាតិកានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន ទ្វយការី ហោតិ វាចាយ ទ្វយការី មនសា ទ្វយការី តស្ស សុតំ ហោតិ ឧបបាតិកា សុបណ្ណា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ

ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ។ លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកគ្រុឌជាអណ្ឌជៈមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកគ្រុឌជាអណ្ឌជៈ ។

[២៦៣] ក្រុងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកគ្រុឌជាជលាពុជៈ ។ បេ ។ ពួកគ្រុឌជាសំសេទជៈ ។ ទៅកើតជាមួយនឹងពួកគ្រុឌជាឱបបាតិកៈ ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត បុគ្គលនោះ បានឮថា ពួកគ្រុឌជាឱបបាតិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ

កាយស្ស ភេទា បរំ មរណា ឧបបត្តិកានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជន្តិ ។ សោ អន្នំ ទេតិ បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ គន្ធំ ទេតិ វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតិ ។ សោ កាយស្ស ភេទា បរំ មរណា ឧបបត្តិកានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ឧបបត្តិកានំ សុបណ្ណានំ សហព្យតំ ឧបបជ្ជតីតិ ។ (ឯវំ បិណ្ឌិតេន ចតុបញ្ញាសំ សុត្តន្តា ហោន្តិ) ។

សុបណ្ណសំយុត្តំ និដ្ឋិតំ ។

តស្សុទ្ទានំ

សុទ្ធកំ ហរន្តិ ចេវ(១)
ទ្វយការី ចតុភេទិ ច
ទានូបការា ចត្តារោ
សុបណ្ណេហិ សុប្បកាសិតាតិ(២) ។

---

១ ឱ. ប. សុទ្ធិកំ ហរន្តិ ចេវ ។ ២ សុបណ្ណសុបកាសិតាតិ ។

ដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកគ្រុឌជាឧបបាតិកៈ ។ បុគ្គលនោះក៏ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយានជំនិះ ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ។ លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកគ្រុឌជាឧបបាតិកៈមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកគ្រុឌជាឧបបាតិកៈ ។ (សូត្រមាន ៤៦ ដោយការរួបរួមយ៉ាងនេះ) ។

ចប់ សុបណ្ណសំយុត្ត ។

## ឧទ្ទានក្នុងសុបណ្ណសំយុត្តនោះគឺ

និយាយអំពីកំណើតគ្រុឌសុទ្ធ ១ គ្រុឌឆាបនាគបាន ១ បុគ្គលធ្វើអំពើទាំងពីរមាន ៤ លើក ឧបការទានមាន ៤ លើក ដែលទ្រង់ប្រកាសហើយដោយរឿងគ្រុឌ ។

# គន្ធព្វកាយសំយុត្តំ

(២៦៤) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។បេ។ ភគវា ឯតទវោច គន្ធព្វកាយិកេ ទេវេ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ ។បេ។ កតមេ ច ភិក្ខវេ គន្ធព្វកាយិកា ទេវា ។ សន្តិ ភិក្ខវេ មូលគន្ធេ អធិវត្ថា ទេវា សន្តិ ភិក្ខវេ សារគន្ធេ អធិវត្ថា ទេវា សន្តិ ភិក្ខវេ ផេគ្គុគន្ធេ អធិវត្ថា ទេវា សន្តិ ភិក្ខវេ តចគន្ធេ អធិវត្ថា ទេវា សន្តិ ភិក្ខវេ បបដិកាគន្ធេ អធិវត្ថា ទេវា សន្តិ ភិក្ខវេ បត្តគន្ធេ អធិវត្ថា ទេវា សន្តិ ភិក្ខវេ បុប្ផគន្ធេ អធិវត្ថា ទេវា សន្តិ ភិក្ខវេ ផលគន្ធេ អធិវត្ថា ទេវា សន្តិ ភិក្ខវេ រសគន្ធេ អធិវត្ថា ទេវា សន្តិ

# គន្ធព្វកាយសំយុត្ត

[២៦៤] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ បេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវទេវតាទាំងឡាយដែលជាពួកគន្ធព្វ(១) ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់រឿងនោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះទេវតាទាំងឡាយជាពួកគន្ធព្វ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតា អាស្រ័យនៅលើឈើមានឫសក្រអូបក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកទេវតាអាស្រ័យនៅលើឈើមានខ្លឹមក្រអូបក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកទេវតាអាស្រ័យនៅលើឈើមានសាច់ស្រាយក្រអូបក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកទេវតា អាស្រ័យនៅលើឈើមានសំបកក្រអូបក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកទេវតាអាស្រ័យនៅលើឈើមានក្រមរក្រអូបក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកទេវតា អាស្រ័យនៅលើឈើមានស្លឹកក្រអូបក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកទេវតាអាស្រ័យនៅលើឈើមានផ្កាក្រអូបក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកទេវតាអាស្រ័យនៅលើឈើមានផ្លែក្រអូបក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកទេវតាអាស្រ័យនៅលើឈើមានរសក្រអូបក៏មាន

---

១ ទេវតាដែលជាអ្នកប្រើប្រាស់នូវវត្ថុមានក្លិនក្រអូប ។

ភិក្ខវេ គន្ធគន្ធេ អធិវត្ថា ទេវា ។ ឥមេ វុច្ចន្តិ ភិក្ខវេ គន្ធព្វកាយិកា ទេវាតិ ។

(៦៦៨) សាវត្ថី ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា ។បេ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា គន្ធព្វកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ តស្ស សុតំ ហោតិ គន្ធព្វកាយិកា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ

ម្នាលភិក្ខុទាំងឡាយ ពួកទេវតាអាស្រ័យនៅលើឈើមានក្លិនក្រអូបទាំងអស់(១)ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទេវតាទាំងឡាយជាពួកគន្ធព្វ ។

[ ៦៦៥ ] ក្រុងសាវត្ថី ។ គ្រានោះឯង មានភិក្ខុមួយរូបចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតាជាពួកគន្ធព្វ ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត បុគ្គលនោះ បានឮថាពួកទេវតាជាពួកគន្ធព្វ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎

១ ឈើដែលមានឫស ខ្លឹម ស្រាយជាដើមក្រអូបទាំងអស់ ។

វោហំ កាយស្ស ភេទា បរំ មរណា គន្ធព្វកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ កាយស្ស ភេទា បរំ មរណា គន្ធព្វកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា គន្ធព្វកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

(២៦៦) សាវត្ថី ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា មូលគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ តស្ស សុតំ ហោតិ មូលគន្ធេ អធិវត្ថា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។

អាត្មាអញ ដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកទេវតាជាពួកគន្ធព្វ ។ លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកទេវតាជាពួកគន្ធព្វមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតាជាពួកគន្ធព្វ ។

(២៦៦) ក្រុងសាវត្ថី ។ គ្រានោះឯង មានភិក្ខុមួយរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានឫសក្រអូប ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត បុគ្គលនោះ បានឮថា ពួកទេវតាដែលអាស្រ័យនៅលើឈើមានឫសក្រអូប មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។

តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា មូលគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧប-បជ្ជេយ្យន្តិ ។ សោ ទាតា ហោតិ មូលគន្ធានំ ។ សោ កាយស្ស ភេទា បរំ មរណា មូលគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា មូលគន្ធេ អធិវត្ថានំ ទេវានំ ស-ហព្យតំ ឧបបជ្ជតីតិ ។

[៦៦៧] សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា

បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ដល់កា ត្មា អញ បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានឫសក្រអូប ៗ បុគ្គលនោះក៏ឲ្យឫសឈើ មានក្លិនក្រអូប ៗ លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើត ជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានឫសក្រអូបមែន ៗ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតាដែលអាស្រ័យ នៅលើឈើមានឫសក្រអូប ៗ

( ២៦៧ ) ក្រុងសាវត្ថី ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វី ជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាង

បរំ មរណា សារគន្ធេ អធិវត្ថានំ ទេវានំ ។បេ។ ផេគ្គុគន្ធេ អធិវត្ថានំ ទេវានំ ។ តចគន្ធេ អធិវត្ថានំ ទេវានំ ។ បបដិកាគន្ធេ អធិវត្ថានំ ទេវានំ ។ បត្តគន្ធេ អធិវត្ថានំ ទេវានំ ។ បុប្ផគន្ធេ អធិវត្ថានំ ទេវានំ ។ ផលគន្ធេ អធិវត្ថានំ ទេវានំ ។ រសគន្ធេ អធិវត្ថានំ ទេវានំ ។ គន្ធគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខវេ(១) ឯកច្ចោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ តស្ស សុតំ ហោតិ សារគន្ធេ អធិវត្ថា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ

១ ភិក្ខុតិ បទំ យុត្តតរំ ។

កាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតាដែលអាស្រ័យនៅលើឈើ មានខ្លឹមក្រអូប ។ បេ ។ នឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានស្រាយក្រអូប ។ នឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានសំបកក្រអូប ។ នឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានក្រមរក្រអូប ។ នឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានស្លឹកក្រអូប ។ នឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានផ្កាក្រអូប ។ នឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានផ្លែក្រអូប ។ នឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានរសក្រអូប ។ ទៅកើតជាមួយនឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានក្លិនក្រអូបទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត បុគ្គលនោះ បានឮថា ពួកទេវតាដែលអាស្រ័យនៅលើឈើមានខ្លឹមក្រអូប មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូច

វតាហំ កាយស្ស ភេទា បរំ មរណា សារគន្ធេ អធិវត្ថានំ ទេវានំ ។ ផេគ្គុគន្ធេ អធិវត្ថានំ ទេវានំ ។ តចគន្ធេ អធិវត្ថានំ ទេវានំ ។ បបដិកគន្ធេ អធិវត្ថានំ ទេវានំ ។ បត្តគន្ធេ អធិវត្ថានំ ទេវានំ ។ បុប្ផគន្ធេ អធិវត្ថានំ ទេវានំ ។ ផលគន្ធេ អធិវត្ថានំ ទេវានំ ។ រសគន្ធេ អធិវត្ថានំ ទេវានំ ។ គន្ធគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ ទាតា ហោតិ សារគន្ធានំ ។ សោ ទាតា ហោតិ ផេគ្គុគន្ធានំ ។ សោ ទាតា ហោតិ តចគន្ធានំ ។ សោ ទាតា ហោតិ បបដិកគន្ធានំ ។ សោ ទាតា ហោតិ បត្តគន្ធានំ ។ សោ ទាតា ហោតិ បុប្ផគន្ធានំ ។ សោ ទាតា ហោតិ ផលគន្ធានំ ។ សោ ទាតា ហោតិ រសគន្ធានំ ។ សោ ទាតា ហោតិ គន្ធគន្ធានំ ។ សោ

គន្ធព្វកាយសំយុត្ត

ម្ដេចហ្ន៎ ដល់អាត្មាអញបែកធ្លាយពីកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានខ្លឹមក្រអូប ។ នឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានស្រាយក្រអូប ។ នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានសំបកក្រអូប ។ នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានក្រមរក្រអូប ។ នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានស្លឹកក្រអូប ។ នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានផ្កាក្រអូប ។ នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានផ្លែក្រអូប ។ នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានរសក្រអូប ។ នឹងបានទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅ លើឈើមានក្លិនក្រអូបទាំងអស់ ។ បុគ្គលនោះក៏ឲ្យខ្លឹមឈើមានក្លិនក្រអូប ។ បុគ្គលនោះក៏ឲ្យស្រាយឈើមានក្លិនក្រអូប ។ បុគ្គលនោះក៏ឲ្យសំបកឈើមានក្លិនក្រអូប ។ បុគ្គលនោះក៏ឲ្យក្រមរឈើមានក្លិនក្រអូប ។ បុគ្គលនោះក៏ឲ្យស្លឹកឈើមានក្លិនក្រអូប ។ បុគ្គលនោះក៏ឲ្យផ្កាឈើមានក្លិនក្រអូប ។ បុគ្គលនោះក៏ឲ្យផ្លែឈើមានក្លិនក្រអូប ។ បុគ្គលនោះ ក៏ឲ្យរសឈើមានក្លិនក្រអូប ។ បុគ្គលនោះក៏ឲ្យឈើមានក្លិនក្រអូបទាំងអស់ ។ លុះបុគ្គលនោះ

កាយស្ស ភេទា បរំ មរណា គន្ធគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា គន្ធគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

(២៦៨) សាវត្ថិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា មូលគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ តស្ស សុតំ ហោតិ មូលគន្ធេ អធិវត្ថា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា មូលគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ អន្នំ ទេតិ បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ គន្ធំ ទេតិ

បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើ មានក្លិនក្រអូបទាំងអស់ ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានក្លិនក្រអូបទាំងអស់ ។

(២៦៨) ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានឫសក្រអូប ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តសុចរិត ដោយកាយ ប្រព្រឹត្តសុចរិត ដោយវាចា ប្រព្រឹត្តសុចរិត ដោយចិត្ត បុគ្គលនោះ បានឮថា ពួកទេវតាដែលអាស្រ័យនៅលើឈើ មានឫសក្រអូប មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ដល់អាត្មាអញ បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានឫសក្រអូប ។ ទើបបុគ្គលនោះឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយានជំនិះ ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប

វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតិ ។ សោ កាយស្ស ភេទា បរំ មរណា មូលគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា មូលគន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

(២៦៩) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា សារគន្ធេ អធិវត្ថានំ ទេវានំ ។បេ។ ផេគ្គុគន្ធេ អធិវត្ថានំ ទេវានំ ។ តចគន្ធេ អធិវត្ថានំ ទេវានំ ។ បបដិកគន្ធេ អធិវត្ថានំ ទេវានំ ។ បត្តគន្ធេ អធិវត្ថានំ ទេវានំ ។

ឲ្យគ្រឿងលាបផ្សេងៗ ឲ្យទីដេក ឲ្យទីសំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ។ លុះបុគ្គលនោះបែកធ្លាយកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅ លើឈើមានឫសក្រអូបមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះ ក្នុងលោកនេះ បែកធ្លាយកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានឫសក្រអូប ។

( ២៦៩ ) ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះ ក្នុងលោកនេះ បែកធ្លាយកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានខ្លឹមក្រអូប ។ បេ ។ នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានស្រាយក្រអូប ។ នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានសំបកក្រអូប ។ នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានក្រមរក្រអូប ។ នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានស្លឹកក្រអូប ។

បុប្ផកេ អភិរត្តានំ ទេវានំ ។ ផលកេ អភិរត្តានំ ទេវានំ ។ រសកេ អភិរត្តានំ ទេវានំ ។ នន្ទនេ អភិរត្តានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ តស្ស សុតំ ហោតិ នន្ទនេ អភិរត្តា ទេវា ទីឃាយុកា វណ្ណវន្តា សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា នន្ទនេ អភិរត្តានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ អន្នំ ទេតិ បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ គន្ធំ ទេតិ វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតិ ។ សោ កាយស្ស ភេទា បរំ មរណា នន្ទនេ អភិរត្តានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ

នឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានផ្កាក្រអូប ១ នឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានផ្លែក្រអូប ១ នឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានរសក្រអូប ១ ទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើមានក្លិនក្រអូបទាំងអស់ ១ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តសុចរិត ដោយកាយ ប្រព្រឹត្តសុចរិត ដោយវាចា ប្រព្រឹត្តសុចរិត ដោយចិត្ត បុគ្គលនោះ បានឮថា ពួកទេវតាដែលអាស្រ័យនៅលើឈើមានក្លិនក្រអូបទាំងអស់មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ដល់អាត្មាអញ បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើ មានក្លិនក្រអូបទាំងអស់ ។ បុគ្គលនោះ ក៏ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយានជំនិះ ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ។ លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកទេវតាដែលអាស្រ័យនៅលើឈើមានក្លិនក្រអូបទាំងអស់មែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ

យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា គន្ធ-គន្ធេ អធិវត្ថានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

(ឯវំ ឯកបិណ្ឌិតេន ឯកសតញ្ច ទ្វាទស ច សុត្តន្តា ភវន្តិ ) ។

គន្ធព្វកាយសំយុត្តំ និដ្ឋិតំ ។

## តស្សុទ្ទានំ

សុទ្ធកំ ច សុចរិតំ
ទាតា ហិ អបរេ ទស
ទានូបការា ទសធា[១]
គន្ធព្វេ សុប្បកាសិតាតិ ។

---

១ ទានូបការា ទសមា ។

ដែលនាំឲ្យបុគ្គលខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកទេវតា ដែលអាស្រ័យនៅលើឈើ មានក្លិនក្រអូបទាំងអស់ ។ (សូត្រ ១ យេ ១ ក្តី ១២ ក្តី រមែងមានដោយការប្រែប្រួលតែមួយយ៉ាងនេះ) ។

ចប់ គន្ធព្វកាយសំយុត្ត ។

## ឧទ្ទាននៃគន្ធព្វកាយសំយុត្តនោះ គឺ

និយាយអំពីគន្ធព្វកាយិកទេវតាសុទ្ធ ១ សុចរិត ១ អ្នកឲ្យទាន ១០ ពួកដទៃទៀត និងឧបការទាន ១០ ដែលឲ្យកើតជាគន្ធព្វកាយិកទេវតា ដែលទ្រង់ប្រកាសហើយ ដោយប្រពៃ ។

# វលាហកសំយុត្តំ

(២៧០) សាវត្ថី ។ វលាហកកាយិកេ ទេវេ វោ ភិក្ខវេ ទេសេស្សាមិ តំ សុណាថ ។បេ។ កតមេ ច ភិក្ខវេ វលាហកកាយិកា ទេវា ។ សន្តិ ភិក្ខវេ សីតវលាហកា ទេវា សន្តិ ភិក្ខវេ ឧណ្ហវលាហកា ទេវា សន្តិ ភិក្ខវេ អព្ភវលាហកា ទេវា សន្តិ ភិក្ខវេ វាតវលាហកា ទេវា សន្តិ ភិក្ខវេ វស្សវលាហកា ទេវា ។ ឥមេ វុច្ចន្តិ ភិក្ខវេ វលាហកកាយិកា ទេវាតិ ។

# វលាហកសំយុត្ត

(២៧០) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវទេវតាទាំងឡាយដែលជាពួកវលាហកៈ (១) ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់រឿងនោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះទេវតាទាំងឡាយដែលជាពួកវលាហកៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយដែលជាសីតវលាហកៈ (អ្នកបណ្តាលនូវធាតុត្រជាក់) ក៏មាន ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយជាឧណ្ហវលាហកៈ (អ្នកបណ្តាលនូវធាតុក្តៅ) ក៏មាន ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយជាអព្ភវលាហកៈ (អ្នកបណ្តាលនូវអ័ព្ទ) ក៏មាន ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយជាពួកវាតវលាហកៈ (អ្នកបណ្តាលនូវខ្យល់) ក៏មាន ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយ ជាពួកវស្សវលាហកៈ (អ្នកបណ្តាលនូវភ្លៀង) ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទេវតាទាំងឡាយជាពួកវលាហកៈ ។

---

១ ជាអ្នកបណ្តាលនូវការត្រជាក់ជាដើម ។

## វលាហកសំយុត្តំ

(៤៧១) សាវត្ថិ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា វលាហកកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ តស្ស សុតំ ហោតិ វលាហកកាយិកា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា វលាហកកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ អន្នំ ទេតិ ទានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ គន្ធំ ទេតិ

(៤៧១) ក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរចំពោះព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយកន្លងកាយស្លាប់ទៅ ទៅកើតជាមួយនឹងទេវតាទាំងឡាយជាពួកវលាហកៈ ។ មាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត បុគ្គលនោះបានឮថា ទេវតាទាំងឡាយជាពួកវលាហកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញដល់បែកធ្លាយកន្លងកាយស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងទេវតាទាំងឡាយជាពួកវលាហកៈ ។ បុគ្គលនោះក៏ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយានជំនិះ ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប

វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ ប-
ទីបេយ្យំ ទេតិ ។ សោ កាយស្ស ភេទា បរំ ម-
រណា វលាហកកាយិកានំ ទេវានំ សហព្យតំ ឧ-
បបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ
យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា វលា-
ហកកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

(២៧២) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ
ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ
កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ
មរណា សីតវលាហកានំ ទេវានំ សហព្យតំ ឧប-
បជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន សុចរិតំ ច-
រតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ តស្ស
សុតំ ហោតិ សីតវលាហកា ទេវា ទីឃាយុកា វណ្ណ-
វន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ
វតាហំ កាយស្ស ភេទា បរំ មរណា សីតវលាហកានំ
ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ អន្នំ ទេតិ
បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ

ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ។ លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងទេវតាទាំងឡាយជាពួកវលាហកៈមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាពួកវលាហកៈ ។

(២៧២) ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាសីតវលាហកៈ ។ ម្នាលភិក្ខុ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តសុចរិត ដោយកាយ ប្រព្រឹត្តសុចរិត ដោយវាចា ប្រព្រឹត្តសុចរិត ដោយចិត្ត បុគ្គលនោះ បានឮថា ទេវតាទាំងឡាយជាសីតវលាហកៈមានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ ដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងទេវតាទាំងឡាយជាសីតវលាហកៈ ។ បុគ្គលនោះ ក៏ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយានជំនិះ ឲ្យផ្កាកម្រង

គន្ធំ ទេតិ វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតិ ។ សោ កាយស្ស ភេទា បរំ មរណា សីតវលាហកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា សីតវលាហកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

(៤៧៣) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ឧណ្ហវលាហកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

(៤៧៤) អព្ភវលាហកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

(៤៧៥) វាតវលាហកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ។ លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាសីតវលាហកៈមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាសីតវលាហកៈ ។

( ២៧៣ ) ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាឧណ្ហវលាហកៈ ។

( ២៧៤ ) ទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាអព្ភវលាហកៈ ។

( ២៧៥ ) ទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាវាតវលាហកៈ ។

[២៦៧] ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភិក្ខុ ឯកច្ចោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ តស្ស សុតំ ហោតិ ចាតុម្មហារាជិកា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ អន្នំ ទេតិ បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ គន្ធំ ទេតិ វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតិ ។ សោ កាយស្ស ភេទា បរំ មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ កាយស្ស ភេទា បរំ មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

(២៧៦) ទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាវស្សវលាហកៈ ។ ម្នាលភិក្ខុ បុគ្គលខ្លះ ក្នុងលោកនេះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត បុគ្គលនោះ បានឮថា ទេវតាទាំងឡាយ ជាវស្សវលាហកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ ដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាវស្សវលាហកៈ ។ បុគ្គលនោះ ក៏ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយានជំនិះ ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ។ លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាវស្សវលាហកៈមែន ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យបុគ្គលខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងទេវតាទាំងឡាយ ជាវស្សវលាហកៈ ។

## វលាហកសំយុត្តំ

(២៧៧) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនេកទា សីតំ ហោតីតិ ។ សន្តិ ភិក្ខុ សីតវលាហកា នាម ទេវា តេសំ យទា ឯវំ ហោតិ យន្នូន មយំ សកាយ រតិយា រមេយ្យាមាតិ(១) តេសន្តំ ចេតោបណិធិមន្វាយ សីតំ ហោតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេនេកទា សីតំ ហោតីតិ ។

(២៧៨) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនេកទា ឧណ្ហំ ហោតីតិ ។ សន្តិ ភិក្ខុ ឧណ្ហវលាហកា នាម ទេវា តេសំ យទា ឯវំ ហោតិ យន្នូន មយំ សកាយ រតិយា រមេយ្យាមាតិ តេសន្តំ ចេតោបណិធិមន្វាយ ឧណ្ហំ ហោតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេនេកទា ឧណ្ហំ ហោតីតិ ។

---

១ ម. វិសេយ្យាមាតិ ។ ឯវំ សព្វសុត្តេសុ ។

វលាហកសំយុត្ត

( ៤៧៧ ) ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលមានត្រជាក់ម្ដងៗ ។ ម្នាលភិក្ខុ មានពួកទេវតាឈ្មោះសីតវលាហកៈ ចួនណាពួកទេវតានោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរយើងត្រេកអរដោយតម្រេករបស់ខ្លួន ព្រោះអាស្រ័យសេចក្ដីប្រាថ្នាក្នុងចិត្តនោះ របស់ទេវតាទាំងនោះ ទើបមានត្រជាក់ ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលមានត្រជាក់ម្ដងៗ ។

( ៤៧៨ ) ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលមានក្ដៅម្ដងៗ ។ ម្នាលភិក្ខុ មានពួកទេវតាឈ្មោះឧណ្ហវលាហកៈ ចួនណាពួកទេវតានោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរយើងត្រេកអរដោយតម្រេករបស់ខ្លួន ព្រោះអាស្រ័យសេចក្ដីប្រាថ្នាក្នុងចិត្តនោះ របស់ទេវតាទាំងនោះ ទើបមានក្ដៅ ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលមានក្ដៅម្ដងៗ ។

(២៧៩) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនេកច្ចោ អព្ភំ ហោតីតិ ។ សន្តិ ភិក្ខុ អព្ភវលាហកា នាម ទេវា តេសំ យទា ឯវំ ហោតិ យន្នូន មយំ សកាយ រតិយា រមេយ្យាមាតិ តេសន្តំ ចេតោបណិធិមន្វាយ អព្ភំ ហោតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេនេកច្ចោ អព្ភំ ហោតីតិ ។

(២៨០) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនេកច្ចោ វាតោ ហោតីតិ ។ សន្តិ ភិក្ខុ វាតវលាហកា នាម ទេវា តេសំ យទា ឯវំ ហោតិ យន្នូន មយំ សកាយ រតិយា រមេយ្យាមាតិ តេសន្តំ ចេតោបណិធិមន្វាយ វាតោ ហោតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេនេកច្ចោ វាតោ ហោតីតិ ។

[ ២៧៩ ] ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលមានអ័ព្ទម្ដងៗ ។ ម្នាលភិក្ខុ មានពួកទេវតាឈ្មោះអព្ភវលាហកៈ ពួកណាពួកទេវតានោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា បើដូច្នោះ គួរយើងត្រេកអរដោយតម្រេករបស់ខ្លួន ព្រោះអាស្រ័យសេចក្ដីប្រាថ្នាក្នុងចិត្តនោះ របស់ទេវតាទាំងនោះ ទើបចុះអ័ព្ទ ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលមានអ័ព្ទម្ដងៗ ។

[ ២៨០ ] ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលមានខ្យល់ម្ដងៗ ។ ម្នាលភិក្ខុ មានពួកទេវតាឈ្មោះវាតវលាហកៈ ពួកណាពួកទេវតានោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា បើដូច្នោះ គួរយើងត្រេកអរដោយតម្រេករបស់ខ្លួន ព្រោះអាស្រ័យសេចក្ដីប្រាថ្នាក្នុងចិត្តនោះ របស់ទេវតាទាំងនោះ ទើបមានខ្យល់ ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលមានខ្យល់ម្ដងៗ ។

(២៨១) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនេកច្ចា ទេវោ វស្សតីតិ ។ សន្តិ ភិក្ខុ វស្សវលាហកា នាម ទេវា តេសំ យទា ឯវំ ហោតិ យន្នូន មយំ សកាយ រតិយា រមេយ្យាមាតិ តេសំ ចេតោបណិធិមន្វាយ ទេវោ វស្សតិ ។ អយំ ខោ ភិក្ខុ ហេតុ អយំ បច្ចយោ យេនេកច្ចា ទេវោ វស្សតីតិ ។

វលាហកសំយុត្តំ និដ្ឋិតំ ។

## តស្សុទ្ទានំ

ទេសនា សុចរិតា(១) បញ្ច
ទានូបការបញ្ចមំ
សីតំ ឧណ្ហញ្ច អព្ភញ្ច
វាតវស្សវលាហកាតិ ។

---

១ ឱ ម. ទេសនា សុចរិតញ្ច ។

វលាហកសំយុត្ត

[ ២៨១ ] ក្រុងសាវត្ថី ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលមានគ្រឿងបង្អុរចុះមកឯង ។ ម្នាលភិក្ខុ មានពួកទេវតាឈ្មោះវស្សវលាហកៈ ចួនណាពួកទេវតានោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា បើដូច្នោះ គួរយើងត្រេកអរដោយតម្រេករបស់ខ្លួន ព្រោះអាស្រ័យសេចក្តីប្រាថ្នាក្នុងចិត្តនោះ របស់ទេវតាទាំងនោះ ទើបមានគ្រឿងបង្អុរចុះ ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលមានគ្រឿងបង្អុរចុះមកឯង ។

ចប់ វលាហកសំយុត្ត ។

# ឧទ្ទានក្នុងវលាហកសំយុត្តនោះ គឺ

និយាយអំពីការសំដែងនូវទេវតាជាពួកវលាហកៈ ១ បុគ្គល ៥ ពួកប្រព្រឹត្តសុចរិត ១ ឧបការទាន ៥ លើក សីតវលាហកៈ ១ ឧណ្ហវលាហកៈ ១ អព្ភវលាហកៈ ១ វាតវលាហកៈ ១ វស្សវលាហកៈ ១ ។

# វច្ឆគោត្តសំយុត្តំ

(៦៨២) ឯកំ សមយំ ភគវា សាវត្ថិយំ វិហា-រតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ វច្ឆគោត្តោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភ-គវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគ-តានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា

## វច្ឆគោត្តសំយុត្ត

( ២៨២ ) សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង បរិព្វាជក ឈ្មោះវច្ឆគោត្ត បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះវច្ឆគោត្តបរិព្វាជក អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលមានទិដ្ឋិច្រើនប្រការនេះ កើតឡើងក្នុងលោក ថា លោកទៀងក៏មាន ថា លោកមិនទៀងក៏មាន ថា លោកមានទីបំផុតក៏មាន ថា លោកមិនមានទីបំផុតក៏មាន ថា ជីវិតនោះគឺសរីរៈនោះក៏មាន

អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរំ មរណាតិ វា ន ហោតិ តថាគតោ បរំ មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។

រូបេ ខោ វច្ឆ អញ្ញាណា រូបសមុទយេ អញ្ញាណា រូបនិរោធេ អញ្ញាណា រូបនិរោធគាមិនិយា បដិបទាយ អញ្ញាណា ឯវមិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។

អយំ ខោ វច្ឆ ហេតុ អយំ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។

ថាជីវិតដទៃសរីរៈដទៃក៏មាន ថា សត្វស្លាប់ទៅកើតទៀតក៏មាន ថា សត្វស្លាប់ទៅមិនកើតទៀតក៏មាន ថា សត្វស្លាប់ទៅកើតទៀតខ្លះមិនកើតទៀតខ្លះក៏មាន ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ ម្នាលវច្ឆៈ ព្រោះការមិនដឹងក្នុងរូប មិនដឹងក្នុងហេតុដែលនាំឲ្យកើតរូប មិនដឹងក្នុងទីរលត់រូប មិនដឹងក្នុងសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់រូប ទើបទិដ្ឋិច្រើនប្រការនេះ កើតឡើងក្នុងលោកយ៉ាងនេះថា លោកទៀងក៏មាន ។ បេ ។ ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ ម្នាលវច្ឆៈ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យទិដ្ឋិច្រើនប្រការនេះ កើតឡើងក្នុងលោកថា លោកទៀងក៏មាន ។ បេ ។ ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។

(២៨៣) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ វេទនាយ ខោ វច្ឆ អញ្ញាណា វេទនាសមុទយេ អញ្ញាណា វេទនានិរោធេ អញ្ញាណា វេទនានិរោធគាមិនិយា បដិបទាយ អញ្ញាណា ឯវមិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ អយំ ខោ វច្ឆ ហេតុ អយំ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។

(២៨៣) ក្រុងសាវត្ថី ។ លុះវច្ឆគោត្តបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលបណ្ដាលឲ្យទិដ្ឋិច្រើនប្រការនេះកើតឡើងក្នុងលោកថា លោកទៀងក៏មាន ថា លោកមិនទៀងក៏មាន ។ បេ ។ ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ ម្នាលវច្ឆៈ ព្រោះការមិនដឹងក្នុងវេទនា មិនដឹងក្នុងហេតុដែលនាំឲ្យកើតវេទនា មិនដឹងក្នុងទីរលត់វេទនា មិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់វេទនា នេះដែលនាំឲ្យទិដ្ឋិច្រើនប្រការកើតឡើងក្នុងលោកយ៉ាងនេះថា លោកទៀងក៏មាន ថា លោកមិនទៀងក៏មាន ។ បេ ។ ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ ម្នាលវច្ឆៈ នេះជាហេតុ នេះជាបច្ច័យ ដែលបណ្ដាលឲ្យទិដ្ឋិច្រើនប្រការនេះកើតឡើងក្នុងលោកថា លោកទៀងក៏មាន ថា លោកមិនទៀងក៏មាន ។ បេ ។ ថា សត្វស្លាប់ទៅកើតទៀងក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។

## វច្ឆគោត្តសំយុត្តំ

(២៨៤) សាវត្ថីៗ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ សញ្ញាយ ខោ វច្ឆ អញ្ញាណា សញ្ញាសមុទយេ អញ្ញាណា សញ្ញានិរោធេ អញ្ញាណា សញ្ញានិរោធគាមិនិយា បដិបទាយ អញ្ញាណា ឯវមិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ អយំ ខោ វច្ឆ ហេតុ អយំ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។

វច្ឆគោត្តសំយុត្ត

( ៤៨៤ ) ក្រុងសាវត្ថី ។ លុះវច្ឆគោត្តបរិញ្វជក អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលបណ្ដាលឲ្យទិដ្ឋិច្រើនប្រការនេះ កើតឡើងក្នុងលោកថា លោកទៀងក៏មាន លោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលវច្ឆៈ ព្រោះការមិនដឹងក្នុងសញ្ញា មិនដឹងក្នុងហេតុដែលនាំឲ្យកើតសញ្ញា មិនដឹងក្នុងទីរលត់សញ្ញា មិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់សញ្ញា នេះឯងដែលនាំឲ្យទិដ្ឋិច្រើនប្រការកើតឡើងក្នុងលោក យ៉ាងនេះថា លោកទៀងក៏មាន ថាលោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលវច្ឆៈ នេះជាហេតុ នេះជាបច្ច័យ ដែលបណ្ដាលឲ្យទិដ្ឋិច្រើនប្រការនេះ កើតឡើងក្នុងលោកថា លោកទៀងក៏មាន ថាលោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

(២៨៨) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ សង្ខារេសុ ខោ វច្ឆ អញ្ញាណា សង្ខារសមុទយេ អញ្ញាណា សង្ខារនិរោធេ អញ្ញាណា សង្ខារនិរោធគាមិនិយា បដិបទាយ អញ្ញាណា ឯវមិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ អយំ ខោ វច្ឆ ហេតុ អយំ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។

( ២៨៥ ) ក្រុងសាវត្ថី ។ លុះវច្ឆគោត្តបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យទិដ្ឋិច្រើនប្រការនេះ កើតឡើងក្នុងលោកថា លោកទៀងក៏មាន ថាលោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ ម្នាលវច្ឆៈ ព្រោះការមិនដឹងក្នុងសង្ខារទាំងឡាយ មិនដឹងក្នុងហេតុនាំឲ្យកើតសង្ខារ មិនដឹងក្នុងទីរលត់សង្ខារ មិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់សង្ខារ នេះហើយដែលនាំឲ្យទិដ្ឋិច្រើនប្រការកើតឡើងក្នុងលោកយ៉ាងនេះថា លោកទៀងក៏មាន លោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ ម្នាលវច្ឆៈ នេះជាហេតុ នេះជាបច្ច័យ ដែលបណ្តាលឲ្យទិដ្ឋិច្រើនប្រការនេះ កើតឡើងក្នុងលោកថា លោកទៀងក៏មាន ថាលោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

## វច្ឆគោត្តសំយុត្តំ

(៤៨៦) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ វិញ្ញាណេ ខោ វច្ឆ អញ្ញាណា វិញ្ញាណសមុទយេ អញ្ញាណា វិញ្ញាណនិរោធេ អញ្ញាណា វិញ្ញាណនិរោធគាមិនិយា បដិបទាយ អញ្ញាណា ឯវមិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ អយំ ខោ វច្ឆ ហេតុ អយំ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។

[ ២៨៦ ] ក្រុងសាវត្ថី ។ លុះវច្ឆគោត្តបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលបណ្ដាលឲ្យទិដ្ឋិច្រើនប្រការនេះកើតឡើងក្នុងលោកថា លោកទៀងក៏មាន ថាលោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ ម្នាលវច្ឆៈ ព្រោះការមិនដឹងក្នុងវិញ្ញាណ មិនដឹងក្នុងហេតុដែលនាំឲ្យកើតវិញ្ញាណ មិនដឹងក្នុងទីរលត់វិញ្ញាណ មិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់វិញ្ញាណ នេះឯងហើយដែលនាំឲ្យទិដ្ឋិច្រើនប្រការ កើតឡើងក្នុងលោក យ៉ាងនេះថា លោកទៀងក៏មាន ថាលោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ ម្នាលវច្ឆៈ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យទិដ្ឋិច្រើនប្រការនេះកើតឡើងក្នុងលោកថា លោកទៀងក៏មាន ថាលោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

(២៨៧) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ រូបេ ខោ វច្ឆ អទស្សនា ។បេ។ រូបនិរោធគាមិនិយា បដិបទាយ អទស្សនា ។បេ។

(២៨៨) សាវត្ថី ។ វេទនាយ ខោ វច្ឆ អទស្សនា ។

(២៨៩) សាវត្ថី ។ សញ្ញាយ ខោ វច្ឆ អទស្សនា ។

(២៩០) សាវត្ថី ។ សង្ខារេសុ ខោ វច្ឆ អទស្សនា ។

(២៩១) សាវត្ថី ។ វិញ្ញាណេ ខោ វច្ឆ អទស្សនា ។បេ។ វិញ្ញាណនិរោធគាមិនិយា បដិបទាយ អទស្សនា ។(១)

(២៩២) សាវត្ថី ។ រូបេ ខោ អនភិសមយា ។បេ។ រូបនិរោធគាមិនិយា បដិបទាយ អនភិសមយា ។បេ។

---

១ ឱ. យថា បុរិម គមនំ ឯវម្បញ្ចបិ ខន្ធា បញ្ចហិ គមនេហិ វិត្ថារេតព្វា ។

(៤៨៧) ក្រុងសាវត្ថី ។ លុះវច្ឆគោត្តបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យទិដ្ឋិច្រើនប្រការនេះកើតឡើងក្នុងលោកថា លោកទៀងក៏មាន ថាលោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ ម្នាលវច្ឆៈ ព្រោះការមិនឃើញក្នុងរូប ។ បេ ។ មិនឃើញក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់រូប ។ បេ ។

(៤៨៨) ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ព្រោះការមិនឃើញក្នុងវេទនា ។

(៤៨៩) ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ព្រោះការមិនឃើញក្នុងសញ្ញា ។

(៤៩០) ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ព្រោះការមិនឃើញក្នុងសង្ខារទាំងឡាយ ។

(៤៩១) ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ព្រោះការមិនឃើញក្នុងវិញ្ញាណ ។ បេ ។ ព្រោះការមិនឃើញក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់វិញ្ញាណ ។

(៤៩២) ក្រុងសាវត្ថី ។ ព្រោះការមិនត្រាស់ដឹងក្នុងរូប ។ បេ ។ ព្រោះការមិនត្រាស់ដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់រូប ។ បេ ។

វច្ឆគោត្តសំយុត្តំ

(២៩៣) សាវត្ថី ។ វេទនាយ ខោ វច្ឆ អនភិសមយា ។ បេ ។

(២៩៤) សាវត្ថី ។ សញ្ញាយ ខោ វច្ឆ អនភិសមយា ។ បេ ។

(២៩៥) សាវត្ថី ។ សង្ខារេសុ ខោ វច្ឆ អនភិសមយា ។ បេ ។

(២៩៦) សាវត្ថី ។ វិញ្ញាណេ ខោ វច្ឆ អនភិសមយា ។ បេ ។

(២៩៧) សាវត្ថី ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ ។ បេ ។ រូបេ ខោ វច្ឆ អននុពោធា ។ បេ ។ រូបនិរោធគាមិនិយា បដិបទាយ អននុពោធា ។ បេ ។

(២៩៨) សាវត្ថី ។ វេទនាយ ខោ វច្ឆ ។ បេ ។

(២៩៩) សាវត្ថី ។ សញ្ញាយ ខោ វច្ឆ ។ បេ ។

(៣០០) សាវត្ថី ។ សង្ខារេសុ ខោ វច្ឆ ។ បេ ។

[២៩៣] ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ព្រោះការមិនត្រាស់ដឹងក្នុងវេទនា ។ បេ ។

[២៩៤] ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ព្រោះការមិនត្រាស់ដឹងក្នុងសញ្ញា ។ បេ ។

[២៩៥] ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ព្រោះការមិនត្រាស់ដឹងក្នុងសង្ខារទាំងឡាយ ។ បេ ។

[២៩៦] ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ព្រោះការមិនត្រាស់ដឹងក្នុងវិញ្ញាណ ។ បេ ។

[២៩៧] ក្រុងសាវត្ថី ។ លុះវច្ឆគោត្តបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ។ បេ ។ ម្នាលវច្ឆៈ ព្រោះការមិនត្រាស់ដឹងតាម ក្នុងរូប ។ បេ ។ ព្រោះការមិនត្រាស់ដឹងតាម ក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់រូប ។ បេ ។

[២៩៨] ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ក្នុងវេទនា ។ បេ ។

[២៩៩] ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ក្នុងសញ្ញា ។ បេ ។

[៣០០] ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ក្នុងសង្ខារទាំងឡាយ ។ បេ ។

(៣០១) សាវត្ថី ។ វិញ្ញាណេ ខោ វត្ថុ អនន្តុ-
តោតា ។ បេ ។ វិញ្ញាណនិរោធគាមិនិយា បដិនាយ
អនន្តុតោតា ។ បេ ។

(៣០២) សាវត្ថី ។ កោ នុ ខោ ភោ គោតម
ហេតុ កោ បច្ចយោ ។ បេ ។ រូបេ ខោ វត្ថុ អប្បដិ-
វេធា ។ បេ ។ វិញ្ញាណេ ខោ វត្ថុ អប្បដិវេធា ។ បេ ។

(៣០៣) សាវត្ថី ។ រូបេ ខោ វត្ថុ អសល្លក្ខ-
ណា ។ បេ ។ វិញ្ញាណេ ខោ វត្ថុ អសល្លក្ខណា ។ បេ ។

(៣០៤) សាវត្ថី ។ រូបេ ខោ វត្ថុ អនុបលក្ខ-
ណា ។ បេ ។ វិញ្ញាណេ ខោ វត្ថុ អនុបលក្ខណា ។ បេ ។

(៣០៥) សាវត្ថី ។ រូបេ ខោ វត្ថុ អសមបេក្ខណា
។ បេ ។ វិញ្ញាណេ ខោ វត្ថុ អសមបេក្ខណា ។ បេ ។

(៣០៦) សាវត្ថី ។ រូបេ ខោ វត្ថុ អប្បច្ចវេក្ខណា
។ បេ ។ វិញ្ញាណេ ខោ វត្ថុ អប្បច្ចវេក្ខណា ។ បេ ។

( ៣០១ ) ក្រុងសាវត្ថី ។ មូលវត្ថុ: ព្រោះការមិនត្រាស់ដឹងតាមកងវិញ្ញាណ ។ បេ ។ ព្រោះការមិនត្រាស់ដឹងតាម កងបដិបទាជាដំណើរទៅកាន់ទីរលត់វិញ្ញាណ ។ បេ ។

( ៣០២ ) ក្រុងសាវត្ថី ។ បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ។ បេ ។ មូលវត្ថុ: ព្រោះការមិនចាក់ធ្លុះ កងរូប ។ បេ ។ មូលវត្ថុ: ព្រោះការមិនចាក់ធ្លុះកងវិញ្ញាណ ។ បេ ។

( ៣០៣ ) ក្រុងសាវត្ថី ។ មូលវត្ថុ: ព្រោះការមិនកំណត់កងរូប ។ បេ ។ មូលវត្ថុ: ព្រោះការមិនកំណត់កងវិញ្ញាណ ។ បេ ។

( ៣០៤ ) ក្រុងសាវត្ថី ។ មូលវត្ថុ: ព្រោះការមិនចូលទៅកំណត់កងរូប ។ បេ ។ មូលវត្ថុ: ព្រោះការមិនចូលទៅកំណត់កងវិញ្ញាណ ។ បេ ។

( ៣០៥ ) ក្រុងសាវត្ថី ។ មូលវត្ថុ: ព្រោះការមិនបានសំឡឹងលែលកកងរូប ។ បេ ។ មូលវត្ថុ: ព្រោះការមិនបានសំឡឹងលែលកកងវិញ្ញាណ ។ បេ ។

( ៣០៦ ) ក្រុងសាវត្ថី ។ មូលវត្ថុ: ព្រោះការមិនពិចារណាកងរូប ។ បេ ។ មូលវត្ថុ: ព្រោះការមិនពិចារណាកងវិញ្ញាណ ។ បេ ។

## វច្ឆគោត្តសំយុត្តំ

(៣០៧) សាវត្ថី ។ រូបេ ខោ វច្ឆ អប្បច្ចុបលក្ខណា ។ បេ ។ វិញ្ញាណេ ខោ វច្ឆ អប្បច្ចុបលក្ខណា ។ បេ ។

(៣០៨) សាវត្ថី ។ អថខោ វច្ឆគោត្តោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ រូបេ ខោ វច្ឆ អប្បច្ចក្ខកម្មា រូបសមុទយេ អប្បច្ចក្ខកម្មា រូបនិរោធេ អប្បច្ចក្ខកម្មា រូបនិរោធគាមិនិយា បដិបទាយ អប្បច្ចក្ខកម្មា ។ បេ ។

វច្ឆគោត្តសំយុត្ត

( ៣០៧ ) ក្រុងសាវត្ថី ។ ម្នាលវច្ឆៈ ព្រោះការមិនបានចូលទៅកំណត់ ក្នុងរូប ។បេ។ ម្នាលវច្ឆៈ ព្រោះការមិនបានចូលទៅកំណត់ក្នុងវិញ្ញាណ ។បេ។

( ៣០៨ ) ក្រុងសាវត្ថី ។ គ្រានោះឯង វច្ឆគោត្តបរិព្វាជកចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះវច្ឆគោត្តបរិព្វាជកអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលបណ្តាលឲ្យទិដ្ឋិច្រើនប្រការនេះ កើតឡើងក្នុងលោកថា លោកទៀងក៏មាន ថាលោកមិនទៀងក៏មាន ។បេ។ ថាសត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលវច្ឆៈ ព្រោះការមិនធ្វើឲ្យជាក់ច្បាស់ក្នុងរូប ការមិនធ្វើឲ្យជាក់ច្បាស់ក្នុងហេតុដែលនាំឲ្យកើតរូប ការមិនធ្វើឲ្យជាក់ច្បាស់ក្នុងទីរលត់រូប ការមិនធ្វើឲ្យជាក់ច្បាស់ក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់រូប ។បេ។

(៣០៩) សាវត្ថី ។ វេទនាយ ខោ វច្ឆ អប្បច្ចក្ខកម្មា ។ បេ ។ វេទនានិរោធគាមិនិយា បដិបទាយ អប្បច្ចក្ខកម្មា ។ បេ ។

(៣១០) សាវត្ថី ។ សញ្ញាយ ខោ វច្ឆ អប្បច្ចក្ខកម្មា ។ បេ ។ សញ្ញានិរោធគាមិនិយា បដិបទាយ អប្បច្ចក្ខកម្មា ។ បេ ។

(៣១១) សាវត្ថី ។ សង្ខារេសុ ខោ វច្ឆ អប្បច្ចក្ខកម្មា ។ បេ ។ សង្ខារនិរោធគាមិនិយា បដិបទាយ អប្បច្ចក្ខកម្មា ។ បេ ។

(៣១២) សាវត្ថី ។ វិញ្ញាណេ ខោ វច្ឆ អប្បច្ចក្ខកម្មា វិញ្ញាណសមុទយេ អប្បច្ចក្ខកម្មា វិញ្ញាណនិរោធេ អប្បច្ចក្ខកម្មា វិញ្ញាណនិរោធគាមិនិយា បដិបទាយ អប្បច្ចក្ខកម្មា ឯវមិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា

[ ៣០៩ ] ក្រុងសាវត្ថី ។ មាលវំបុះ ព្រោះការមិនធ្វើឲ្យជាក់ច្បាស់នូវវេទនា ។ បេ ។ ព្រោះការមិនធ្វើឲ្យជាក់ច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់វេទនា ។ បេ ។

[ ៣១០ ] ក្រុងសាវត្ថី ។ មាលវំបុះ ព្រោះការមិនធ្វើឲ្យជាក់ច្បាស់នូវសញ្ញា ។ បេ ។ ព្រោះការមិនធ្វើឲ្យជាក់ច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់សញ្ញា ។ បេ ។

[ ៣១១ ] ក្រុងសាវត្ថី ។ មាលវំបុះ ព្រោះការមិនធ្វើឲ្យជាក់ច្បាស់នូវសង្ខារទាំងឡាយ ។ បេ ។ ព្រោះការមិនធ្វើឲ្យជាក់ច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់សង្ខារ ។ បេ ។

[ ៣១២ ] ក្រុងសាវត្ថី ។ មាលវំបុះ ព្រោះការមិនធ្វើឲ្យជាក់ច្បាស់នូវវិញ្ញាណ ការមិនធ្វើឲ្យជាក់ច្បាស់នូវហេតុដែលនាំឲ្យកើតវិញ្ញាណ ការមិនធ្វើឲ្យជាក់ច្បាស់នូវទីរលត់វិញ្ញាណ ការមិនធ្វើឲ្យជាក់ច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់វិញ្ញាណ នេះឯងហើយដែលនាំឲ្យទិដ្ឋិច្រើនប្រការកើតឡើងក្នុងលោកយ៉ាងនេះថា លោកទៀងក៏មាន

វច្ឆគោត្តសំយុត្តំ

។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ អយំ ខោ វច្ឆ ហេតុ អយំ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរំ មរណាតិ វា ន ហោតិ តថាគតោ បរំ មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ អយំ ខោ វច្ឆ ហេតុ អយំ បច្ចយោ យានិមានិ អនេកវិហិតានិ ទិដ្ឋិគតានិ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ ( ឯកាបិណ្ណោន បញ្ចបញ្ញាសំ សុត្តន្តា ភវន្តិ ) ។

វច្ឆគោត្តសំយុត្តំ និដ្ឋិតំ ។

## វច្ឆគោត្តសំយុត្ត

។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលវច្ឆៈ នេះជាហេតុ នេះជាបច្ច័យ ដែលបណ្តាលឲ្យទិដ្ឋិច្រើនប្រការនេះកើតឡើងក្នុងលោកថា លោកទៀងក៏មាន ថាលោកមិនទៀងក៏មាន ថាលោកមានទីបំផុតក៏មាន ថាលោកមិនមានទីបំផុតក៏មាន ថាជីវិតនោះគឺសរីរៈនោះក៏មាន ថាជីវិតដទៃ សរីរៈដទៃក៏មាន ថាសត្វស្លាប់ទៅកើតទៀតក៏មាន ថាសត្វស្លាប់ទៅមិនកើតទៀតក៏មាន ថាសត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មាន ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលវច្ឆៈ នេះជាហេតុ នេះជាបច្ច័យ ដែលបណ្តាលឲ្យទិដ្ឋិច្រើនប្រការនេះ កើតឡើងក្នុងលោកថា លោកទៀងក៏មាន លោកមិនទៀងក៏មាន ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

( សូត្រ ៥៥ មានដោយការប្រែប្រួលគ្នាតែមួយ ) ។

ចប់ វច្ឆគោត្តសំយុត្ត

## ឥទំ សំយុត្តស្ស ឧទ្ទានំ

អញ្ញាណា អទស្សនញ្ចេវ

អនភិសមយា អននុពោធា

អប្បដិវេធា អសល្លក្ខណា

អនុបលក្ខណេន អសមបេក្ខណា

អប្បច្ចវេក្ខណា អបច្ចុបលក្ខណា

អប្បច្ចក្ខកម្មន្តិ ។

## នេះជាឧទ្ទាននៃវច្ឆគោត្តសំយុត្ត គឺ

និយាយអំពីការមិនដឹង ១ ការមិនឃើញ ១ ការមិនត្រាស់ដឹង ១ ការមិនត្រាស់ដឹងតាម ១ ការមិនចាក់ធ្លុះចំពោះ ១ ការមិនកំណត់ ១ ការមិនចូលទៅកំណត់ ១ ការមិនសំឡឹងលៃលក ១ ការមិនពិចារណា ១ ការមិនចូលទៅពិចារណា ១ ការមិនធ្វើឲ្យជាក់ច្បាស់ ១ ។

---

# សមាធិសំយុត្តំ

(៣០៣) សាវត្ថី ។ តត្រ ខោ ។បេ។ ចត្តារោមេ ភិក្ខវេ ឈាយី ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ ឈាយី សមាធិស្មឹ សមាធិកុសលោ ហោតិ ន សមាធិស្មឹ សមាបត្តិកុសលោ ។ ឥធ បន ភិក្ខវេ ឯកច្ចោ ឈាយី សមាធិស្មឹ សមាបត្តិកុសលោ ហោតិ ន សមាធិស្មឹ សមាធិកុសលោ ។ ឥធ បន ភិក្ខវេ ឯកច្ចោ ឈាយី នេវ សមាធិស្មឹ សមាធិកុសលោ ហោតិ ន សមាធិស្មឹ សមាបត្តិកុសលោ ។ ឥធ បន ភិក្ខវេ ឯកច្ចោ ឈាយី សមាធិស្មឹ សមាធិកុសលោ ច ហោតិ សមាធិស្មឹ សមាបត្តិកុសលោ ច ។ តត្រ ភិក្ខវេ យ្វាយំ ឈាយី សមាធិស្មឹ សមាធិកុសលោ ច សមាធិស្មឹ សមាបត្តិកុសលោ ច ។ អយំ ឥមេសំ ចតុន្នំ ឈាយីនំ អគ្គោ ច សេដ្ឋោ ច បាមោក្ខោ ច ឧត្តមោ ច

# សមាធិសំយុត្ត

